ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្ដីនៅដំណាក់កាលពីរ

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសង

**ថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦**

**ម៉ោង ០៩:០០នាទី**

**សវនាការលើកទី៤៥០**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 24-Jan-2017, 11:20
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម យ៉ា សុខន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្ដរា

ចៅក្រម ធូ មណី

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឯម ហ៊ុយ

លោក រ៉ូជឺ ហ្វីលីព *(Mr.Roger PHILLIP)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

កញ្ញា សុង ឆវ័ន្ត

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក លីវ សុវណ្ណា

លោកស្រី ដូរីន ជិន*(Mrs. Doreen CHEN)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វលក្ស

លោក ខលវីន សោនដឺស៍

*(Mr Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD)*

លោក ឡេ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ស៊ីន សុវ៉ន

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម យ៉ា សុខន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក លីវ សុវណ្ណា | ខ្មែរ |
| លោកស្រី ដូរីន ជិន | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី ម៉ារី ហ្គីរ៉ូដ៍ | បារាំង |
| លោកស្រី ណុប ងឹម (2-TCW-1002) | ខ្មែរ |

## ខ្លឹមសារ

**ការសួរសំណួរទៅសាក្សី ៖ លោកស្រី ណុប ទីម** (2-TCW-1002)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........ ទំព័រ ១៨
សួរដោយលោក នីកូឡាស គូមជែន ផ្តើមពី ........ ទំព័រ ២០
សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍ ផ្តើមពី ........ ទំព័រ ៣៤
សួរដោយលោក ពេជ អង្គ ផ្តើមពី ........ ទំព័រ ៣៦
សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........ ទំព័រ ៤១
សួរដោយលោក លីវ សុវណ្ណា ផ្តើមពី ........ ទំព័រ ៤៧
សួរដោយចៅក្រម ក្លូឌា ហ្វេនស៍ ផ្តើមពី ........ ទំព័រ ៥៨
សួរដោយលោកស្រី ដូរីន ជិន ផ្តើមពី ........ ទំព័រ ៦០

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:៥៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះនឹងស្ដាប់ចម្លើយតបរបស់ភាគីនានា ពាក់ព័ន្ធនឹងសំណើសុំចំនួនបីតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងទាក់ទងនឹងអ្នកជំនាញ 2-TCE-82 បន្ទាប់មកនឹងចាប់ផ្ដើមសក្ខីកម្មសាក្សី 2-TCW-1002។

ក្រឡាបញ្ជីសវនាការ លោក ឯម ហ៊ុយ ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគី និងបុគ្គលទាំងឡាយដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថាគ្រប់ភាគីទាំងអស់នៃរឿងក្ដីនេះ មានវត្តមាន។ លើកលែងតែលោកមេធាវី ខេរិន សូម៉ុរ អវត្តមានដោយស្មះសាវាចរ គាត់ឃើតបន្តិច ហើយនិងលោកមេធាវី ពេជ អង្គ អវត្តមាន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សាក្សីដែលត្រូវមកផ្ដល់សក្ខីកម្មបញ្ចប់នៅថ្ងៃនេះ មានរហស្សនាម 2-TCW-1002 សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន ឬភាគីដើមបណ្ដឹងរដ្ឋប្បវេណីណាមួយដែលត្រូវទទួលស្គាល់នៅក្នុងរឿងក្ដីនេះទេ។ សាក្សីបានធ្វើសម្បថរួចហើយនៅចំពោះមុខលោកតាដំបងដែកកាលពីព្រឹកមិញនេះ។ សាក្សីមានវត្តមានរួចហើយនៅក្នុងបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សូមអរគុណលោកប្រធាន។

[០៩:០៣:០៦]

**ប្រធានអង្គជំនុំ៖**

អរគុណលោក ឯម ហ៊ុយ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន និងមិនអាចផ្ដង់អារម្មណ៍បានយូរ និងដើម្បីមានលទ្ធភាពចូលរួមសវនាការនាថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និង មានវត្តមានដោយផ្ទាល់ក្នុងបន្ទប់សវនាការនៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦។

មេធាវីការពារក្ដីរបស់ខ្លួនបានប្រាប់អំពីផលប៉ះពាល់នៃការលះបង់សិទ្ធិនេះថា ការលះបង់សិទ្ធិនេះ មិនអាចបកស្រាយថាជាការលះបង់សិទ្ធិរបស់ខ្លួនក្នុងការកាត់សេចក្ដីដោយយុត្តិធម៌ ឬក៏សិទ្ធិក្នុងការជំទាស់ទៅនឹងភស្តុតាងក្នុងការដាក់បង្ហាញ ឬដាក់ជូនតុលាការនេះគ្រប់ពេលវេលានៃសវនាការលើរូបខ្លួនឡើយ។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំ-ការ ពិនិត្យ ព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០១៦ បានកត់សម្គាល់ថា ស្ថានភាពសុខភាពរបស់លោក នួន ជា ថ្ងៃនេះមានអាការៈឈឺចង្កេះពិបាកអង្គុយយូរ និងបានផ្ដល់អនុសាសន៍ថា សូមឲ្យអង្គជំនុំជម្រះអនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមកិច្ច តាមដានកិច្ច -- ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់ខាងក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និង យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះយល់ព្រម និងអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញ១ថ្ងៃនេះ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួមនិងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅខាងក្រោមសាលសវនាការនេះ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

[០៩:០៥:០០]

មុននឹងចាប់ផ្ដើមស្ដាប់សក្ខីកម្មសាក្សី 2-TCW-1002 អង្គជំនុំជម្រះនឹងស្ដាប់ចម្លើយតបរបស់ភាគីនានាពាក់ព័ន្ធនឹងសំណើសុំចំនួនបីតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុងដែលទាក់ទងនឹងអ្នកជំនាញ

2-TCE-82។ កាលពីថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១៦ សហព្រះរាជអាជ្ញាបានស្នើសុំឱ្យទទួលយកធ្វើជាភស្តុតាង យកជាឯកសារភស្តុតាងនូវឯកសារចំនួនពីរដែលនិពន្ធដោយអ្នកជំនាញ 2-TCE-82, ឯកសារ E331/1។ ឯកសារទី១ ការសិក្សាធ្វើឡើងដោយអ្នកជំនាញ 2-TCE-82 ដែលមានចំណងជើងថា "អំពើហិង្សាផ្អែកយេនឌ័រប្រឆាំងអនីតិភាពផ្លូវភេទក្នុងរបបខ្មែរក្រហម"។ ឯកសារទី២ សៀវភៅដែលមានចំណងជើងថា "មាតុភាពពេលសង្គ្រាម ការមានផ្ទៃពោះក្នុងរបបខ្មែរក្រហម"។ ដែលឯកសារទាំងពីរនេះមាននៅក្នុងប្រពន្ធឯកសាររួមនៅក្នុង*ហ្សាយឡូ*រួចហើយ ដែលមានលេខ ERN ជាភាសាអង់គ្លេស 01322766 ដល់ 01322839, និង 01322840 ដល់ 01322893។ នៅថ្ងៃដដែលនោះមេធាវីការពារក្តីលោក ខៀវ សំផន ក៏ដាក់សំណើតាមវិធាន៨៧(៤) សុំឱ្យទទួលយកធ្វើជាភស្តុតាងនូវប្រវត្តិរូបរបស់អ្នកជំនាញ 2-TCE-82 និងឯកសារចំនួនប្រាំផ្សេងទៀត ដែលមេធាវីការពារក្តីមានបំណងប្រើប្រាស់ក្នុងការសួរដេញដោលទៅអ្នកជំនាញ 2-TCE-82, ឯកសារ E331/2។ ហើយមេធាវីការពារក្តីលោក នួន ជា ក៏បានដាក់សំណើតាមវិធាន៨៧(៤) និងសំណើអនុលោមតាមវិធាន៩៣ ទាក់ទងនឹងអ្នកជំនាញ 2-TCE-82 នៅថ្ងៃនោះដែរ ឯកសារ E331/3។ មេធាវីការពារក្តីស្នើសុំឱ្យទទួលយកឯកសារចំនួនពីរធ្វើជាឯកសារភស្តុតាងគឺ ឯកសារទី១ ប្រវត្តិរូបការងាររបស់អ្នកជំនាញ 2-TCE-82 និងឯកសារទី២ របាយការណ៍របស់អ្នកជំនាញស្តីពីការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងអំឡុងជម្លោះនៅប្រទេសសៀរ៉ាឡេអូន ដែលរៀបរៀងដោយ ហ្សេណេប ប៊ីងហ្គូរ៉ា និង គ្រីស្ទីណា សូឡូម៉ុងដ៍។

[០៩:០៧:៣៧]

ដោយសារតែអ្នកជំនាញ 2-TCE នឹងមកផ្តល់សក្ខីកម្មក្នុងពេលឆាប់ៗខាងមុខនេះ ហេតុនេះអង្គជំនុំជម្រះមានបំណងស្តាប់ចម្លើយតបផ្ទាល់មាត់របស់ភាគីនានា ទៅលើភាពអាចទទួលយកបាននៃឯកសារទាំងនេះ។

ជាដំបូងអង្គជំនុំជម្រះសូមប្រគល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាក្នុងការឆ្លើយតបទៅនឹងសំណើសុំឱ្យទទួលយកឯកសារទាំងនេះ។ សូមអញ្ជើញ!

**លោក វីល្លៀម ស្មីត៖**

ជម្រាបសួរលោក លោកស្រីចៅក្រម លោកប្រធាន ហើយនិងភាគី។ ពាក់ព័ន្ធទៅនឹងសំណើរបស់មេធាវី ខៀវ សំផន ដើម្បីដាក់ចូលឯកសារប្រាំមួយជាភស្តុតាង គឺថាសហព្រះរាជអាជ្ញាមិនមានការជំទាស់ទៅនឹងសំណើនេះទេ ដោយពិនិត្យលើភាពពាក់ព័ន្ធនឹងបរិបទ។ ចំពោះសំណើរបស់មេធាវី

នួន ជា ដើម្បីសុំដាក់ឯកសារពីរ គឺប្រវត្តិរបស់អ្នកជំនាញ ហើយនិងភាពទំនាក់ទំនងទៅនឹងអាពាហ៍ពិពាហ៍ដោយបង្ខំនៅសៀរ៉ាឡេអូន គឺថាសុំរំឭកថា គឺមេធាវីនឹងសួរទៅអ្នកជំនាញ<លើបញ្ហាមួយចំនួនដែលកើតឡើងនៅទីនោះ> គឺថាយើងមិនជំទាស់ទេ ចំពោះការដាក់ចូលឯកសារក្នុងភស្តុតាង។ អ៊ីចឹងប្រហែលដូចយើងទៅវិធាន៩៣ សំណើតាមវិធាន៩៣ របស់មេធាវី នួន ជា។ ជាទូទៅយើងជំទាស់នឹងសំណើរបស់គាត់ចំពោះឯកសារសំខាន់ៗមួយចំនួនដែលពាក់ព័ន្ធទៅនឹងអ្នកជំនាញ ជាពិសេសរបាយ-ការណ៍អ្នកជំនាញ។ មូលដ្ឋានសំខាន់នៃការជំទាស់នោះគឺថា សំណើ<>នេះដាក់មិនទាន់ពេល ហើយយឺតពេលខ្លាំងណាស់។ មូលហេតុទី២ មិនអាចធ្វើសំណើនៅពេលមួយដែលមេធាវីការពារក្ដីត្រូវបានអនុញ្ញាត<ឱ្យ -- ក្នុងពេលដែលតុលាការស្នើសុំឱ្យមេធាវីការពារក្ដី>ផ្ដល់<ឯកសារ>ទៅតុលាការនោះគឺមិនត្រឹមត្រូវ។

[០៩:០៩:៥១]

មូលដ្ឋានទី៣គឺថា ឯកសារទាំងនេះគឺថាបញ្ជាក់ពីការស្រាវជ្រាវ គឺមិនតម្រូវឱ្យមានការបង្ហាញជាភស្តុតាងដោយផ្អែកទៅលើគោលការណ៍សំខាន់នៃសក្ខីកម្មរបស់អ្នកជំនាញនេះទេ។ អ៊ីចឹងជាដំបូង ខ្ញុំសូមជម្រាបថា មេធាវីការពារក្ដីបានស្នើ ហើយនៅក្នុងសំណើហ្នឹង គឺថាសុំបទសម្ភាសន៍ដែលនាំឱ្យចូលទៅដល់របាយការណ៍ដែលនិយាយអំពីការបំពារបំពានរំលោភខាងយេនឌ័រនៅក្នុងកម្ពុប្រជាធិបតេយ្យ។ <ពួកគេកំពុងស្នើសុំប្រតិចារឹកចំនួន១០០ ដែលជា>បទសម្ភាសន៍<>ធ្វើដោយអ្នកជំនាញនិងអ្នកផ្សេងទៀត។ ហើយសូមឱ្យមានបទសម្ភាសន៍ ដំបូង១៥០០ ដែលធ្វើឡើងដោយមនុស្សផ្សេងទៀតនៅក្នុងគម្រោង មេធាវីការពារក្ដី គម្រោងការពារក្ដីកម្ពុជា ដែលសរុប<ទៅ>ឃើញមានចំនួន<១.៦០០>ដល់ពេលនេះ។ ហើយគឺថាមានបទសម្ភាសន៍៦០០ទៀត ដែលសាកលវិទ្យាល័យបានឱ្យនិស្សិតធ្វើសម្ភាសន៍និយាយអំពីអំពើហិង្សាយេនឌ័រ ហើយនិងផ្លូវភេទដែលកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តែមានភាពពាក់ព័ន្ធទៅនឹងការរៀបការដោយបង្ខំផង។ ដោយអ៊ីចឹងជាសរុបនោះ គឺថាមេធាវីការពារក្ដីសុំឱ្យមានបទសម្ភាសន៍២២០០នៃបទសម្ភាសន៍ ដើម្បីដាក់បញ្ចូលក្នុងសំណុំរឿងជាភស្តុតាង។ <វាហាក់ដូចជាថា កិច្ចសម្ភាសន៍នោះភាគច្រើនគឺធ្វើជាភាសាខ្មែរ។> សំណើបែបនេះ ត្រូវបានធ្វើឡើង គឺថ្ងៃពុធអាទិត្យទៅ -- អាទិត្យកន្លងទៅ គឺនៅថ្ងៃទី៣១ ខែសីហា។ <អ្នកជំនាញនឹងមកនៅថ្ងៃទី១៣ កញ្ញា។> បាទ អ៊ីចឹង គឺថាឯកសារ<ដ៏ច្រើនដល់ទៅ>២២០០ឯកសារ ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿងតុលាការនោះ <-- ជាការពិតហើយ ពួកគេបានស្នើសុំឱ្យផ្ដល់ឯកសារទាំងនោះ យ៉ាងយូរបំផុត> គឺថា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

៧ថ្ងៃមុនកោះអញ្ជើញអ្នកជំនាញមកហ្នឹង <ហើយការពិតទៅគឺថ្ងៃស្អែកនេះហើយ។ ដូច្នេះ ពួកគេបានស្នើសុំរយៈពេល៥ថ្ងៃដើម្បីឲ្យ>បំពេញ<សំណើនេះ>។ គឺថាសំណើនេះគឺយឺតពេលពេក។ អ៊ីចឹងយើងច្បាស់ហើយ៥ឆ្នាំកន្លងមក គឺសហព្រះរាជអាជ្ញា បានដាក់របាយការណ៍នេះនៅក្នុងបញ្ជីដែលត្រូវដាក់បញ្ចូលទៅក្នុងភស្តុតាង។ អ៊ីចឹង គឺថាចាប់ពីឆ្នាំ២០១៤មក យើងច្បាស់ថា សហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខ បានដាក់ស្នើថា សូមឲ្យអ្នកជំនាញនេះមកធ្វើសក្ខីកម្មចំពោះអង្គជំនុំជម្រះ។ អ៊ីចឹង<នៅ>ថ្ងៃទី០៣ មិថុនា នៃឆ្នាំនេះ<> គឺថាមន្ត្រីជាន់ខ្ពស់តុលាការ បានបញ្ជូនអ៊ីម៉ែល<បញ្ជាក់ពី>សាក្សីនិងអ្នកជំនាញដែលនឹងត្រូវកោះអញ្ជើញមកធ្វើសក្ខីកម្មក្នុងវគ្គនេះ<>។ <>គឺ៣ខែ<កន្លង>ទៅហើយ។ <ហើយ ម្នាក់ក្នុងចំណោមបុគ្គលទាំងអស់នោះ គឺមាន>អ្នកជំនាញម្នាក់នេះផងដែរ។

[០៩:១២:៥៥]

នៅថ្ងៃទី២៣ ខែសីហា គឺអង្គជំនុំជម្រះបានចេញសេចក្ដីសម្រេចមួយ គឺថាបុគ្គលនេះ គឺថាគឺយើងនឹងចាត់ទុកគាត់ថាជាអ្នកជំនាញ គឺថាដោយទទួលបានការជូនដំណឹងនេះ <>សំណើសុំដាក់ឯក-សារ២.២០០នេះ <នៅមិនទាន់បង្ហាញខ្លួនទេ នៅ១៣ថ្ងៃមុនពេលសាក្សីអ្នកជំនាញមកផ្ដល់សក្ខីកម្ម ហើយទី២ បានស្នើសុំថា ឯកសារនេះត្រូវផ្ដល់ឲ្យមិនឲ្យហួសរយៈពេល>៧ថ្ងៃមុន<>។ ឥឡូវនេះគឺបញ្ហានេះយើងនៅសល់តែ៥ថ្ងៃដើម្បីដោះស្រាយ។ ដូច្នេះ គឺវាយឺតពេលពេក។ អ៊ីចឹងអ្វីដែលខ្ញុំសូមជម្រាបតុលាការហ្នឹង សំណើនេះគឺយឺតពេលពេក មិនបានបំពេញតាមតម្រូវការពេលវេលា។ <យើងមានហេតុផលពីរ។ ទី១ យើងត្រូវនិយាយជាមួយ>មនុស្ស២.២០០នាក់<ដែល>ផ្ដល់សម្ភាសន៍នោះ<> ថាតើ<ពួកគេ>ពេញចិត្ត <ឬមិនពេញចិត្តទេក្នុងការផ្ដល់ព័ត៌មានទាំងនោះមកឲ្យអង្គជំនុំជម្រះសាលាដំបូង ហើយជាពិសេសនោះ ត្រូវចាំទុកថា> ការសម្ភាស<ទាំងនោះគឺ>ទាក់ទងទៅនឹងការបំពារបំពានខាងផ្លូវភេទ <ដែល>ជាបញ្ហា<រសើប និងបញ្ហាផ្ទាល់ខ្លួនរបស់>អ្នកផ្ដល់សម្ភាស<ទាំងអស់នោះ>។ <ដូច្នេះអ្នកជំនាញត្រូវដោះស្រាយបញ្ហា>រក្សាការសម្ងាត់ផងដែរ។ អ៊ីចឹងគឺថាយើងនឹងត្រូវធ្វើការៗវាយតម្លៃ ថាតើវត្ថុ សម្ភារៈ ឬក៏ឯកសារហ្នឹងអាចនឹងផ្ដល់ នឹងប្រើបានឬអត់ ទាក់ទងទៅនឹងសាក្សីម្នាក់ៗដែលគេផ្ដល់ព័ត៌មាននៅក្នុងឆ្នាំ<២០០០ និងឆ្នាំ>២០០៦មកនោះ។ ហើយបើយើងអាចពិនិត្យមើលបានចំពោះការរក្សាការសម្ងាត់នេះ អាចនឹងដាក់ជូនមកអង្គជំនុំជម្រះបាននោះ គឺទំនងថាយើងត្រូវកោសលុបឯកសារចំណុចជាច្រើននៅក្នុងឯកសារ។ អ៊ីចឹងនៅក្នុងបទសម្ភាសន៍២.២០០នោះ ក្នុងការៗដែលយើងកោសលុបចំណុចជាក់លាក់ចំពោះសាក្សីមួយៗនោះ គឺថាអ្នកណាដែលនិយាយពាក់

ព័ន្ធនឹងអ្នកជំនាញនោះ អាចនឹងប្រើពេលវេលាច្រើនណាស់។

[០៩:១៥:២៣]

បន្ទាប់មក គឺបញ្ហាទី៣ គឺថាដោយសារព័ត៌មានទាំងអស់នោះជាភាសាខ្មែរដើម្បីឲ្យភាគីអាច ពិនិត្យមើលឯកសារទាំងអស់នេះដើម្បីកំណត់ថាតើមានភាពពាក់ព័ន្ធ ឬក៏មិនពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់ អ្នកជំនាញនោះ អ៊ីចឹងវានឹងត្រូវប្រើពេលផ្សេងទៀតសម្រាប់ឲ្យភាគីអាចនឹងសួរដេញដោលអ្នកជំនាញ បែបនេះដោយរាប់ទាំងពេលវេលានៃការបកប្រែឯកសារទាំងនោះផង។ ជាទូទៅយើងជំទាស់សំណើនេះ គឺថាដោយសារភាគីបានដាក់យឺតពេលវេលាហ្នឹងយឺតពេក ហើយនេះជាចំណុចទី២ ពួកគាត់ចង់ឲ្យ តុលាការទទួលយកគឺថាក្នុងរយៈពេល៥ថ្ងៃ គិតត្រឹមថ្ងៃស្អែកនេះ អ៊ីចឹងគឺថាមិនអាចធ្វើទៅបានទេ។ អ៊ីចឹងគឺថាសំណើនេះគឺហាក់ដូចជាមិនអាចទៅរួចទេ។ អ៊ីចឹងគឺចំណុចទី៣មួយទៀត គឺបញ្ហាសារធាតុ។ មេធាវីបានបញ្ជាក់ថាគឺប្រភពពាក់ព័ន្ធ ហើយនិងរបាយការណ៍អ្នកជំនាញដែលគេបានផ្តល់ ឬក៏ធ្វើឲ្យភាគី អាចទទួលបាននោះ អាចនឹងមានភាពពាក់ព័ន្ធដូចដែលគេផ្តល់ទៅតុលាការក្នុងគោលបំណងដែលនិយាយ ពីការទទួលយកបាននៅក្នុងតុលាការ។ ប៉ុន្តែមាន<សៀវភៅ និងឯកសារ>ជាច្រើនទៀតដែល<ត្រូវបាន បង្កើតឡើងបញ្ច្រាសគ្នា>មុនពេលដំណើរការនីតិវិធី <ហើយមិនចាំបាច់សម្រាប់គោលបំណងនៃ ដំណើរការនីតិវិធីច្បាប់>។ <មិនមានការតម្រូវផ្នែកច្បាប់>ថា <ត្រូវតែផ្តល់រាល់>ប្រភពសំខាន់ៗដែល <ត្រូវបានប្រើដើម្បី>បង្កើតបានជាទស្សនៈ <ឬ>ជាមូលដ្ឋាននៃការសរសេរសៀវភៅ ឬក៏អត្ថបទនានា នោះ<ទេ។> អ៊ីចឹងគឺថាមូលហេតុហ្នឹងគឺវាអាចនឹងបង្កើត -- នាំឲ្យនីតិវិធីនោះមានភាពគាំង។ <គ្រាន់ តែគិតមើលទេ បើសិនជា>ថាសៀវភៅនីមួយៗ ហើយនិងអត្ថបទមួយៗដែលដាក់នៅក្នុងសំណុំរឿង ហើយ ត្រូវតែកំណត់ប្រភពទាំងអស់ឲ្យបាននោះ។ <វាស្ទើរតែមិនអាចធ្វើបានទេ ហើយវាស្មុគស្មាញ ខ្លាំងណាស់សម្រាប់អ្នកជំនាញក្នុងការធ្វើដូច្នោះ។>

[០៩:១៧:៤១]

អ៊ីចឹងគឺថា អ៊ីចឹងហើយគឺជាបញ្ហាមួយ។ អ៊ីចឹងនិយាយអំពីការថ្លឹងថ្លែងទម្ងន់នៃភស្តុតាង អ៊ីចឹងគឺ ថាចំពោះអត្ថបទសៀវភៅរបស់របស់អ្នកជំនាញកាលពីមុននោះ គឺថាយើងអាចធ្វើតេស្ត ក៏ដេញដោល តាមរយៈការសួរចំពោះមុខអង្គជំនុំជម្រះដើម្បីឲ្យគាត់បញ្ជាក់ពីវិធីសាស្ត្រ ហើយនិងប្រភពដែលជាមូល- ដ្ឋាននៃមតិរបស់គាត់។ <បើ>អង្គជំនុំជម្រះពិនិត្យឃើញ<>ថា ពេលខ្លះពេលវេលានឹងខ្លី <អ្វីដែលយើង គិតគឺតម្រូវឲ្យមានទស្សនៈមួយដែលគួរឲ្យជឿបាន> អ៊ីចឹងគឺថា<អង្គជំនុំជម្រះ>អាចនឹងថ្លឹងថ្លែងនៅ

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ក្នុងដំណើរការនៃការសួរដេញដោល។ អង្គជំនុំជម្រះតែងតែបញ្ជាក់ថា ទស្សនៈរបស់អ្នកជំនាញ<គឺផ្តល់នូវ>ការវាយតម្លៃប្រហាក់ប្រហែលនៅក្នុងភស្តុតាងផ្សេងទៀត <នៅពេលសម្រេចពី>ភាពអាចជឿជាក់បាន។ ដូច្នេះ ប្រហែលថាជាការលើកលែងមួយទៅនឹងការជំទាស់នេះ គឺថាអាចជាសេចក្តីដកស្រង់ជាក់លាក់មកពីប្រភពណាមួយជាក់លាក់ដែលយោងទៅរក ទៅសៀវភៅរបស់អ្នកជំនាញនោះ គឺថាតាមពិតគឺវាជាសៀវភៅ៤០ ឬ៥០ទំព័រនោះ។ សម្រង់ជាក់លាក់នេះគឺពាក់ព័ន្ធទៅនឹងជំពូកទី៣ អំពីអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយនិងអំពើហិង្សាផ្លូវភេទ ឬក៏ការរៀបការដោយបង្ខំនោះ។ ក្នុងន័យនេះ សហព្រះរាជអាជ្ញាមិនជំទាស់ទេ ជាពិសេសចំពោះបទសម្ភាសន៍ដែលដកស្រង់ដែលបានជាសម្រង់នៅក្នុងសៀវភៅនេះ មិនបានបញ្ជាក់ពីឈ្មោះនៃសាក្សី មិនបានបញ្ជាក់ពីទីតាំងរបស់សាក្សី ហ្នឹងទេ។ យើងមិនជំទាស់ទៅនឹង<ការបញ្ចេញឯការទាំងនោះទេ ហើយកម្មវត្ថុដែល>អ្នកជំនាញបាននិយាយ<អ្នក>ទាំងឡាយដែលផ្តល់ព័ត៌មានឲ្យគាត់នោះ។ <ហើយនៅក្នុងជំពូកទី៣ហ្នឹង>គឺប្រហែលជាមានមនុស្សតែ១៤នាក់តែប៉ុណ្ណឹងទេ។ យើងមិនមានការជំទាស់ទៅនឹងករណីនេះទេ។ ប៉ុន្តែត្រូវពិចារណាផងដែរអំពីការរក្សាការសម្ងាត់។ អ៊ីចឹងវាមិនអាចនឹង អាចនឹងព័ត៌មានហ្នឹងអាចទម្លាយមុនពេលដែលសាក្សីនឹងមកផ្តល់សក្ខីកម្មទេ ពីព្រោះថាអ្នកទាំងអស់នោះគឺជាប្រភពដោយផ្ទាល់ ដែលអ្នកជំនាញបានជួបទាក់ទងទៅនឹងបញ្ហាការរៀបការដោយបង្ខំជាដើម។

<យើងមិនជំទាស់ ព្រោះនោះគឺជាប្រភពព័ត៌មានផ្ទាល់ ដែលអ្នកជំនាញបានប្រើប្រាស់ពាក់ព័ន្ធទៅនឹងបញ្ហារៀបការដោយបង្ខំ និងអំពើហិង្សាផ្លូវភេទនៅក្នុងការរៀបការដោយបង្ខំ។>

[០៩:២០:២៤]

<ហើយយើងក៏មិនជំទាស់ទៅនឹង>សម្រង់នៃបទសម្ភាសន៍ដែលសម្រង់នេះត្រូវបានយកមកប្រើយកទៅដាក់នៅក្នុងរបាយការណ៍ផ្សេងទៀត អំពីកញ្ញា ច័យ ក្រូណិន នោះ គឺឯកសារ E3/3416 ដែលមានរបាយការណ៍ខ្លីមួយអំពីអំពើហិង្សាផ្លូវភេទនៅក្នុងកម្ពុជាប្រជាធិបតេយ្យ ហើយក៏មានផ្នែកខ្លីមួយ គឺ<ការរៀបការដោយបង្ខំ និង>អំពើហិង្សា<ផ្លូវភេទ>ក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងសម័យនោះ។ ហើយផ្នែកនេះគាត់និយាយអំពីសេចក្តីដកស្រង់យកពីចម្លើយរបស់មនុស្សមួយចំនួន ហើយយើងពិនិត្យមើលឃើញថា អាចប្រហែលជាចម្លើយរបស់សាក្សី ប្រហែលជា១៤នាក់នៅក្នុងការសិក្សានោះ។ ហើយនិយាយដោយសង្ខេប គឺថាយើងខ្ញុំមិនមានការជំទាស់ទៅនឹងផ្នែកនេះទេ នៅក្នុងឯកសារទាំងពីរនេះ។ ប៉ុន្តែក៏គប្បីចងចាំផងដែរថា ឯកសារដែលទាក់ទងទៅនឹងអំពើហិង្សាផ្លូវភេទនោះ នៅក្នុងកម្ពុជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ប្រជាធិបតេយ្យ គឺមានលក្ខណៈទូលំទូលាយ។

អាពាហ៍ពិពាហ៍ដោយបង្ខំ ហើយអំពើហិង្សានៅក្នុងការរៀបការដោយបង្ខំ គឺថាវាអាចមានដប់ ឬដប់ប្រាំភាគរយនៃរបាយការណ៍នោះតែប៉ុណ្ណោះ។ ដូច្នេះ ដើម្បីផ្ដល់ឯកសារទាំងស្រុង ហើយនិងបទសម្ភាសន៍ទាំងអស់ ដែលរួមមានឯកសារ២.២០០ឯណោះ គឺថាអាចនឹងបង្ហាញអំពីបញ្ហាផ្សេងទៀត នៅក្នុងកម្ពុជាប្រជាធិបតេយ្យ នៅក្នុងលក្ខណៈទូទៅជាង។ គឺវាមិនសូវមានភាពពាក់ព័ន្ធទៅនឹងអាពាហ៍-ពិពាហ៍ដោយបង្ខំ និងអំពើហិង្សាផ្លូវភេទដែលពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់អ្នកជំនាញនោះទេ។ ដូច្នេះ នេះជាមតិយោបល់ដែលខ្ញុំជម្រាបជូនអង្គជំនុំជម្រះនៅពេលនេះ ហើយខ្ញុំនឹងឆ្លើយ ប្រសិនជាមានសំណួរអ្វីនោះ បាទ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ សូមអញ្ជើញមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើការឆ្លើយតបនឹងសំណើសុំទទួលយកឯកសារទាំងនេះ។ សូមអញ្ជើញ!

[០៩:២២:៤១]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ជម្រាបសួរភាគីទាំងអស់ យើងខ្ញុំគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះទៅលើសំណើទាំងអស់នេះ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ យោងទៅតាមមតិកត់សម្គាល់របស់ការិយាល័យសហព្រះរាជអាជ្ញាកាលពីព្រឹកមិញនេះ យើងចង់ឲ្យការស្ដាប់ចម្លើយ អ្នកជំនាញនៅតែរក្សាទុកដដែល គឺមិនត្រូវលើកពេលទេ យោងទៅតាមសំណើផ្សេងៗរបស់សហមេធាវីការពារក្ដី ក៏ដូចជាការលើកឡើងរបស់សហព្រះរាជអាជ្ញាអម្បាញ់មិញនេះ។ ដូច្នេះ សំណើទាំងអស់នេះធ្វើឡើងតាមវិធាន៨៧(៤) ហើយនិងសំណើដែលយោងទៅតាមវិធាន៩៣នោះ យើងខ្ញុំគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី។

សូមអញ្ជើញលោកស្រីមេធាវីការពារលោក នួន ជា ឡើងធ្វើការឆ្លើយតប។

[០៩:២៣:៥២]

**លោក កញ្ញា ដូរីន ជិន៖**

ជម្រាបសួរលោកប្រធាន លោកស្រីចៅក្រម ហើយនិងភាគីទាំងអស់។ ទី១ ខ្ញុំនឹងនិយាយឆ្លើយតបទៅនឹងមតិរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងសំណើតាមវិធាន៨៧ជាដើម។ <ហើយបន្ទាប់មកនឹងឆ្លើយតបទៅនឹងមតិរបស់សហព្រះរាជអាជ្ញា ដែលបានលើកឡើងពាក់ព័ន្ធទៅនឹងវិធាន៨៧ និងវិធាន៩៣។ ដូចដែល>សហព្រះរាជអាជ្ញា<លើកឡើងពីការព្រួយបារម្ភ>នោះ <យើងគិតថា ឯកសារដែលបានស្នើសុំនោះ> គឺថាមានភាពពាក់ព័ន្ធ។ គឺថាវាទាក់ទងទៅនឹងការចោទប្រកាន់ <ដែលអង្គជំនុំជម្រះទើបតែបានកំណត់ថ្មីៗនេះ នៅក្នុងសេចក្ដីសម្រេចរបស់ខ្លួន>នៅក្នុងរឿងក្ដី គឺថាឯកសារ <E306/7/3> គឺថានិយាយអំពីអាពាហ៍ពិពាហ៍ដោយបង្ខំ ហើយនិងអំពើហិង្សាផ្លូវភេទ។ <ដូច្នេះនៅទីបញ្ចប់ យើងគួរតែនិយាយថា>មានតែ<>ឯកសារដែលពាក់ព័ន្ធ<ទៅនឹងការចោទប្រកាន់ទេ> ដែលត្រូវទទួលយកនោះ។ <តាមអ្វីដែលយើងបានដឹង ពាក់ព័ន្ធនឹងឯកសារ>ដំបូង <ដែលនិយាយអំពីអំពើហិង្សាយេនឌ័រ ប្រឆាំងនឹងជនជាតិភាគតិចក្នុងអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ> គឺថាយើងសូមឲ្យទទួលស្គាល់ទំព័រ៤១ ដល់៥០ ជំពូកទី២ ទី៣។ <ចំពោះឯកសារទី២ គឺ "មាតុភាពក្នុងពេលសង្គ្រាម" យើងគិតថា ជំពូកដែលពាក់ព័ន្ធគឺ> ជំពូកទី១ អំពីការរៀបការ <ជំពូកទី២ "រៀបការជាមួយកម្ពុជាប្រជាធិបតេយ្យ"> ជំពូកទី៥ អាពាហ៍ពិពាហ៍ដោយបង្ខំ, ជំពូកទី៨ <នៅ>ទំព័រ៧៣<ពាក់ព័ន្ធនឹងការរំលូតកូន នៅក្នុងបរិបទនៃការរៀបការដោយបង្ខំ> ហើយនិងជំពូក១២<ដែលនិយាយអំពីការរៀបការនៅក្រោយរបបកម្ពុជាប្រជាធិបតេយ្យ>។ ហើយអ៊ីចឹង យើងស្នើឲ្យមានការទទួលយកស្ទើរតែទាំងស្រុង។ អ៊ីចឹង ហើយសហព្រះរាជអាជ្ញា សូមឲ្យយកតែចំណុចមួយតូចតែប៉ុណ្ណោះ។ ហើយអ៊ីចឹងគឺថាអាចនឹងតម្រូវឲ្យមានពេលដើម្បីរៀបចំដើម្បីសួរសំណួរ។ អ៊ីចឹងតើយើងត្រូវមានពេលបន្ថែមដើម្បីរៀបចំ ឬក៏អាចនឹងទុកបញ្ហានេះសិន អាចនឹងកោះអញ្ជើញអ្នកជំនាញនៅពេលក្រោយ ឬយ៉ាងដូចម្ដេច ឬក៏អាចបំបែកផ្នែកនៃសក្ខីកម្មរបស់គាត់អាច ១ថ្ងៃនៅអាទិត្យណាមួយ ហើយ១ថ្ងៃទៀតនៅអាទិត្យមួយផ្សេងទៀត។ អ៊ីចឹងនេះ ឯងជាចម្លើយរបស់យើងខ្ញុំតបទៅនឹង វិធាន៨៧(៤)នោះ។

<ទាក់ទងទៅនឹងវិធាន៨៧ផ្ទាល់របស់យើង ហើយជាពិសេសគឺការស្នើសុំតាមវិធាន៩៣ គឺជា> ចំណុចចាប់ផ្ដើមនៃការពិភាក្សា យើងគិតថា វាត្រូវតែពិនិត្យមើល គឺថាសំណើឯកសារដែលយើងស្នើសុំ គឺថាផ្អែកទៅលើជំនាញរបស់អ្នកជំនាញនេះឯង។ គឺថា<ខ្ញុំយោងដោយសង្ខេបទៅលើ>កថាខណ្ឌ២៣ <នៃ>សំណើរបស់យើង <ដែលយើងពិភាក្សាពីបញ្ហា>ហ្នឹង។ <ហើយដូចដែលយើងបាននិយាយរួចហើយ> គឺថាយើងមិនមានលទ្ធភាពមើលប្រភព ឬក៏<ព័ត៌មានសំខាន់នៃរបាយការណ៍ទាំងពីរដែលជា

ខ្លឹមនៃ>ការសិក្សាជំនាញរបស់គាត់នោះទេ។ អ៊ីចឹងតាមយុត្តិសាស្ត្រហ្នឹង គឺថា អ្នកជំនាញត្រូវតែបង្ហាញអំពីនីតិវិធី វិធីសាស្ត្រ ដែលគាត់បានប្រើនោះ។

[០៩:២៦:៥៦]

<អ្វីដែលយើងបានជួបនៅពេលនេះ ដូចដែលយើងបាននិយាយរួចមកហើយ>នៅក្នុងសំណើនេះ គឺថា យើងឃើញរបាយការណ៍ពីរអំពីព័ត៌មានដែលដាក់បន្ទុក <ដែលជាសម្រង់ចេញពីបុគ្គលអនាមិក ដោយ>មិនមានលទ្ធភាពមើលព័ត៌មាន<សំខាន់ និងអត្តសញ្ញាណរបស់បុគ្គលទាំងនោះ ឬក៏ប្រវត្តិនៃ> ទីតាំងនៃអង្គហេតុនៅពេលនោះ <និងដោយមិនដឹងពីបរិបទ ថាតើក្នុងអង្គហេតុអ្វីដែលត្រូវបានគេចោទប្រកាន់នៅក្នុងរបាយការណ៍នោះ។ ជា>លទ្ធផលចុងក្រោយនោះគឺថា នួន ជា គឺថាមិនអាចនឹងប្រើសិទ្ធិរបស់គាត់ដើម្បីសួរដេញដោល និងជំទាស់ភស្តុតាងនោះទេ ពីព្រោះថាខ្លួនមិនអាចមានលទ្ធភាពមើលធាតុផ្សំសំខាន់ៗទាំងនោះ។ <នៅក្នុងការអនុវត្ត បើគ្មានប្រភពដែលយើងស្នើសុំទេ យើងចាំបាច់>ពឹងផ្អែកទៅលើសក្ខីកម្មរបស់បុគ្គល <ដែលមិនមានវត្តមាន>នៅទីតាំងនោះទេពេលនោះ <ហើយជាអ្នកដែល>ផ្អែកទៅលើ<សក្ខីកម្មរបស់>អ្នកផ្សេងទៀត<>។ ហើយឆ្លើយតបទៅនឹងបញ្ហាមួយដែលថា យើងដាក់យឺតពេលនោះ គឺថា តាមពិតយើងគោរពតាមពេលវេលាដែលអង្គជំនុំជម្រះបានសម្រេច។ ផ្អែកទៅលើការអនុវត្តនោះគឺថា យើងមិនដឹងថា<តើវាមិនអាច>ទៅរួច<យ៉ាងណានោះទេ។ ខ្ញុំគិតថា ចំណុចនេះទុកឲ្យអ្នកជំនាញជាអ្នកប្រាប់យើង។ ហើយនៅក្នុងកថាខណ្ឌ២៥ នៃសារណារបស់យើង ដែលត្រូវបានកោសលុប គឺមានបន្ថែម>នូវចំណុចជាក់លាក់<ជាច្រើន>។ អ៊ីចឹងគឺថា យើងមើលថាអ្នកជំនាញត្រូវផ្តល់ព័ត៌មានឲ្យបានឆាប់រហ័ស តាមដែលអាចធ្វើទៅបាននោះ។ ដោយសារថាព័ត៌មាននេះ <ត្រូវបាន>ចងក្រង<ដោយសង្ខេបសម្រាប់>អ្នកជំនាញ <ដើម្បីបន្ថយសម្រាប់ការបោះពុម្ពនោះ យើងសង្ស័យថា ប្រហែលជាយើងអាច>ពិនិត្យ<មើល>បាន។ <យើងក៏កត់សម្គាល់ដែរថា តាមការយល់របស់យើង ព័ត៌មានភាគច្រើន គឺមានជាភាសាអង់គ្លេសរួចហើយ។>

[០៩:២៨:៣២]

ហើយចំពោះឯកសារថា ១.៥០០នោះ យើងយល់ថា <វាមិនមែនជា>បទសម្ភាសន៍<ទេ ប៉ុន្តែគឺជាការស្ទង់មតិ ដូច្នេះព័ត៌មាននោះគឺងាយនឹងបំបែកណាស់។ ពាក់ព័ន្ធនឹងថា តើហេតុអ្វីបានជាយើងស្នើសុំព័ត៌មាននេះ គឺខ្ញុំបានផ្តល់ទស្សនទូទៅរួចហើយ ប៉ុន្តែសូមបង្ហាញចំណុចជាក់លាក់មួយចំនួនទៀត ដូចដែលមាននៅក្នុង>កថាខណ្ឌ២០ <និង>២១ នៃសំណើរបស់យើងនេះ។ យើងបានបញ្ជាក់ថា ការ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សិក្សាពីរដែល<ត្រូវបានទទួលយកជាភស្តុតាងនោះ គឺ>ពឹងផ្អែកទៅលើ<ប្រភពពីរប្រភេទ។ ទី១ គឺ> បទសម្ភាសន៍<ជាមួយ>មនុស្ស១០០នាក់ នៅក្នុងចំណោមមនុស្ស<១.៥០០>នាក់ ដែលគេបាន<ស្ទង់មតិជាបឋមរួចហើយ ហើយបន្ទាប់មកវាហាក់ដូចជាថា មនុស្សទាំង១០០នាក់នេះ>បានផ្ដល់នូវប្រវត្តិរឿងផ្ទាល់ខ្លួន<អំពីបទពិសោធន៍ទាក់ទងទៅនឹងអំពើហិង្សាយេនឌ័រ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ>។ ហើយចំណុចមួយទៀតនៅក្នុងរបាយការណ៍ដែល<សរសេរដោយ ថ័យ គ្រូវិន ក៏ឃើញដែរថា> គឺផ្អែកទៅលើចម្លើយរបស់មនុស្ស ១០០នាក់ ជាអ្នករស់រានពីរបបខ្មែរក្រហម <ដែលគេបានកំណត់អត្តសញ្ញាណ តាមរយៈការស្ទង់មតិដូចគ្នានោះ>។ អ៊ីចឹង យើងមិនប្រាកដថា១០០ ឬក៏តិចជាងប៉ុណ្ណឹងនោះទេ។ ប៉ុន្តែ<យើងពិតជាមិនមាន>ព័ត៌មានដែលសំខាន់<នោះទេ។ ប៉ុន្តែសម្រាប់យើង ការដឹកនាំសម្ភាសន៍បឋមនោះ ហាក់ដូចជាមានសារៈសំខាន់ មិនត្រឹមតែក្នុងទទួលបាន>នូវព័ត៌មានលម្អិត<នោះទេ គឺថែមទាំងជួយឲ្យយល់កាន់តែច្បាស់>អំពី<>វិធីសាស្ត្រនៃ<ការ>ប្រមូលព័ត៌មាន ថាតើគេជ្រើសរើសអ្នកទាំងហ្នឹងដោយរបៀបណា <ថាតើពួកគេត្រូវបានជ្រើសរើសដោយត្រឹមត្រូវទេ> ដែលអាចនឹងជាគំរូទូលំទូលាយផងដែរ។ <ដូច្នេះ ចំណុចនេះគឺនិយាយអំពីវិធីសាស្ត្រ។>

ចំណុចទាំងពីរ យើងកត់សម្គាល់ថា គឺមានការពឹងផ្អែកទៅលើបទសម្ភាសន៍ ៦០០នាក់ ប្រហែលជា៧និស្សិត២០០នាក់ដែលបានធ្វើការងារនេះ <ពាក់ព័ន្ធនឹងអំពើហិង្សាយេនឌ័រនៅក្នុងកម្ពុជាប្រជាធិបតេយ្យ។> ហើយបទសម្ភាសន៍៦០០នេះគឺថា ត្រូវបានដាក់បញ្ចូលមកក្នុងឯកសារជារបាយការណ៍គឺជាពិសេសគឺ E3/2959។ <ជាថ្មីម្ដងទៀត បញ្ហាវិធីសាស្ត្រនៃការស្រាវជ្រាវទៀតហើយ។> ថាតើ យើងដឹងថាតើគេជ្រើសរើសដោយវិធីណា។ ចំពោះយើងឃើញថា និស្សិត២០០នាក់ហ្នឹងគឺថាច្រើនណាស់<ក្នុងការដឹកនាំកិច្ចសម្ភាសន៍ទាំងអស់នោះ ដូច្នេះវាគួរឲ្យចង់ដឹង> ថាតើគេប្រមូលទិន្នន័យដូចម៉េចដាក់បញ្ចូលយ៉ាងដូចម្ដេច។ ដូច្នេះហើយភស្តុតាងនេះសំខាន់<ណាស់។ ឥឡូវពាក់ព័ន្ធនឹង>បញ្ហា<>ថា<តើ>សំណើនេះក្លាយជាមោឃៈដោយសារយឺតពេល <ឬយ៉ាងណានោះ> យើង<ដឹងថារយៈពេលមួយសប្ដាហ៍អាចនឹងផុតនៅថ្ងៃស្អែក។ ហើយដូចដែលយើងបាន>ឆ្លើយ<តបទៅនឹងសារណារបស់សហព្រះរាជអាជ្ញារួចហើយ គឺយើងស្នើសុំថាឲ្យបំបែក>សក្ខីកម្មរបស់អ្នកជំនាញជា<ពីរវគ្គ។ ដូច្នេះប្រហែលជាយើងធ្វើ>មួយថ្ងៃ<នៅសប្ដាហ៍ក្រោយ ហើយបន្ទាប់មកយើងមានពេលកន្លះ>ថ្ងៃទៀត<នៅពេលណា ដែលយើងអាចបន្តការពិភាក្សាបាន។ ដូច្នេះ> យើងអាចធ្វើបាន<ដំណើរការនៅលើមូលដ្ឋានបច្ចុប្បន្ន ដោយ>ទទួល <និង>ពិនិត្យ<មើលឯកសារ> ហើយ<>បន្ទាប់មក<បន្តការសួរ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បន្ថែមទៀតនៅពេលក្រោយ>។ អ៊ីចឹងហើយ ដូច្នេះគឺថាមិនមានអ្វីដែលរំខានដល់ដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះទេ។ សូមអរគុណ។

[០៩:៣១:២៥]

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវីការពារលោក នួន ជា។

សូមអញ្ជើញលោកស្រីមេធាវីការពារលោក ខៀវ សំផន!

**កញ្ញា អង់តា ហ្គីសសេះ**

សូមអរគុណលោកប្រធាន។ សូមគោរពលោកប្រធាន លោក លោកស្រី ចៅក្រម និងភាគីទាំងអស់។ ការកត់សម្គាល់ទី១របស់ខ្ញុំ គឺឆ្លើយតបទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ខ្ញុំគាំទ្រយ៉ាងពេញទំហឹងទៅនឹងសហភាតារបស់ខ្ញុំ<> ទាក់ទងនឹងផ្នែកពាក់ព័ន្ធនៃឯកសារដែលសហព្រះរាជអាជ្ញាសូមឲ្យអង្គជំនុំជម្រះទទួលយក។ ក៏ប៉ុន្តែទោះយ៉ាងណាក៏ដោយ ខ្ញុំមានលក្ខណៈខុសគ្នាបន្តិច។ ច្បាស់ណាស់គឺយើងនៅក្នុងការជំនុំជម្រះដែលមានបទចោទជាក់លាក់។ ចំពោះយើង គឺយើងមិនមានហេតុផលអីដែលត្រូវសួរអ្នកជំនាញទៅលើបញ្ហាដែលមិនពាក់ព័ន្ធនឹងបទចោទទេ ដូច្នេះយើងមិនសុំពេលវេលាបន្ថែមដើម្បីនិយាយអំពីបទចោទផ្សេងទេ យើងនិយាយតែអំពីផ្នែកពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវសុំឲ្យទទួលយកជាភស្តុតាងនោះ។

នៅក្នុងសំណើរបស់យើងៗបានស្នើសុំដាក់បញ្ចូលឯកសារទាំងស្រុង ពីព្រោះថាវាពិបាកក្នុងការបែងចែកឲ្យដាច់ណាស់ ក៏ប៉ុន្តែយើងបានជ្រើសរើសផ្នែកពាក់ព័ន្ធដែលយើងចង់សួរទៅអ្នកជំនាញ។ អ៊ីចឹងខ្ញុំគិតថា ខ្ញុំចង់ធ្វើបែបហ្នឹងហើយ។

[០៩:៣២:៥៩]

ហើយនៅពេលដែលយើងទទួលបានបញ្ជីរបស់សហព្រះរាជអាជ្ញា ហើយនិង ERN ដែលគាត់ចង់ប្រើប្រាស់ក្នុងក្របខ័ណ្ឌនៃការសួរសំណួរអ្នកជំនាញនោះ យើងកត់សម្គាល់ឃើញថាឯកសារពីរនោះគឺត្រូវបានដាក់ទាំងស្រុងតែម្តង ERN ហ្នឹងគឺថាដាក់មក ឯកសារពេញទាំងមូលតែម្តង អត់មានដកស្រង់ជាផ្នែកទេ គឺអ៊ីចឹងកន្លែងហ្នឹងជាបញ្ហាហើយ។ <យើងនឹងមិននិយាយអំពី និងមិនប្រើពេលវេលាដែលបានផ្តល់ឲ្យសម្រាប់អ្នកជំនាញ ដើម្បីពិភាក្សាអំពីបញ្ហាដែលមិនមែនជាផ្នែកនៃការចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទនោះទេ>។ នេះជាការកត់សម្គាល់ដំបូងរបស់ខ្ញុំ។ <ទាក់ទងទៅនឹង>ផ្នែកពាក់ព័ន្ធ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ផ្សេងៗនោះយើងគាំទ្រទាំងស្រុងទៅលើមេធាវី នួន ជា។ ចំពោះសំណើរបស់មេធាវីការពារក្ដីលោក នួន ជា ផ្អែកទៅលើភស្តុតាងដែលគាំទ្រទៅដល់របាយការណ៍របស់អ្នកជំនាញនោះ ជាពិសេសគឺកំណត់ហេតុសម្ភាសន៍នោះ ខ្ញុំយល់ថាអ្នកជំនាញគាត់មានជំនាញខាងវិទ្យាសាស្ត្រសង្គម ដូច្នេះវាមានវិធានការសម្ងាត់ដែលត្រូវគោរព ហើយដែលយើង មានចំណុចខ្លះដែលយើងមិនអាចចូលទៅមើលបាន។ អ៊ីចឹងហើយយើងមិនសុំឱ្យអ្នកជំនាញរំលោភទៅលើគោលការណ៍រក្សាការសម្ងាត់របស់គាត់ទេ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែសហព្រះរាជអាជ្ញាបានលើកឡើងនូវបញ្ហាពេលវេលា និងបញ្ហាផលប្រយោជន៍នៃការដាក់បង្ហាញឯកសារទាំងអស់នេះ ខ្ញុំ<សូមរំឭកអង្គជំនុំជម្រះ>ថា បើដូចសហព្រះរាជអាជ្ញាលើកឡើងនោះ គឺបញ្ហាហ្នឹងយើងចង់ដឹងថា តើយើងត្រូវសួរនាំយ៉ាងម៉េចទាក់ទងទៅនឹងអ្នកជំនាញនេះ។ តើយើងយកកំណត់ហេតុសម្ភាសន៍របស់គាត់ហ្នឹងយកមកសួរគាត់យ៉ាងម៉េច ពីព្រោះថាអង្គជំនុំជម្រះនឹងធ្វើការវាយតម្លៃទៅលើភស្តុតាងដែលគាត់នឹងផ្ដល់ជូន។ ដូច្នេះមុនពេលអ្នកជំនាញមកផ្ដល់សក្ខីកម្ម ឬក្រោយពេលមកផ្ដល់សក្ខីកម្មក៏ដោយ យើងត្រូវតែមានព័ត៌មានពាក់ព័ន្ធទៅនឹងការសម្ភាសរបស់គាត់ ថាតើគាត់សម្ភាសអ្នកណាខ្លះ ហើយអ្នកខ្លះដែលចូលរួមសម្ភាសជាមួយគាត់នោះ <ទាំងអស់នេះមានភាពពាក់ព័ន្ធខ្លាំងណាស់ ក្នុងការប៉ាន់ប្រមាណតម្លៃនៃភស្តុតាង ដែលបានសិក្សាដោយអ្នកជំនាញ មិនថាមុន ឬក្រោយពេលអ្នកជំនាញបង្ហាញខ្លួននោះទេ>។

[០៩:៣៥:២៧]

ដូចសហភាតារបស់ខ្ញុំបានលើកឡើងរួចមកហើយ អ្នកជំនាញគាត់មិននិយាយភាសាខ្មែរទេ ហើយគាត់បានធ្វើការលើឯកសារនិងសំយោគជាច្រើន។ អ៊ីចឹងមុននឹងនិយាយថា រឿងមិនអាចទៅរួចនោះ យើងត្រូវសួរអ្នកជំនាញសិន ថាតើគាត់មានឯកសារណាខ្លះនៅពេលមកដល់សព្វថ្ងៃនេះ ហើយពេលនុ៎ងយើងនឹងពិនិត្យមើល ថាតើយើងនឹងមានជំហានអ្វីខ្លះដើម្បីប្រើប្រាស់ឯកសារទាំងអស់នេះ។ ទោះជាយ៉ាងណាក៏ដោយ បើយើងឯកភាពទាំងអស់គ្នាថា បញ្ហានៃតម្លៃភស្តុតាង និងការវាយតម្លៃទៅលើភស្តុតាង ហើយនិងការជ្រើសរើសផ្នែកនៃបទសម្ភាសន៍ដែលពាក់ព័ន្ធនោះ ខ្ញុំគិតថាវាជាចំណុចសំខាន់ក្នុងការវិភាគទៅលើភាពជំនាញរបស់គាត់។ ទោះបីជាឯកសារផ្ដល់ជូននៅពេលណាក៏ដោយ ក៏ខ្ញុំគិតថាវាមានការសំខាន់ណាស់សម្រាប់ភាគីទាំងអស់គ្នា ជាពិសេសមេធាវីការពារក្ដី។ ទោះជាយ៉ាងណាក៏ដោយ យើងត្រូវតែសួរដេញដោលគាត់នូវវិធីសាស្ត្រស្រាវជ្រាវ ហើយនិងព័ត៌មានដែលគាត់បានច្បិចយកមកសរសេរក្នុងសៀវភៅរបស់គាត់នេះ។ យើងធ្វើយ៉ាងម៉េចឱ្យយើងអាចដេញដោលទៅលើចំណុច

ទាំងអស់នេះបាន នៅក្នុងពេលសួរសំណួរអ្នកជំនាញនោះ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកចៅក្រម ហ្វង់ម៉ាក!

[០៩:៣៦:៥៥]

**ចៅក្រម ហ្វង់ម៉ាក ឡាវ៉ែន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណើមួយសម្រាប់មេធាវីការពារក្ដី នួន ជា។ លោកស្រីបានស្នើសុំឱ្យអង្គជំនុំជម្រះទទួលយករបាយការណ៍ជំនាញ ដែលត្រូវបានផ្ដល់ជូនសហព្រះរាជអាជ្ញានៅចំពោះមុខតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន។ របាយការណ៍នេះ គឺពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងបរិបទនៃជម្លោះនៅសៀរ៉ាឡេអូន។ លោកស្រីអាចពន្យល់បានទេថា របាយការណ៍ហ្នឹងមានសារៈសំខាន់អ្វី មានភាពពាក់ព័ន្ធអ្វីទៅនឹងបរិបទនៃការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំនៅកម្ពុជានោះ? ហេតុអីបានជាលោកស្រីស្នើសុំដាក់ឯកសារនុ៎ងបញ្ចូលទៅក្នុងសំណុំរឿង?

[០៩:៣៧:៤៦]

**លោកស្រី ដូរីន ជិន៖**

សូមអរគុណលោកចៅក្រម។ ពាក់ព័ន្ធទៅនឹងរបាយការណ៍ប្រទេសសៀរ៉ាឡេអូន យើងដឹងថាតុលាការពិសេសសម្រាប់ប្រទេសសៀរ៉ាឡេអូន គឺជាតុលាការព្រហ្មទណ្ឌតែមួយគត់ដែលមានយុត្តាធិការដែលត្រូវចោទប្រកាន់ពីបទបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ <ដូច្នេះ គឺក្នុងន័យពាក់ព័ន្ធជាទូទៅ>។ របាយ-ការណ៍ទី១ <អំពីការងារ>ដែលអ្នកជំនាញបានសរសេរ ពាក់ព័ន្ធទៅនឹង<អំពើហិង្សាផ្លូវភេទនៅ>កម្ពុជាប្រជាធិបតេយ្យគឺប្រៀបធៀបស្ថានភាពក្នុងរបបកម្ពុជាប្រជាធិបតេយ្យជាមួយនឹងប្រទេសសៀរ៉ាឡេអូន <ហើយយើងចង់និយាយអំពីរបាយការណ៍នេះជាមួយអ្នកជំនាញ>។ ហើយមូលហេតុនោះ គឺថាយើងខ្ញុំគិតថាវានឹងជួយឱ្យខ្ញុំយល់អំពីជំហររបស់អ្នកជំនាញពីរបបកម្ពុជាប្រជាធិបតេយ្យ និង<កំណត់>ស្ថាន-ភាពនៅក្នុងសំណុំរឿងរបស់យើងខ្ញុំ<ជាមួយនឹង>យុត្តាធិការអន្តរជាតិ ដែលវាពាក់ព័ន្ធទៅនឹង<ការរៀបការដោយបង្ខំ ដែលអាចមានប្រយោជន៍ ជាពិសេសសម្រាប់ការដាក់សេចក្ដីសន្និដ្ឋាន>ផ្លូវច្បាប់ <ដែលយើងនឹងធ្វើនៅចុងបញ្ចប់នៃសំណុំរឿង>។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវីការពារលោក ខៀវ សំផន!

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងខ្សែបកប្រែ និងខ្សែបកប្រែបន្ត។*

[០៩:៣៨:៤៤]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមកែតម្រូវនូវចំណុចមួយ ដែលខ្ញុំបាននិយាយអម្បាញ់មិញនេះ។ ខ្ញុំគិតថា អ្នកជំនាញហ្នឹង គាត់និយាយជាភាសាខ្មែរ ក៏ប៉ុន្តែឯកសារមួយចំនួនហ្នឹង គឺ<អ្នកដែលធ្វើសេចក្តីព្រាងនោះ>មិន<និយាយ>ភាសាខ្មែរទេ <ដូច្នេះ>ឯកសារជាភាសាអង់គ្លេស<ដែលត្រូវបានប្រើ គួរតែអនុញ្ញាតឲ្យភាគីអាចពិនិត្យមើលបានផងដែរ។ នេះជាការកែតម្រូវដែលខ្ញុំចង់លើកឡើង>។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានការកត់សម្គាល់ខ្លីមួយ ក្រោយពីការលើកឡើងដោយមេធាវីការពារក្តីលោក នួន ជា ពាក់ព័ន្ធនឹងសេចក្តីសម្រេច ដែលអង្គជំនុំជម្រះបានចេញកាលពីពេលថ្មីៗនេះទៅលើការបំភ្លឺអំពីវិសាលភាពនៃការជំនុំជម្រះក្តី ពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈនៅក្រាំងតាចាន់ ត្រាំកក់ និងស-២១ គឺឯកសារ E306/7/3។ យើងយល់ឃើញថា សេចក្តីសម្រេចនេះមានឥទ្ធពលក្នុងការបញ្ចប់កិច្ចដំណើរការនីតិវិធី ហើយបើកពេលវេលាបណ្តឹងសាទុក្ខមួយខែ គឺបណ្តឹងសាទុក្ខភ្លាមៗ។

[០៩:៤០:០៧]

ដូច្នេះ ខ្ញុំជម្រាបជូនអង្គជំនុំជម្រះ និង ភាគីថា យើងខ្ញុំកំពុងតែរៀបចំបណ្តឹងសាទុក្ខទៅតុលាការកំពូលទៅលើសេចក្តីសម្រេចរបស់អង្គជំនុំជម្រះមួយនេះ ពីព្រោះថាយើងអត់យល់ទេ ចំពោះសេចក្តីសម្រេចមួយនេះ។ បើយើងមិនអាចពន្យល់ទៅដើមបណ្តឹងរដ្ឋប្បវេណីដែលកូនក្តីរបស់យើងបានទេ បើយើងមិនយល់អំពីសេចក្តីសម្រេចរបស់អង្គជំនុំជម្រះមួយនេះផង។ <យើងបានស្នើសុំឲ្យបំភ្លឺពីវិសាល-ភាពនៃការជំនុំជម្រះ។> អ៊ីចឹងអង្គជំនុំជម្រះបានច្រានចោលនូវពាក្យសុំនៃការកំណត់ចរិតលក្ខណៈឡើងវិញ <ដែលមិនមែនជាអ្វីដែលយើងស្នើសុំនោះទេ ហើយដោយសារការយល់ច្រឡំនោះ> យើង<បានសម្រេច>រៀបចំបណ្តឹងសាទុក្ខភ្លាមៗ។ <នេះជាការសម្រេចចិត្តមួយ> ហើយសេចក្តីសម្រេចហ្នឹង គឺមិនមែនជាសេចក្តីសម្រេចស្ថាពរទេ។ ដូច្នេះ អង្គជំនុំជម្រះនៅតែទទួលបណ្តឹងអំពីការរំលោភសេពសន្ថវៈនៅក្រាំងតាចាន់ ត្រាំកក់ និងស-២១ ដរាបណាដែលតុលាការកំពូលមិនទាន់សម្រេចទៅលើបណ្តឹងសា

ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

ទុក្ខរបស់យើង ដែលយើងនឹងដាក់នាពេលខាងមុខនេះ។ ដូច្នេះ យើងខ្ញុំរក្សាសិទ្ធិក្នុងការសួរសំណួរទៅលើអ្នកជំនាញ ទៅលើជំពូករបស់គាត់មួយចំនួន ដែលនិយាយអំពីការរំលោភសេពសន្ថវៈនៅក្នុងមន្ទីរសន្តិសុខ។

[០៩:៤១:១៩]

ខ្ញុំសូមឆ្លៀតឱកាសនេះក្នុងការធ្វើការកត់សម្គាល់នៅពេលនេះឲ្យហើយ ដើម្បីឲ្យអង្គជំនុំជម្រះជ្រាបច្បាស់អំពីគោលជំហររបស់យើង ហើយនៅពេលដែលខ្ញុំសម្រេចសួរសំណួរទៅលើអ្នកជំនាញពាក់ព័ន្ធនឹងការរំលោភសេពសន្ថវៈនៅមន្ទីរសន្តិសុខនោះ អង្គជំនុំជម្រះអាចសម្រេចទៅលើការជំទាស់បាននៅពេលនោះ ដោយមានប្រសិទ្ធភាព។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ គឺការសម្រេចរបស់អង្គជំនុំជម្រះនោះ មិនអាចកែប្រែវិសាលភាពបានទេ។ ដូច្នេះ ការរំលោភសេពសន្ថវៈនៅក្រាំងតាចាន់ ត្រាំកក់ នៅស-២១ នោះ វាស្ថិតនៅក្នុងវិសាលភាពនៃការជំនុំជម្រះក្ដីយើងនេះ។

**ប្រធានអង្គជំនុំ៖**

លោកស្រីមេធាវី លោកលើកដៃដែល អីក៏មានថ្មី?

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមឆ្លើយតបទៅនឹងការកត់សម្គាល់របស់ដើមបណ្ដឹងរដ្ឋប្បវេណីលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមឆ្លើយតបដោយខ្លីលោកប្រធាន។ យើងដឹងអំពីសេចក្ដីសម្រេចរបស់ដើមបណ្ដឹងរដ្ឋប្បវេណីក្នុងការប្ដឹងសាទុក្ខទៅលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ <>បើមានបណ្ដឹងសាទុក្ខ<ដែលនៅមិនទាន់បានសម្រេច នៅពេលនេះ ភាគីតែមួយគត់ដែលមានតួនាទីលើសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះតុលាការកំពូលគឺភាគីដើមបណ្ដឹងរដ្ឋប្បវេណី ហើយនៅពេលដែលយើងរង់ចាំសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ យើងគួរតែ>រក្សាទុកនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះដដែល ទោះបីជាមានការប្ដឹងសាទុក្ខក៏ដោយ ហើយបើសិនជាតុលាការកំពូលច្រានចោលនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងនុ៎ង ពេលនុ៎ងហើយទើបយើងអាចរំឭកទៅដល់អ្នកជំនាញថា ចំណុចមួយនុ៎ងវាមិនស្ថិតនៅក្នុងវិសាលភាពទេ។ <ដើម្បីចៀសវាងបញ្ហាក្នុងការជំទាស់ជា

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដើមនោះ គឺមានតែការចោទប្រកាន់ដែលទាក់ទងនឹងការសម្រេចរបស់អង្គជំនុំជម្រះទេ ដែលគួរតែត្រូវបានលើកយកមកពិភាក្សាដេញដោល ហើយនៅវគ្គក្រោយទៀត បើសេចក្ដីសម្រេចត្រូវបាន>ច្រានចោល<>នោះ គឺយើងអាចកោះហៅអ្នកជំនាញមកម្ដងទៀត ដើម្បីសួរនាំទៅលើចំណុចផ្សេងទៀតបាន។

**ប្រធានអង្គជំនុំ៖**

មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី សូមចប់រឿងហ្នឹងត្រឹមហ្នឹង។

អង្គជំនុំជម្រះជម្រាបទៅមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីរួចហើយថា សូមចប់រឿងនេះ ត្រឹមនេះ!

[០៩:៤៤:១៥]

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

លោកប្រធាន ដោយសារតែក្នុងការបកប្រែជាភាសាបារាំងនុ៎ង គឺថាមិនសូវច្បាស់ទេ <អ៊ីចឹងហើយបានជាខ្ញុំក្រោកឈរឡើង។> ក៏ប៉ុន្តែខ្ញុំគោរពតាមការសម្រេចរបស់អង្គជំនុំជម្រះក្នុងការបិទការពិភាក្សាត្រង់ចំណុចនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា វាជាសិទ្ធិរបស់ភាគីដែលមានសិទ្ធិប្ដឹងជំទាស់ អង្គជំនុំជម្រះសូមបញ្ចប់ត្រឹមនេះ។

[០៩:៤៤:៥៩]

**លោក វិក្ដៀម ស្មីត៖**

លោកប្រធាន ប្រសិនណាបើចង់បញ្ចប់ការពិភាក្សាខ្ញុំមិនជំទាស់ទេ។ អ្វីដែលខ្ញុំចង់ឆ្លើយតប<ដោយសង្ខេប>នោះគឺឆ្លើយតបពាក់ព័ន្ធទៅនឹង<>សំណើសុំ<តាម>វិធាន៩៣<ដោយក្រុមមេធាវី នួន ជា និងសំណើសុំតាមវិធាន៨៧(៤)> គឺខ្ញុំសុំពេលតែមួយនាទី ឬពីរនាទីទេ បើលោកប្រធានអនុញ្ញាត។ មិនមែនពាក់ព័ន្ធនឹងបណ្ដឹងឧទ្ធរណ៍មួយនេះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

**លោក វិក្ដៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំ<និយាយខ្លីៗ>ពាក់ព័ន្ធទៅនឹងចម្លើយតបរបស់ក្រុម នួន ជា និង

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ក្រុម ខៀវ សំផន។ ពាក់ព័ន្ធទៅនឹងការកំណត់<នៃសំណើសុំដោយ>អនុលោមទៅតាមវិធាន៩៣ មេធាវីការពារក្តី នួន ជា និយាយថា វាមានកាលបរិច្ឆេទកំណត់សម្រាប់<សំណើសុំតាម>វិធាន៩៣ គឺនៅត្រឹមថ្ងៃទី៣១ សីហា។ <ចំណុចនេះគឺយល់មិនត្រឹមត្រូវទេ។> តាមការពិតវិធាន៨៧(៤)ទៅវិញនោះទេដែលថាវិធាននេះ គឺត្រូវកំណត់ការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះ។ សំណើ សុំទាំងឡាយណាស្នើសុំឲ្យមានការស៊ើបអង្កេតបន្ថែម <ហើយដែល>មិនមានកាលបរិច្ឆេទផុតកំណត់នៅត្រឹមថ្ងៃនោះ <និងដើម្បីឲ្យអាចដំណើរការឲ្យបានជោគជ័យ> មេធាវីការពារក្តី<ចាំបាច់>ត្រូវ<ជូនដំណឹងដល់លោកប្រធានអំពី>បញ្ហានេះយូរយារណាស់មកហើយ។ <ហើយយើងបានពិភាក្សាពីមូលហេតុតើវាអាចធ្វើបានយ៉ាងណា។> ហើយពាក់ព័ន្ធទៅនឹង<ថា មាន>តែមួយផ្នែកនៃរបាយការណ៍របស់សហព្រះរាជអាជ្ញា<ទេដែលត្រូវបានទទួលយកនោះ។> យើងខ្ញុំសុំបញ្ជាក់ថា <>អង្គជំនុំជម្រះទទួលយកឯកសារទាំងអស់<នៅក្នុងសំណុំរឿង> ក៏ដូចជាឯកសារដែលមេធាវីការពារក្តីស្នើសុំ <ហើយពិតណាស់មានតែ>ភស្តុតាងដែលបានទទួលយកចេញពីឯកសារទាំងអស់នោះ<ទេ> ដែលពាក់ព័ន្ធទៅនឹងដំណាក់កាលនៃការជំនុំជម្រះនេះ គឺថាបញ្ហាទាំងអស់នេះអាចមានការជាប់ពាក់ព័ន្ធគ្នា។ វាអាចជាប់ពាក់ព័ន្ធនៅតាមទំព័រខុសគ្នាៗនៅក្នុងសៀវភៅនោះទាំងមូលតែម្តង។

[០៩:៤៧:០៦]

មេធាវីការពារក្តីបាននិយាយថា មូលដ្ឋានសម្រាប់អ្នកជំនាញ គឺអ្នកជំនាញរូបនេះ 2-TCE-82 គឺរបាយការណ៍ឆ្នាំ<>២០០៦ នោះគឺមិនត្រឹមត្រូវទេ។ <លោកប្រធានអាចដឹងហើយថា> អ្នកជំនាញបានសរសេរឯកសារជាច្រើនទៀត<ពាក់ព័ន្ធទៅនឹង>ការរៀបការដោយបង្ខំ <និងការរំលោភផ្លូវភេទនៅក្នុងការរៀបការដោយបង្ខំ ដែលមាននៅក្នុង>នូវរបាយការណ៍ដែលខាងសហព្រះរាជអាជ្ញាបានដាក់ពីមុននោះ<>។ <ដូច្នេះវាមិនមែនត្រឹមតែមូលដ្ឋាននៃជំនាញរបស់គាត់នោះទេ។>

ទី២ មេធាវីការពារក្តីស្នើសុំឲ្យទទួលយកសេចក្តីថ្លែងការណ៍ ក៏ដូចជា<>ទីតាំង<របស់>សាក្សី<ដែលមានដកស្រង់>នៅក្នុង<របាយការណ៍ទាំងពីរ>នេះ។ យើងខ្ញុំមិនជំទាស់ទេ <ដែលសំណួរទាំងនោះត្រូវសួរទៅអ្នកជំនាញ ហើយយើងក៏មិនជំទាស់ដែរ>ប្រសិនណាជាអ្នកជំនាញគាត់ផ្តល់ព័ត៌មាន<អំពីប្រភព>ដែលបានលើកឡើងយ៉ាងជាក់ច្បាស់នៅក្នុងសៀវភៅរបស់លោកស្រី។ មេធាវីការពារក្តី នួន ជា អះអាងថាពួកគាត់មិនអាច<>ជំទាស់តវ៉ាទៅនឹងព័ត៌មានរបស់អ្នកជំនាញនោះទេ។ <នោះជាអ្វីដែលមាននៅក្នុងដំណើរការសួរផ្ទៀងផ្ទាត់> គឺថា ត្រូវ<>សួរអ្នកជំនាញពាក់ព័ន្ធទៅនឹងប្រភព<ដែល

គាត់បានប្រើ និង>វិធីសាស្ត្រក្នុងការធ្វើការសិក្សាស្រាវជ្រាវ។ <បើសិនជាមានសំណួរល្អណាមួយ> ក្រោយការសួរតទល់គ្នាហើយនោះ <ដែលនាំ>ឲ្យអង្គជំនុំជម្រះ<ជឿ>ថា <អាចតម្រូវឲ្យមាន>ឯក-សារបន្ថែមទៀត <នោះគឺ>នឹងត្រូវ<ធ្វើនៅពេលធ្វើការវាយតម្លៃ មិនមែនធ្វើ>នាពេល<ទេ។ ជាពិសេស>ដោយសារតែពេលវេលាវាខ្លី ដូច្នេះមេធាវីការពារក្ដីគឺអនុញ្ញាតឲ្យចែកនូវព័ត៌មាន ចែកចាយនូវព័ត៌មានទាំងអស់នេះ ក្នុងចំណោមភាគី។ យើងខ្ញុំយល់ថា សំណើសុំបំបែកភស្តុតាង ហើយនិងសាក្សីនេះគឺថា យើងមិនអាចធ្វើទៅរួចទេ។ <នេះគឺផ្អែកទៅលើ>សំណើយឺតយ៉ាវពេកទៅហើយរបស់មេធាវីការពារក្ដី នួន ជា នោះ ហើយ<>ការជំនុំជម្រះ<មិនគួរត្រូវបានរារាំងដោយការស្នើសុំយឺតយ៉ាវបែបនេះទេ>។ <>ហើយប្រសិនណាបើចុងបញ្ចប់នៃសវនាការទៅ ហើយអ្នកជំនាញត្រូវបានទទួលសួរតទល់រួចហើយនោះ <បើ>អង្គជំនុំជម្រះ<យល់ឃើញថា ត្រូវផ្ដល់>ព័ត៌មាន<>បន្ថែម<ទៀត គឺយើងគោរពទៅតាមការសម្រេចរបស់អង្គជំនុំជម្រះ ហើយបន្ទាប់មកអាចកោះហៅអ្នកជំនាញត្រឡប់មកវិញបាន>។ ប៉ុន្តែការបំបែកយកសក្ខីកម្មនេះ <គឺមិនមែនជាការប្រើប្រាស់ពេលវេលាឲ្យមានប្រយោជន៍> ទេ។ <វាបង្កើតនូវបញ្ហាជាច្រើនរវាងបញ្ហាអ្វីដែលត្រូវបានពិភាក្សា និងបញ្ហាអ្វីដែលមិនត្រូវបានពិភាក្សា។> ដូច្នេះ យើងខ្ញុំសុំស្នើសុំដល់អង្គជំនុំជម្រះថា កុំផ្អាកពេលវេលានៃការ<ផ្ដល់សក្ខីកម្មរបស់> អ្នកជំនាញ។ សូមអរគុណ។

[០៩:៤៩:៥៩]

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ ភាគីដែលបានឆ្លើយតបចំពោះសំណើសុំទាំងនេះ អង្គជំនុំជម្រះនឹងយកមតិយោបល់ទាំងនេះទៅពិនិត្យពិចារណា ដើម្បីអាចចេញសេចក្ដីសម្រេចលើសំណើសុំទាំងនេះឲ្យបានឆាប់ មុនពេលស្ដាប់សក្ខីកម្មអ្នកជំនាញ 2-TCE-82។

ជាបន្ត អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី 2-TCW-1002។

អង្គជំនុំជម្រះសូមជម្រាបដល់ភាគីនិងសាធារណជនឲ្យបានជ្រាបថា ដំណើរការស្ដាប់សក្ខីកម្មសាក្សីរូបនេះ នឹងធ្វើឡើងនៅក្នុងសវនាការជាអសាធារណៈ ដោយសារតែសាក្សីរូបនេះ ត្រូវបានស្ដាប់ចម្លើយនៅក្នុងកិច្ចស៊ើបអង្កេតដែលកំពុងដំណើរការនៅក្នុងសំណុំរឿងផ្សេង។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់សាក្សីរូបនេះស្ថិតនៅក្នុងក្រុម“គ” ដែលតម្រូវឲ្យការស្ដាប់សក្ខីកម្មរបស់គាត់ ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ ក្នុងគោលបំណងការពារនូវភាពសម្ងាត់ នៃកិច្ចដំណើរការស៊ើប

អង្កេត ឯកសារ E319/35។

ក្រោយពីបានស្តាប់មតិយោបល់របស់ភាគីទៅលើអសាធារណភាពនៃដំណើរការស្តាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះសម្រេចស្តាប់សក្ខីកម្មសាក្សីរូបនេះ នៅក្នុងសាល -- ក្នុងសវនាការជាអសាធារណ: E319/35/6។

បង្គាប់ឲ្យមន្ត្រីផ្នែកសោតទស្សន៍កាត់ផ្តាច់នូវការផ្សព្វផ្សាយប្រព័ន្ធសំឡេង និងរូបភាពសម្រាប់ផ្សព្វផ្សាយចេញពីបន្ទប់សវនាការទៅកាន់សាលសវនាការសម្រាប់សាធារណជន បន្ទប់ផ្សព្វផ្សាយសម្រាប់អ្នកសារព័ត៌មាន និងបុគ្គលិកនៃ អ.វ.ត.ក ផ្សេងទៀត ដែលជាការផ្សាយតាមរយៈវីដេអូសម្រាប់ផ្ទៃក្នុង អ.វ.ត.ក លើកលែងតែអ្នកពាក់ព័ន្ធនៅក្នុងសាលសវនាការនេះ។

បង្គាប់ឲ្យមន្ត្រីរដ្ឋបាលតុលាការ អញ្ជើញសាក្សីដែលមានរហស្សនាម 2-TCW-1002 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សវនាការសាធារណ:សម្រាកនៅម៉ោង ០៩:៥២ នាទី)*

*(សវនាការអសាធារណ:ចាប់ផ្តើមនៅម៉ោង ០៩:៥៥ នាទី)*

[០៩:៥៥:៣៥]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកស្រី តើលោកស្រីឈ្មោះអី?

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** ខ្ញុំឈ្មោះ ណុប ង៉ឹម។

**ស៖** លោកស្រីកើតនៅថ្ងៃ ខែ ឆ្នាំណាដែរ? លោកស្រីៗ ចាំឆ្លើយនៅពេលដែលមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហមចាំលោកស្រីឆ្លើយ។ ដល់ថ្ងៃនេះ លោកស្រីអាយុប៉ុន្មានហើយ?

**ឆ៖** ៦៦ហើយដឹង! ខ្ញុំអត់ចេះដែរនឹងណា៎ ខ្ញុំអត់ចេះអក្សរផង។

**ស៖** សព្វថ្ងៃលោកស្រីរស់នៅកន្លែងណាដែរ?

**ឆ៖** ខេត្តពោធិ៍សាត់ នៅស្រុកវាលវែង។

**ស៖** ហើយប្រកបមុខរបរអី?

**ឆ៖** ចាស ខ្ញុំអត់ដឹងខែ ថ្ងៃ។

**ស៖** លោកស្រីប្រកបមុខរបរអី?

**ឆ៖** ខ្ញុំដាំដំឡូង ដាំសណ្ដែកសៀង។

**ស៖** ឪពុកម្ដាយលោកស្រីឈ្មោះអីដែរ?

**ឆ៖** គាត់ស្លាប់អស់ហើយ គាត់ស្លាប់យូរហើយ។ គាត់ឈ្មោះ ម៉ែខ្ញុំឈ្មោះ ប្រាក់ ង៉ែត។ ឪពុកខ្ញុំឈ្មោះ ណុប យី។

**ស៖** អរគុណលោកស្រី។ ប្ដីលោកស្រីឈ្មោះអី? ហើយមានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំមានកូនពីរនាក់។

**ស៖** លោកស្រីចេះអក្សរទេ?

**ឆ៖** ខ្ញុំអត់ចេះអក្សរទេ។

**ស៖** អរគុណលោកស្រី។ តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការថាតាមសមត្ថភាពដែលលោកស្រីអាចដឹង គឺលោកស្រីមិនមានចំណងញាតិលោហិត ឬញាតិពន្ធជាមួយជនជាប់ចោទទាំងពីររូប គឺលោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលទាំងឡាយដែលត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះទេ។ តើពិតមែនដែរឬទេ?

**ឆ៖** ពីមុនមក ខ្ញុំឮតែឈ្មោះ ខ្ញុំមិនដែលឃើញគាត់ផង ឮសូរតែឈ្មោះ។

**ស៖** ហើយថាលោកស្រីបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយឬនៅ រួចហើយមុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

**ឆ៖** ខ្ញុំធ្វើហើយៗ ស្បថហើយៗ។

[០៩:៥៨:៥៦]

**ស៖** អរគុណលោកស្រី។ ជាបន្តទៅនេះ អង្គជំនុំជម្រះប្រាប់អំពីសិទ្ធិ និងករណីយកិច្ចក្នុងឋានៈលោកស្រីជាសាក្សីចំពោះមុខអង្គជំនុំជម្រះ។ អំពីសិទ្ធិ លោកស្រី ណុប ងឹម ក្នុងឋានៈលោកស្រីជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ លោកស្រីអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការណ៍ដែលលោកស្រីធ្វើអត្ថាធិប្បាយមួយឬច្រើន ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនសិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ អំពីករណីយកិច្ច ក្នុងឋានៈលោកស្រីជាសាក្សីក្នុងការកិច្ចដំណើរសវនាការនេះ លោកស្រីត្រូវតែឆ្លើយតបទៅនឹងរាល់សំណួរដែលភាគី ឬចៅក្រមសួរចំពោះលោកស្រីលើកលែងតែសំណួរណាដែលនាំឲ្យចម្លើយរបស់លោកស្រីដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពី

សិទ្ធិរួចហើយ។ ក្នុងឋានៈលោកស្រីជាសាក្សី លោកស្រីត្រូវឆ្លើយតែការណ៍ណាដែលពិត ដែលលោកស្រីបានដឹង បានឮ បានឃើញ បានចងចាំ ឬក៏ធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬក៏បានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ឬហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោកស្រី។

លោកស្រី ណុប ធីម តើលោកស្រីធ្លាប់បានផ្តល់សក្ខីកម្ម ឬកិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតដែរឬទេពីមុនមក? ហើយប្រសិនបើបានធ្វើ ធ្លាប់ធ្វើប៉ុន្មានដងហើយ នៅកន្លែងណា?

**ឆ៖** ខ្ញុំមក មើល៍ បីដង បួនដងលើកហ្នឹងហើយ។

**ស៖** អរគុណលោកស្រី ហើយមុនចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ តើលោកស្រីបានពិនិត្យមើល ឬបានអាន ឬបានស្តាប់ការអាននូវកំណត់ហេតុដែលលោកស្រីបានផ្តល់សក្ខីកម្មពីពេលមុន ដើម្បីរំឭកការចងចាំរបស់លោកស្រីដែរឬទេ?

[១០:០១:០៧]

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ស៖** លោកស្រីដើមបណ្តឹងរដ្ឋប្បវេណី -- អ៎! លោកស្រីសាក្សី ចាំមីក្រូហ្វូនដំណើរការចេញភ្លើងពណ៌ក្រហម ចាំលោកស្រីឆ្លើយ។

**ឆ៖** ខ្ញុំ ច្រើនពេក ខ្ញុំអត់ចាំដែរហ្នឹង បើវាយូរឆ្នាំទៅហើយ ហើយវង្វេងវង្វាន់ដែរហ្នឹង ខ្ញុំ។

**ស៖** អរគុណលោកស្រី។ ហើយតាមសមត្ថភាពដែលលោកស្រីអាចដឹង និងចងចាំ តើលោកស្រីអាចបញ្ជាក់បានទេថា តើកំណត់ហេតុដែលស្តាប់ចម្លើយដែលលោកស្រីបានអាន ឬក៏ស្តាប់ការអានដើម្បីរំឭកការចងចាំ វាពិតជាត្រឹមត្រូវ វាសមស្រប ហើយវាស៊ីចង្វាក់គ្នាទៅនឹងអ្វីដែលលោកស្រីបានផ្តល់កិច្ចសម្ភាសន៍ជាមួយអ្នកស៊ើបអង្កេតកាលពីលើកមុនដែរឬទេ?

**ឆ៖** ចាស ខ្ញុំ បើសួរចំពោះតាម ហ្នឹងខ្ញុំភ្លេចដែរ ដល់អធ្យាស្រ័យឲ្យផង ខ្ញុំអត់ចេះអក្សរផង។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រី។ ក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អនុវត្តតាមបញ្ញត្តិនៃវិធាន៩១ស្ទួននៃវិធានក្នុង អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនតំណាងសហព្រះរាជអាជ្ញាសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀត។

សហព្រះរាជអាជ្ញា ទាំងសហមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីមានរយៈពេលពីរវគ្គ នៃថ្ងៃសវនាការ ក្នុងការតាំងសំណួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញលោកព្រះរាជអាជ្ញា!

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី។ តើត្រឹមត្រូវទេ ដែលថាលោកស្រីកើតនៅស្រុកត្រាំកក់?

**លោកស្រី ណុប ងឹម៖**

**ឆ៖** ត្រឹមត្រូវ។

**ស៖** សូមលោកស្រីប្រាប់តុលាការដោយសង្ខេប ថាតើលោកស្រីបានធ្វើអ្វី បន្ទាប់ពីរដ្ឋប្រហារលន់ នល់ ក្នុងឆ្នាំ១៩៧០ <ក្នុងអំឡុងពេលសង្គ្រាមស៊ីវិលនៅកម្ពុជា> រហូតមកដល់ឆ្នាំ១៩៧៥នោះ?

**ឆ៖** មួយពាន់ប្រាំបួនរយ -- ខ្ញុំអង្កាល់នោះ ខ្ញុំនៅស្រែអំបិល។ នៅស្រែអំបិល ពីមុនមក ជំនាន់លន់ នល់ ទាហាន លន់ នល់។ ខ្ញុំធ្វើទាហានលន់ នល់ កងនារី។ ដល់ហើយ បានមកស្រែអំបិលវិញ។ ខ្ញុំភ្លេចដែរហ្នឹងណា វាយូរដែរហើយ សម្ដាសអ៊ីចឹង អ៊ីចេះនេះ គាត់សួរនេះ ប៉ុន្តែដល់ឥឡូវ ខ្ញុំភ្លេចដែរហ្នឹង អធ្យាស្រ័យឲ្យផង។

[១០:០៣:៥៤]

**ស៖** នៅពេលដែលលោកស្រីថា លោកស្រី<>ជាទាហាន<ក្នុងពេល>លន់ នល់<នោះ> តើទាហានកាលនោះ ជាទាហានរបស់លន់ នល់ ឬក៏ជាទាហានរបស់ខ្មែរក្រហម?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីចាំមីក្រូហ្វូនប្រតិបត្តិការឡើងភ្លើងក្រហម ចាំឆ្លើយ។

**លោកស្រី ណុប ងឹម៖**

**ឆ៖** ខ្ញុំធ្វើទាហានខ្មែរក្រហម។

**ស៖** អ៊ីចឹង ខ្ញុំចូលទៅដល់សម័យកាលក្រោយពីខែមេសា ១៩៧៥ បន្ទាប់ពីភ្នំពេញត្រូវបានកាន់កាប់ដោយខ្មែរក្រហម។ លោកស្រីនិយាយអំពីស្រែអំបិល តើក្រោយពីជ័យជម្នះរបស់ខ្មែរក្រហមឆ្នាំ១៩៧៥ បានទៅស្រែអំបិល ឬយ៉ាងម៉េច?

**ឆ៖** ខ្ញុំ៧៥ ផ្លាស់មកនៅភ្នំដិន ដល់៧៨ បានទៅស្រែអំបិល -- ៧៧។ ៧៧ ទៅស្រែអំបិល។

[១០:០៥:០០]

**ស៖** នៅពេលដែលលោកស្រីធ្វើជាយោធាខ្មែរក្រហម តើមេបញ្ជាការរបស់លោកស្រីឈ្មោះអ្វី តើមេបញ្ជាការខ្ពស់ ឬក៏មេបញ្ជាការធំ ឈ្មោះអ្វី?

**ឆ៖** កាលហ្នឹង មានតាម៉ុក ហ្នឹង។ តាម៉ុក មេបញ្ជាការ ស្លាប់បាត់ហើយ។

**ស៖** នៅពេលដែលគេបញ្ជូនលោកស្រីទៅស្រែអំបិល តើអ្នកណាជាអ្នកបញ្ជូនទៅ?

**ឆ៖** តាម៉ុក ដែរ។

**ស៖** តើស្រែអំបិល នៅភូមិភាគណា នៅភូមិភាគនិរតី ឬក៏នៅភូមិភាគណា?

**ឆ៖** ស្រែអំបិល នៅកំពត ស្រែអំបិល កែប។

**ស៖** តើលោកស្រីមានតួនាទីជាអ្នកមើលការងារ ឬក៏ត្រួតការងាររបស់កម្មករផ្សេងទៀតទេ នៅស្រែអំបិល?

**ឆ៖** អ៊ូ!អំមិញខ្ញុំឆ្លើយខុស នៅស្រែអំបិល នេះ ស្រែអំបិលអង្គោល ប៉ុន្តែស្រែអំបិលរួមគ្នាទាំងអស់ វាអង្គភាពតែមួយ។

**ស៖** ខ្ញុំមិនទាន់យល់ចម្លើយរបស់លោកស្រី។ តើលោកស្រីជាប្រធានរបស់ក្រុមមួយដែលមានសមាជិក ៥០នាក់ដែរឬទេ? ហើយអ្នកណាជាមេពីលើរបស់លោកស្រី ឬក៏ដូចម្ដេច បាទ?

**ឆ៖** ខ្ញុំគេចាត់តាំងឲ្យធ្វើកងហា១ មានគេពីលើហ្នឹងទៀត។ ត្រឹមកងវរៈ កងរយអីមានគេ។

[១០:០៧:៣៩]

**ស៖** តើប្រធានរបស់លោកស្រីមានអ្នកណាម្នាក់ ឈ្មោះ ឃឹម ទេបាទ?

**ឆ៖** ចាស មាន អង្គភាព។

**ស៖** នៅពេលដែលលោកស្រីនៅស្រែអំបិល តើឃឹម គាត់បានរៀបការទេ កាលនោះ?

**ឆ៖** គាត់មករៀបការនៅសំឡូតជាមួយខ្ញុំ។ អ៊ូ ! បងឃឹម អត់ទេ ខ្ញុំចង់វង្វេងហើយ បងឃឹម អត់ទេ។ គាត់បានរៀបការផងហ្នឹង ប្ដីគាត់ហើយគាត់មិនដឹងទៅណាបាត់ទេ ជំនាន់ហ្នឹង។ គាត់រៀបការហើយ រៀបការនៅស្រែអំបិល។

**ស៖** តើមានអ្នកណា<ប្រាប់លោកស្រីអំពីការ>រៀបការ<នោះទេ? តើមានអ្នកណារៀបចំ> ទេ?

**ឆ៖** កាលនៅស្រែអំបិលអត់ទាន់បានការទេ។ តែខ្ញុំការមួយៗ កាលនោះភ្លេចអស់ហើយ ជំនាន់

ហ្នឹងយូរហើយ។

[១០:០៨:៤៧]

**ស៖** សូមលោកស្រីស្ដាប់សំណួរខ្ញុំឲ្យយល់។ ខ្ញុំសួរអំពី ឃឹម ហើយឥឡូវនេះគឺថាបំភ្លេចចោលពាក្យថាអ្នកនៅស្រែអំបិល។ ខ្ញុំសួរថាតើ ឃឹម ហ្នឹងគាត់រៀបការនៅភ្នំ<មិន> ឬក៏គាត់រៀបការនៅឯណា?

**ឆ៖** រៀបការនៅស្រែអំបិល។ កាលជំនាន់ហ្នឹង មិនដឹងយកទៅរៀបការឯណា ឃើញមកវិញរៀបការនៅស្រែអំបិល គេហៅថាស្រែអំបិល។ រៀបការហើយៗ។ អធ្យាស្រ័យផង ខ្ញុំវង្វេងវង្វាន់ដែលហ្នឹង ភ្លេចដែរ យូរដែរហើយ។

**ស៖** តើគាត់រៀបការនៅភ្នំពេញ ហើយមានគេផ្គូរផ្គងរៀបការឲ្យគាត់ ឬក៏ដូចម្ដេច?

**ប្រធានអង្គជំនុំ៖**

លោកស្រីសាក្សី ចាំមីក្រូហ្វូនដំណើរការសិនចាំឆ្លើយ ភ្លើងក្រហម។

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** កាលជំនាន់ហ្នឹង គាត់រៀបការមានឯណា ចាប់ការៗតែម្ដង។ ទោះបីអ្នកមិនព្រម ក៏ត្រូវការដែរ។

**ប្រធានអង្គជំនុំ៖**

លោកព្រះរាជអាជ្ញា អរគុណលោកព្រះរាជអាជ្ញា។

ឥឡូវដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាក ២០នាទីចាប់ពីពេលនេះតទៅ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១០ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:៤០]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកព្រះរាជអាជ្ញាបន្តសំណួរ!

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកស្រីសាក្សី លោកស្រីនឹកឃើញទេ ៥ឆ្នាំកន្លងទៅហើយនេះ មានបុរសម្នាក់ឈ្មោះ ឡុង ដានី បានទៅសម្ភាសលោក<ស្រី និងប្ដីលោកស្រី>នៅភូមិរបស់លោកស្រី គាត់មកពីអង្គការមួយ ឈ្មោះថា “មជ្ឈមណ្ឌលឯកសារកម្ពុជា” ហើយបានទៅសួរលោកស្រីអំពីអ្វីដែលបានកើតឡើងនៅក្នុង ជីវិតរបស់លោកស្រី។ លោកស្រីនឹកឃើញទេ?

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** គាត់ទៅសម្ភាសដឹងដែរតើ។ គាត់សួរខ្ញុំថា មុនដំបូងនៅណាអីណា អង្គភាពណាអ៊ីចឹង នៅ ធ្វើអី ខ្ញុំប្រាប់គាត់ ខ្ញុំពីមុនមក ៧២, ៧៣ ខ្ញុំធ្វើទ័ពខ្មែរក្រហម ធ្វើទាហានខ្មែរក្រហម។ ខ្ញុំប្រាប់គាត់អ៊ីចឹង ដែរហ្នឹង។

[១០:៣១:៤៨]

**ស៖** ខ្ញុំមិនចង់សួរនៅគ្រប់ចម្លើយរបស់លោកស្រីនោះទេ ដោយសារតែយើងមានប្រតិចារឹក៩០ ទំព័ររួចហើយ ប៉ុន្តែខ្ញុំចង់សួរពីឈ្មោះ ឃឹម ហើយនិងការរៀបការរបស់ ឃឹម។ លោកស្រីទើបឆ្លើយថា គាត់ត្រូវបានគេបង្ខំឲ្យរៀបការ។ នេះគឺអ្វីដែលលោកស្រីបានឆ្លើយប្រាប់ ឡុង ដានី គឺឯកសារ <E3/9087> ERN ជាភាសាខ្មែរ 00733821, អង់គ្លេស 01155586, មិនមានការបកប្រែទៅជា ភាសាបារាំងទេ។ គាត់បាននិយាយថា ឃឹម រស់នៅឯភ្នំដិន។ ក្រោយភ្នំពេញដួលរលំទៅ ពួបានយកគាត់ មកឲ្យរៀបការនៅភ្នំពេញ។ ហើយ ដានី សួរថាតើការរៀបការ រៀបការនៅភ្នំពេញឬ? លោកស្រីឆ្លើយ ថា ចាស គឺថាគាត់រៀបការជាមួយនឹងចិន -- បានរៀបការជាមួយបុរសម្នាក់ឈ្មោះ ហួ កាត់ចិន។ តើ អ៊ីចឹងមែនទេ គឺថា ឃឹម គេត្រូវបានយកមកភ្នំពេញ ហើយរៀបការជាមួយបុរសម្នាក់ឈ្មោះ ហួ?

**ឆ៖** ចាស គាត់នៅស្រែអំបិល ហើយដល់នេះ គេយកមកការនៅភ្នំពេញ គ្រួសារគាត់ឈ្មោះ ពូ ហួ។ គ្រួសារគាត់ចិន។ ចិនជំនាន់ហ្នឹង ចេះតែខ្មែរទាំងអស់ហ្នឹងណ៎ា។ ខ្ញុំបានដឹងអ៊ីចឹង ហើយខ្ញុំគាត់សួរ ខ្ញុំថា ធ្វើម៉េចបានខ្ញុំដឹងថាគេរៀបការ ព្រោះអីនារីៗជំនាន់ហ្នឹងនិយាយប្រាប់គ្នាដែរហ្នឹងណ៎ា “ហ៊ឺ ! គេ បង្ខំឲ្យការឲ្យអ៊ីចឹង” បានខ្ញុំដឹងហ្នឹង។

[១០:៣៣:៥០]

**ស៖** លោកស្រីបានឆ្លើយថា អ៊ំៗនេះបានយកគាត់មកឲ្យរៀបការនៅភ្នំពេញ។ អ៊ំ ហ្នឹងជាអ្នក ណា?

**ឆ៖** អ៊ំ ម៉ុក។

**ស៖** នៅពេលដែលលោកស្រីបានឆ្លើយថា ហួ នេះជាចិន។ ហួ នេះជាចិនមកពីប្រទេសចិន ឬគ្រាន់តែជាចិនជាប់ដោយសាច់ឈាមរស់នៅក្នុងប្រទេសកម្ពុជាទេ?

**ឆ៖** ចិន មិនមែនមកស្រុកចិនណា គាត់នៅប្រទេសកម្ពុជាហ្នឹង ប៉ុនចេះថាគាត់ឈ្មោះ ហួៗ ចេះតែថាចិនទៅ ព្រោះគាត់សដូចចិនអ៊ីចឹងណ៎ា អ៊ីចឹងឯង ប៉ុនខ្សែចិនខ្លះ វាមិនអត់ទេ។

**ស៖** តើ យឹម មានបានធ្លាប់ស្គាល់ ហួ ដែរ មុនពេល តាម៉ុក យក យឹម មកឲ្យរៀបការជាមួយនឹង ហួ ហ្នឹង?

**ឆ៖** អត់មានដែលស្គាល់គ្នាទេ អត់សោះ។

**ស៖** ឥឡូវខ្ញុំបន្តទៅសួរ តើមានអ្វីកើតឡើងក្រោយពេលលោកស្រីចេញពីស្រែអំបិល ដែលពេលនោះនៅភូមិភាគនិរតី។ តើលោកស្រីចេញទៅឯណា ពេលដែលលោកស្រីចេញពីស្រែអំបិល<នៅខេត្តកណ្តាល>រួចមក?

[១០:៣៥:២១]

**ឆ៖** ស្រែអំបិលគឺ ពូម៉ុក គាត់ដឹកដាក់រទេះភ្លើងយកមកពាយ័ព្យនេះ យកមកបាត់ដំបងហ្នឹង។ ពូម៉ុក គាត់ដឹកមក អត់ដឹង អត់សួរដឹងដែរ។ ខ្ញុំ គាត់ដឹកមក ចេះតែមក។ ធ្វើម៉េច ធ្វើបញ្ជាតាម បើយើងនៅក្រោមបញ្ជាគេ គេបញ្ជាទៅណា ទៅនៅហ្នឹងហើយ។

**ស៖** នៅពេល តាម៉ុក បញ្ជូនលោកស្រីទៅបាត់ដំបង តើគាត់បញ្ជូនលោកស្រីទៅទីនោះតែម្នាក់ឯង ឬក៏បញ្ជូនទៅជាមួយអ្នកដទៃៗទៀតមកពីភូមិភាគផ្សេងដែរ?

**ប្រធានអង្គជំនុំ៖**

លោកស្រីសាក្សីៗ ចាំឆ្លើយនៅពេលមីក្រូហ្វូនដំណើរការសិន!

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** គឺគាត់ដឹកមក គឺមកគ្នាប្រហែលជិត៣០០នាក់នោះ មកមន្ទីរស្រែអំបិល មកចង់អស់។ មកដឹកបាត់ដំបង ខ្ញុំមិនដែលស្គាល់បាត់ដំបង បាត់អីទេ ចេះតែមកទៅ។ ខ្ញុំសុំសំណួរមួយ ខ្ញុំមិនមែនឈ្មោះ ង៉ឹម ទេណា ឈ្មោះ ង៉ឹម ណ៎ា ប្រយ័ត្នច្រឡំទៀត។ គាត់មិញហៅខ្ញុំ ង៉ឹម។

[១០:៣៦:៥០]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** អរគុណ លោកស្រី ង៉ឹម។ នៅពេលលោកស្រីទៅបាត់ដំបង តើ តាម៉ុក រស់នៅឯបាត់ដំបង

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

នោះដែរឬអត់ទេ?

**ឆ៖** កាលហ្នឹង គាត់នៅតាកែវហើយ គាត់ទៅបាត់ដំបង។ គាត់ទៅមកៗ ខ្ញុំមិនបានដឹងដែរ មិនបានយល់។ គាត់ទៅមកៗ គាត់មេ ខ្ញុំមិនដឹងដែរ។ ហ្នឹងខ្ញុំមានដឹងតែប៉ុណ្ណឹង។

**ស៖** តើ តាម៉ុក គាត់មានផ្ទះនៅឯបាត់ដំបងដែរអត់ទេ នៅពេលដែលលោកស្រីទៅដល់ទីនោះ?

**ឆ៖** មាន ផ្ទះគាត់មាននៅបាត់ដំបងមួយកន្លែង។

**ស៖** តើ តាម៉ុក <>មានប្រាប់លោកស្រី<ឬក៏អ្នកដទៃទៀត>ទេថា ហេតុអីបានជាគេបញ្ជូនលោកស្រីទៅបាត់ដំបង?

**ឆ៖** ជូនទៅគ្នាច្រើនហើយ ដាក់រទេះភ្លើងទៅ ដើរហៅជូនទៅបាត់ដំបង ទៅនៅ ប្រាប់ខ្ញុំថាទៅនៅបាត់ដំបង ហើយយកទៅនៅស្រុកសំឡូតទៅ ស្រុកសំឡូត បាត់ដំបង។

**ស៖** នៅឯស្រុកសំឡូតហ្នឹង តើ តាម៉ុក ឲ្យលោកស្រីកាន់មុខតំណែងអ្វីដែរ?

[១០:៣៨:២៣]

**ឆ៖** ឲ្យខ្ញុំ ហ៊ឺ ! ទៅនៅបាន៦ខែហ្នឹង ប្រាំមួយប្រាំពីរខែហ្នឹង ដល់គាត់ឲ្យខ្ញុំទៅនៅហ្នឹង កាន់នៅជាមួយ បងឡេង ហ្នឹងនៅជាមួយស្រុកហ្នឹង ចេះតែនៅជាមួយ ចេះជួយធ្វើការងារគ្នាទៅ ចាំស្រុកឲ្យគ្នាហ្នឹង។ ខ្ញុំក្រោមគេទេ ខ្ញុំមិនចេះអក្សរទេ ស្រេចគេប្រើ។ ខ្ញុំក្រោមគេ។

**ស៖** ចុះ ឡេង ហ្នឹងមានតួនាទីអ្វីដែរ?

**ឆ៖** គាត់ខាងស្រុក ប្រធាន។

**ស៖** ខ្ញុំសុំសួរបញ្ជាក់ឲ្យបានច្បាស់ តើ ឡេង នេះប្រុស ឬក៏ស្រី?

**ឆ៖** ស្រី គាត់ស្រី។

**ស៖** តើនៅពេលនោះ លោកស្រីជាអនុប្រធានស្រុក ជាអនុលេខាស្រុកមែនទេ?

**ឆ៖** ចាស ចាត់តាំងគ្នាជួយៗគ្នាទៅ។ នៅស្រុកគេឆ្ងាយ។

**ស៖** តើ តាម៉ុក មានណែនាំអ្វីទៅដល់លោកស្រីថា តើត្រូវបំពេញមុខងារនេះដោយរបៀបណាដែរឬទេ?

[១០:៣៩:៥៨]

**ឆ៖** គាត់ណែនាំនាងខ្ញុំថា ខំបំពេញភារកិច្ចមើលឲ្យប្រជាជនហូបបាយឲ្យគ្រប់គ្រាន់។ គាត់ថាវាស្រុកហ្នឹងវាស្រុកថ្មី គេទើបមកនៅ។ គាត់ប្រាប់អ៊ីចឹង កុំឲ្យប្រជាជនហូបបបរពេក ឲ្យហូបបាយខ្លះ

អីខ្លះទៅ។

**សៈ** តើ ឡេង នេះ<មកពីខាងណា? តើ>គាត់មកពីខាងក្រៅភូមិភាគ<ពាយ័ព្យឬ>?

**ឆៈ** នៅតាកែវ នៅកំពត ដូចតែគ្នាហ្នឹង ប៉ុន្តែនៅស្រុកតាកែវដូចគ្នា ប៉ុន្តែគេចាត់តាំងឲ្យមក មកនៅបាត់ដំបងដូចតែគ្នាហ្នឹង ពូ។

**សៈ** តើ ឡេង នេះក្នុងឋានៈជាលេខាស្រុកហ្នឹង គាត់ត្រូវរាយការណ៍ទៅឲ្យអ្នកណា តើអ្នកណា នៅពីលើគាត់ អ្នកណាជាចៅហ្វាយរបស់ ឡេង?

**ឆៈ** ប្រធានតំបន់ គណៈតំបន់។

**សៈ** ចុះប្រធានតំបន់នោះ ឈ្មោះអ្វីដែរ?

**ឆៈ** តំបន់១ ឈ្មោះ អ៊ំទិត្យ។ ខ្ញុំស្គាល់គាត់។

**សៈ** ចុះឈ្មោះ ទិត្យ នេះ មកពីភូមិភាគនិរតីដែរ ឬក៏យ៉ាងណា?

**ឆៈ** ចាស មកពីនិរតីដែរ។

**សៈ** ចុះ ទិត្យ នេះ រាយការណ៍ទៅអ្នកណាដែរ? អ្នកណាជាៗប្រធាន អ្នកណានៅពីលើ ទិត្យ នេះ?

**ឆៈ** ខ្ញុំអត់ដឹង ព្រោះអីខ្ញុំតូចតាចអីចឹង មិនដឹងណាប្រធាន ណាអនុអី ខ្ញុំអត់ដឹងទេ។ ដឹងណាគេខ្លះ ខ្ញុំស្គាល់តែ អ៊ំទិត្យ មួយ។

[១០:៤២:១៦]

**សៈ** ខ្ញុំគិតថាលោកស្រីចងចាំ អាចចងចាំបាន។ តើលោកស្រីរៀបការនៅពេលដែលលោកស្រី ទៅនៅឯសំឡូតនោះឬ?

**ឆៈ** ចាស ខ្ញុំគាត់ការនៅសំឡូត ការ៤០គូ តែបីម៉ោងទេ៤០គូ។ ចាប់ដាក់ៗ ខ្លះយំ ខ្លះស្រែក ខ្លះ រត់ចោល។ រត់ចោលពីរនាក់។

**សៈ** ចុះលោកស្រីខ្លួនឯងនេះ គឺស្ថិតនៅក្រោមចំណោមមនុស្សម្នាក់ ឬក៏គូមួយដែលស្រែកយំអី ដែរទេ មុនពេល និងក្រោយពេលរៀបការនុ៎ង?

**ឆៈ** ខ្ញុំមិន -- ខ្ញុំយំដែរហ្នឹង ប៉ុនអន់ចិត្តអត់ដឹងខ្លួនសោះ អន់ចិត្តៗមាំណាស់ ព្រោះអីអត់ដែល ឃើញ វាដែលឃើញ ធ្លាប់ឃើញគ្នាកាលនៅទ័ពដូចគ្នា ប៉ុនដល់តែចាប់ដាក់អីចឹង ខ្ញុំអន់ចិត្ត ខ្ញុំចង់រត់ដែរ ប៉ុន្តែខ្លាចគេវៃចោល កុំអីរត់បាត់ហើយ ព្រោះអីឯងអ្នកដឹកនាំគេបន្តិចបន្តួចដែរ យើងធ្វើអីចឹង ខ្លាចគេវៃ

ចោល។ អ៊ីចឹងចេះតែទ្រាំ។ ទ្រាំបាន បានគ្រួសារខ្ញុំចេះស្រឡាញ់គ្នារហូត។

[១០:៤៣:៥០]

**សៈ** លោកស្រីនៅចាំថ្ងៃខែរៀបការហ្នឹងដែរឬទេ?

**ធៈ** ចាំ ខ្ញុំការខែ០៨ អ៎នែ! ឆ្នាំ៧៨ សល់ខែ អ៎!ខែណាទេ ខែ១ស្រូវបែកគុម្ព ដឹងខែណា! ខែស្រូវបែកគុម្ព ខែ៩មិនដឹង ខែ១២ ខែប៉ុន្មានទេ ខ្ញុំអត់ចាំ ចាំតែឆ្នាំ ព្រោះអីខ្ញុំមិនចេះអក្សរ ព្យាយាមមិនច្បាស់ទេ។ នោះក្នុងនោះមាន ប៉ុនខ្ញុំអត់ចាំ។ ក្នុងហ្នឹងមានអានុំង ៧៨។ ខ្ញុំវាអត់ចាំ។

**សៈ** មិនថ្វីទេ លោកស្រី។ តើលោកស្រីនៅនឹកឃើញទេថា លោកស្រីបានរៀបការហ្នឹង បានរៀបការរយៈពេលប៉ុន្មានខែ នៅពេលមុនពេលវៀតណាមចូលមកដល់នុ៎ង? តើវាមានរយៈពេលប៉ុន្មានខែ ឬក៏ប៉ុន្មានឆ្នាំ មុនពេលវៀតណាមចូលមកដល់?

**ធៈ** បាន ខ្ញុំនៅសំឡូត គាត់សួរខ្ញុំនៅសំឡូតហ្នឹង យួនចូលបានប៉ុន្មានខែហើយ ប៉ុន្មានឆ្នាំ? បាន ៩ខែ បើមិន៩ខែ ១ឆ្នាំហ្នឹងឯង នៅមួយវស្សា។ រត់ ប្រាំងឡើងរត់។ កុំប្រកាន់ណ៎ា ខ្ញុំភ្លេចខ្លះ ភ្លេចអាឆ្លើយពីមុនមកភ្លេចខ្លះហើយ កុំប្រកាន់ ខ្ញុំវង្វេងវង្វាន់ដែរណ៎ា។

**សៈ** មិនថ្វីទេលោកស្រី រឿងរ៉ាវនេះគឺថា៣៨ឆ្នាំមកហើយ យូរហើយ ប៉ុន្តែកាលណានិយាយពីការរៀបការនេះ ជាធម្មតាសាក្សីគាត់ចាំ។ លោកស្រីថាមានគូស្រករហ្នឹង៤០គូ ដែលគេរៀបការឲ្យហ្នឹង តើគូស្រករទាំង៤០គូហ្នឹង គេណែនាំឲ្យស្គាល់គ្នា ផ្គូរផ្គង ហើយណែនាំឲ្យស្គាល់គ្នាដោយរបៀបណាដែរក្នុងថ្ងៃតែមួយហ្នឹង?

[១០:៤៦:១២]

**ធៈ** ឲ្យអង្គុយ យុវជនមួយចំហៀង ប្រុសៗមួយចំហៀង ស្រីៗមួយចំហៀងអ៊ីចឹងឲ្យចាប់ឡើងចាប់ដៃគ្នា។ ហើយយើងឆ្លើយទៅប្ដេជ្ញាចិត្តទៅ ប្ដេជ្ញាចិត្តជូនអង្គការ យើងប្ដេជ្ញាចិត្តជូនអង្គការជូនវណ្ណៈ -- ជូនបក្សអ៊ីចឹងទៅណ៎ា។ អ៊ីចឹងទៅ ចាប់ដៃគ្នាទៅ។

**សៈ** តើត្រឹមត្រូវដែរឬទេ យោងទៅតាមស្តង់ដារ ឬក៏ហៅថារបៀបរបបរបស់គេពេលនោះ គឺថាលោកស្រីមានប្រវត្តិរូបល្អ គឺថាលោកស្រីអត់មានសមាជិកគ្រួសារជាទាហាន ជារដ្ឋការ លន់ នល់ លោកស្រីមិនមែនជា ធ្លាប់ជាមនុស្សម្នាក់នៅក្នុងគ្រួសារដែលមានជីវភាពធូរធារ។ ត្រឹមត្រូវទេថាពេលនោះលោកស្រីគឺថា លោកស្រីមានប្រវត្តិរូបល្អ?

**ធៈ** ចាស។ កាលហ្នឹងណ៎ា គេយកការមានប្រវត្តិរូបល្អ គូហ្នឹង គូជាមួយតាខ្ញុំ និងហើយខ្ញុំមាន

ប្រវត្តិរូបល្អ គេយកដាក់ជាមួយគ្នាទៅ ហើយត្រូវគ្នាទៅ។ ប៉ុន្តែទឹកចិត្តខ្ញុំនោះវា ទាំងសងខាង ទឹកចិត្តវាមិនពេញចិត្តទេ ប៉ុនដល់បានគ្នាទៅ ចេះតែសាមគ្គីគ្នាទៅ ធ្វើម៉េចគេការឲ្យ បើយើងរត់ទៅវាពិបាកដែរ ជំនាន់ហ្នឹងនោះ គេវៃចោលក៏មិនដឹងដែរ។ ខ្ញុំប្រាប់តាមត្រង់ តាមស្មោះត្រង់ហ្នឹងហ្មង។

**ស៖** ចុះខាងប្ដីនោះ ខាងបុរសទាំង៤០នាក់នោះ គាត់មកពីខាងណាដែរ?

**ឆ៖** គាត់មកចម្រុះគ្រប់។ តាំងពីតាកែវៗច្រើនតាកែវ។ តាកែវហើយនិងកំពត មកចម្រុះគ្នា។

**ស៖** តើបុរសទាំង៤០នាក់ហ្នឹង មកពីខាង -- មកពីកងពិសេសណាមួយដែរ?

[១០:៤៣:៣៥]

**ឆ៖** គាត់អ្នកពិការតាខ្មៅ។ គាត់បញ្ជូនពីភ្នំពេញទៅ។ សុទ្ធតែអ្នកពិការកំបុតដៃកំបុតជើង ខ្វាក់ភ្នែក គ្រួសារខ្ញុំខ្វាក់ ពិការភ្នែកម្ខាង។

**ស៖** តើប្ដីលោកស្រីហ្នឹងមានបញ្ហាជាមួយនឹងភ្នែកម្ខាងហ្នឹង គឺថាគាត់មិនអាចមើលឃើញទេ ឬ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីដើមបណ្ដឹងរដ្ឋប្បវេណីចាំឆ្លើយនៅពេលដែលមីក្រូហ្វូនដំណើរការមានភ្លើងក្រហម។

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** គ្រួសារខ្ញុំពិការភ្នែកម្ខាង ដល់ពាក់វ៉ែនតាម្ងួបបានមើលឃើញ បើអត់វ៉ែនតាម្ងួប ដើរដឹកដៃ។ គាត់មកដែរតើ ជូនខ្ញុំមកដែរហ្នឹង។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** បាទ សូមអរគុណ។ ចុះស្ត្រីទាំង៤០នាក់វិញ តើស្ត្រីទាំង៤០នាក់នេះ មកពីខាងណាដែរ? តើពួកគាត់មកពីកងណាមួយដែរ?

[១០:៥០:០២]

**ឆ៖** គាត់មកពីស្រែអំបិលដូចគ្នា។ នារីស្រែអំបិលដូចគ្នាហ្នឹង។ ការនៅហ្នឹង ការនៅសំឡូត។ ប៉ុន្តែរត់ពីរនាក់។ ក្មេងៗវាអត់ព្រមការ វារត់ចេញទៅ ហក់តាមបង្អួចជញ្ជាំងចេញទៅ។

**ស៖** ចុះតើក្មេងៗស្រីហ្នឹង គេមានយល់<>មិន<ឲ្យ>រៀបការដែរទេ ហើយបើសិនជាយល់ព្រម តើមូលហេតុអីបានគេយល់ព្រម?

**ឆ៖** ទាំងអស់ហ្នឹងឯង គាត់យល់ព្រម ព្រោះអីការអត់ដឹងទាំងអស់គ្នា ចេះតែថែរក្សាគ្នាទៅ យល់ព្រមទៅ ធ្វើម៉េចបានចាប់ការហើយ។ គាត់នៅពីរនាក់នោះ អត់អីទេ អាហ្នឹងអត់យករហូត។ អ៊ំគាត់ថា វានៅក្មេងៗពេក មិនបាច់ធ្វើអីវាទេ។

**ស៖** ចុះក្មេងស្រីពីរនាក់ដែលមិនចង់រៀបការហ្នឹង មានអាយុប៉ុន្មានឆ្នាំដែរ?

**ឆ៖** អាយុវាប្រាំមួយដណ្ដប់ ប្រាំមួយដណ្ដប់ឆ្នាំ គាត់អត់ឲ្យការទេ ការតែចាស់ៗបន្តិច គាត់ការឲ្យ ប៉ុនអាការហ្នឹង ក្នុងអស់ទាស់ហើយ អន់ចិត្តអស់ទាស់ហើយ។ ខឹងមាំណាស់។

**ស៖** និយាយថា "គាត់ខឹងមាំណាស់" ហ្នឹង គាត់ហ្នឹងអ្នកណាគេ?

**ឆ៖** ទាំងអស់គ្នាហ្នឹង ខឹងណាស់ ខឹងចាប់ការ។ និយាយតាមត្រង់ជាក់ស្ដែងតែម្ដង ខឹងចាប់ការ។ នារីទាំងអស់គ្នាហ្នឹង។

**ស៖** ក្មេងស្រីអាយុ១៦ឆ្នាំហ្នឹង គឺថាគេយកអនុគ្រោះ គឺថាដោយសារតែវានៅក្មេងៗពេកឬយ៉ាងម៉េច?

[១០:៥២:៤៤]

**ឆ៖** ចាស គាត់ថាវានៅក្មេងពេក វារត់ៗទៅ ឲ្យវាទៅកន្លែងចាស់ ដេកនៅពួនទៅ។ ឲ្យទៅនៅផ្ទះ កុំឲ្យវាទៅណា។ គាត់ថាអ៊ីចឹង។ វាមានទៅណាវា នៅផ្ទះ នៅកង នៅធ្វើធម្មតា។

**ស៖** នៅពេលដែលលោកស្រី និងអ្នកដទៃទៀតទៅពីភូមិភាគនិរតី គឺពីតាកែវហ្នឹង ពីខេត្តកណ្ដាល តើមានអ្វីកើតឡើងទៅដល់កម្មាភិបាលនៅភូមិភាគពាយ័ព្យហ្នឹង?

**ឆ៖** ខ្ញុំអត់ដឹងដែរ ព្រោះអីគាត់ចេះនាំគ្នាទៅ គាត់ចេះតែបញ្ជូនទៅ ចេះទៅហើយ អត់ដឹងទេ ខ្ញុំអត់ដឹងទេ។ បញ្ជូនទៅ ចេះទៅៗ ធ្វើកម្មាភិបាលហ្នឹងខ្លះទៅ ព្រោះអីមើលតាមភូមិតាមអីហ្នឹង។ បើកម្មាភិបាលពីមុនមកនៅហ្នឹង គាត់ថាកម្មាភិបាលហ្នឹងក្បត់។ អត់ឲ្យបាយប្រជាជនហូប។ គាត់ថាអ៊ីចឹង។ ហើយគាត់ប្រមូលពួកខ្ញុំទៅឲ្យថែរក្សាប្រជាជនបានតែប៉ុន្មាន មិនបាន១ឆ្នាំផង រត់ យួនចូលក៏រត់ទៅ។

[១០:៥៤:១៦]

**ស៖** អ្នកណាជាអ្នកដែលបានប្រាប់លោកស្រីថា កម្មាភិបាលចាស់នៅឯភូមិភាគពាយ័ព្យហ្នឹង គឺជាពួកក្បត់?

**ឆ៖** អ៊ំម៉ុក។ អ៊ំម៉ុក គាត់អ្នកប្រាប់ និយាយជាមួយពួកខ្ញុំ ប្រាប់។ កាលជំនាន់នោះ ខ្ញុំប្រាប់ទៅពូអីក៏មិនហ៊ាន ដាំដើមគក្នុងពោះ មិនហ៊ានទេ ខ្លាចគេធ្វើបាប។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើកម្មាភិបាលទាំងអស់នោះបាត់ខ្លួន ឬយ៉ាងណា?

**ឆ៖** គាត់ថា កម្មាភិបាលគេនៅយូរហើយហ្នឹងអ្ហែ? ខ្ញុំទៅ អត់ដែលឃើញគាត់ផង មិនដឹងគាត់ទៅណា ដឹងបាត់ខ្លួនអី បើអត់ដែលឃើញសោះ ឮតែគាត់ថាអ៊ីចឹង។ ហ្នឹងនិយាយឲ្យជាក់ស្តែង។

**ស៖** តាម៉ុក មានបានប្រាប់លោកស្រី ឬក៏ណែនាំលោកស្រីថា ត្រូវធ្វើយ៉ាងដូចម្តេចដែរឬទេ ចំពោះខ្មាំងដែលប្រឆាំងនឹងអង្គការ?

**ឆ៖** កុំឲ្យមានខ្មាំងចូល ចូលខ្មាចគិញ ដូចថាជំនាន់ហ្នឹងមានគិញមានអ៊ីចឹងណ៎ា។ មានខ្មាំងមានអី ចាំគុំក្លួនយើងអ៊ីចឹង គាត់ប្រាប់ដែរហ្នឹង។ គាត់ណែនាំថា ធ្វើម៉េចកុំឲ្យ ពេលយប់ព្រលប់ឲ្យល្បាសវែ កុំឲ្យដេកប្រមឹក ខ្លាចខ្មាំងចូល។

[១០:៥៦:១៦]

**ស៖** ខ្ញុំសូមអានទូវចម្លើយលោកស្រី ដែលលោកស្រីបានឆ្លើយជូនមន្ត្រីស៊ើបអង្កេតពីសាលាក្តីខ្មែរក្រហមយើងនេះ គឺឯកសារE3/9819 នៅត្រង់សំណួរចម្លើយលេខ៥៦។ នេះគឺអ្វីដែលលោកបាន លោកស្រីបានឆ្លើយថា “តាម៉ុក និងតាទិត្យ បាននិយាយអំពីស្ថានភាពខ្មាំង។ ពួកគាត់បានណែនាំយើងថា យើងត្រូវតែកម្ទេចខ្មាំងណាដែលប្រឆាំងនឹងអង្គការ។ ពួកគាត់មិនបាននិយាយថា អ្នកណាជាខ្មាំងនោះទេ ហើយក៏មិនបាននិយាយថា ត្រូវកម្ទេចខ្មាំងទាំងនោះតាមវិធីណាដែរ។ តាមខ្ញុំយល់ឃ្លាដែលថា ខ្មាំងណាដែលក្បត់នឹងយើង យើងត្រូវកម្ទេចចោល។ មានន័យថា ខ្មាំងនោះនឹងត្រូវសម្លាប់ចោលហើយ។” បញ្ចប់ការដកស្រង់។ តើលោកស្រីរកនឹកឃើញទេ តើតាទិត្យ និង តាម៉ុក បាននិយាយអំពីខ្មាំង ហើយនិងបានប្រាប់ទៅលោកស្រី ណែនាំទៅលោកស្រីថា ត្រូវតែកម្ទេចខ្មាំងទាំងនោះចោល?

**ឆ៖** ចាស គាត់បាននិយាយមែន ប៉ុនខ្ញុំភ្លេច។ ខ្ញុំវារង្វេងខ្លះហើយ ភ្លេចខ្លះហើយ។ គាត់បាននិយាយមែន គាត់ ម៉ុក និង ទិត្យ ហ្នឹង គាត់ថា ណែនាំដូចខាងលើអ៊ីចឹង។ ណែនាំខ្មាំង វាយកម្ទេចខ្មាំង បើមានខ្មាំងណា ប្រហែលជាក្បត់អីមកនៅជាមួយយើងអ៊ីចឹងទៅ សម្លាប់យើងចោលអស់ទៅ។ ហ្នឹងអ៊ីចឹង។ ហ្នឹងសភាពថា បើមានខ្មាំងចូលក្នុងអង្គភាពយើងហ្នឹង សម្លាប់យើងចោលអស់ក៏មិនដឹង យើងងាប់បាត់អស់ហើយ។ ហ្នឹងគាត់ឲ្យតាមដានអ៊ីចឹងណ៎ា។ ហ្នឹង អ៊ំម៉ុក និង អ៊ំទិត្យ គាត់និយាយអ៊ីចឹង។

[១០:៥៨:០៣]

**ស៖** លោកស្រីនិយាយថា បានទៅនៅសំឡូតប្រហែលមួយឆ្នាំ មុនវៀតណាមចូលមក។ តើមុនពេលហ្នឹង តើមានការវាយប្រយុទ្ធគ្នាដែរឬទេនៅសំឡូត ដែលនៅក្នុងភូមិភាគពាយ័ព្យកាលនោះ?

**ឆ៖** ខ្ញុំនៅនោះ អត់មានរើគ្នាផង។ មានតែ៧៩ រត់។ រត់ទៅថៃទាំងអស់គ្នា។ ចេះតែរត់ទៅៗៗទៅ មិនដឹងដល់ណាដល់ណើ ចេះតែរត់ទៅ ៧៩ហ្នឹង ៧៩។ ហ្នឹង ខ្ញុំឆ្លើយតាមត្រង់។

**ស៖** នៅពេលដែលលោកស្រីទៅដល់សំឡូតដំបូង តើអ្នកណាជាប្រធានភូមិភាគ ជាលេខាភូមិភាគ?

**ឆ៖** លេខាភូមិភាគ ខ្ញុំអត់បានដឹងដែរហ្នឹង ដឹងតែ ភូមិភាគដឹងតែអ៊ំហ្នឹង គាត់នាំមក។ ដឹងតែថា គាត់ហ្នឹងហើយ។ ភូមិភាគហ្នឹង មានអ៊ំម៉ុក ហ្នឹងហើយ។ ខ្ញុំដឹង អ៊ំម៉ុក គាត់មកពីភូមិភាគ គាត់មកស្រែអំបិលមក នាំពួកខ្ញុំមក។

**ស៖** តើលោកស្រីធ្លាប់ឮអ្នកណានិយាយពី រស់ ញឹម ដែរទេ?

**ឆ៖** រស់ ញឹម ធ្លាប់ឮនិយាយតៗគ្នាដែរ ប៉ុន្តែខ្ញុំមិនព្យាយាមស្តាប់ផង។ ឮសូរតែនិយាយដែរហ្នឹង ឮសូរ ប៉ុន្តែអត់ដែលស្គាល់មុខគាត់។ ស្គាល់ឈ្មោះ អត់ដែលស្គាល់មុខ ឮសូរតែឈ្មោះ។

[១០:៥៩:៥៥]

**ស៖** នៅពេលដែលកម្មាភិបាលពីភូមិភាគនិរតី រួមទាំងលោកស្រីផងដែរទៅពាយ័ព្យ តើកាលនោះ <លោកស្រីរាយការណ៍ទៅ> តាម៉ុក ឬក៏របស់ រស់ ញឹម?

**ឆ៖** អត់ទេដែល តាម៉ុក មក អត់មានដែលឃើញ រស់ ញឹម ហ្នឹងផង។ ឮតែគាត់ថា ឮតែគេថាគ្រប់គ្នា ថារស់ ញឹម ហ្នឹងនៅកន្លែងស្រុកដែរ ក៏អត់ដែលស្គាល់សុទ្ធ ឮសូរតែឈ្មោះ។ ចេះនិយាយតៗគ្នាទៅ។

**ស៖** ខ្ញុំត្រឡប់ថយក្រោយបន្តិច ឈ្មោះ ឡេង ជាលេខាស្រុក។ តើគេបង្ខំគាត់ឲ្យរៀបការ <ជាមួយយោធាពិការ>ដែរឬទេ នៅក្នុងគូស្រករដែលមានគ្នា៤០គូហ្នឹង?

**ឆ៖** បងឡេង គេបង្ខំតើ។ អ៊ំម៉ុក ហ្នឹងអ្នកបង្ខំ។ បងឡេង ឯងអ្នកដឹកនាំគេ ការទៅ ការឲ្យហើយៗទៅ។ ខ្ញុំអីការឲ្យហើយៗទៅ ហើយដល់នេះហៅគ្នាមក៤០គូហ្នឹងការ តែបីបួនម៉ោងហ្នឹងហើយបាត់។ អត់បាយឡើងពីរបីថ្ងៃ ការហើយអត់ គេមាននាំគ្នាហូបបាយឯណា ខឹងពេក។ គេបង្ខំគាត់ដែរហ្នឹងណា បង្ខំៗមែនទែន។ បើគាត់ មិនអ្នកណាស្រឡាញ់ គ្មានអ្នកណាស្រឡាញ់អ្នកណាទេ អត់ទេជំនាន់ហ្នឹង។ បង្ខំ គេបង្ខំតែម្តង។

[១១:០១:៣៣]

**ស៖** អ៊ីចឹងគេក៏បានបង្ខំ ឡេង ឲ្យរៀបការជាមួយយោធាពិការដែរ។ តើអ៊ីចឹង ឬដូចម្តេច?

**ឆ៖** គេបង្ខំឲ្យគាត់រៀបការដែរ គាត់អត់មាត់ទេ ចេះតែការទៅ ទាំងគេទាំងខ្ញុំ ចេះតែទៅៗ ក្រុមគេចាត់តាំងហើយ។

**ស៖** នៅពេលដែលលោកស្រីទៅដល់ភូមិភាគពាយ័ព្យ តើផលស្រូវដែលប្រមូលបានហ្នឹង គេតម្រូវឲ្យបញ្ជូនទៅមជ្ឈិមដែរឬទេ?<តើលោកស្រីដឹងទេថាមានការតម្រូវឲ្យបញ្ជូនស្រូវទៅមជ្ឈិមទេ?>

**ឆ៖** គេធ្វើនៅពាយ័ព្យហ្នឹងហើយ អ៊ំ។ ធ្វើនៅពាយ័ព្យហ្នឹង ខ្ញុំអត់បានដឹងដែរហ្នឹងណា ធ្វើដឹងគេយកទៅណាទៅណី ចេះតែធ្វើៗទៅ យកទៅណាទៅណី ធ្វើចម្ការធ្វើស្រូវហ្នឹង។

**ស៖** តើលោកស្រីដឹងថា គេបញ្ជូនស្រូវតាមរទេះភ្លើងពីបាត់ដំបងមកភ្នំពេញដែរឬទេ?

**ឆ៖** អត់ដឹងផង។

**ស៖** តើលោកស្រីបានទទួលការណែនាំថា ត្រូវបង្កបង្កើនផលស្រូវ ១ហិកតា ឲ្យបានប៉ុនណា? ហើយបានផលត្រូវបញ្ជូនប៉ុនណា ទៅណាដែរឬទេ?

**ឆ៖** បង្កើតផលបានអ៊ីចឹងទៅ ទុកហូបខ្លះ ហើយបញ្ជូនមកទៀត ខ្ញុំអត់ដឹងបញ្ជូនមកណា ដឹកមក។ ដឹកចែកតាមគ្នាឯង ហូបគ្នាឯងតាមសហករណ៍ដឹងមិនស្រួល ក៏ខ្ញុំអត់ដឹងដែរ។

[១១:០៣:៣៨]

**ស៖** តាមដែលលោកស្រីដឹង ថាតើកម្មាភិបាលមួយចំនួនណាដែលថា ដោយសារតែបញ្ជូនស្រូវមកថ្នាក់លើធ្វើឲ្យប្រជាជនមូលដ្ឋាន អត់ ដាច់ពោះស្លាប់ដែរឬទេ?

**ឆ៖** ខ្ញុំនៅស្រុកសំឡូត អត់ គាត់អត់មានអត់បាយផង ព្រោះអីពួកខ្ញុំគ្រប់គ្រងគាត់ ឲ្យហូបបាយឆ្អែតៗ ហើយគាត់ជួយធ្វើទាំងអស់គ្នា ធ្វើតាមសហករណ៍ សាមគ្គីគ្នាទាំងអស់គ្នា ហូបបានឆ្អែតៗរហូត។ ចួនណាក៏យើងខ្វះខាត ក៏ហូបបាយលាយពោតអ៊ីចឹងទៅ។ មិនបានគ្រប់គ្រាន់ទាំងអស់ទេ។

**ស៖** ខ្ញុំសួរពីចំណុចដែលលោកស្រីឆ្លើយទៅ ឡុង ដានី។ ខ្មែរ ERN 00733838, អង់គ្លេស 01155611។ ខ្ញុំចង់ឲ្យលោកស្រីស្ដាប់ ហើយគេកត់ត្រាពីអ្វីដែលលោកស្រីនិយាយ។ លោកស្រីបាននិយាយពីបញ្ហាកម្មាភិបាលថ្នាក់ក្រោម៖ នៅពេលដែលគេចង់លើកខ្លួនរបស់គេ គឺគេបន្ថយរបបអាហារ<ឲ្យប្រជាជនហូបបបរ។> រីឯស្រូវអង្ករ<នៅសល់។> ហើយ ដានី សួរថា តើស្រូវដែលគេយកហ្នឹងយកទៅណា ដែលសេសសល់ហ្នឹង? ហើយលោកស្រីនិយាយថា គេបញ្ជូនស្រូវអង្ករទៅថ្នាក់លើ ហើយទុកឲ្យប្រជាជនអត់អាហារ។ អ៊ីចឹង តើលោកស្រីដឹងដែរឬទេគឺថា មូលហេតុដែលនាំឲ្យប្រជាជនអត់អាហារហ្នឹង គឺដោយសារគេបញ្ជូនស្រូវ អង្ករទៅថ្នាក់លើ?

**ឆ៖** ចាស នេះបញ្ជូនធ្វើទៅ ទុកឲ្យប្រជាជនហូបខ្លះអីខ្លះអ៊ីចឹង បញ្ជូនទៅថ្នាក់លើ ប៉ុន្តែទៅថ្នាក់លើត្រឹមណា ខ្ញុំអត់បានយល់ដែរ។ ខ្ញុំវាយការណ៍ទៅវាមានខុសឆ្គងកុំប្រកាន់ ព្រោះអីយូរហើយ។

[១១:០៥:៥៣]

**សៈ** តើលោកស្រីបានចូលវគ្គសិក្សា រៀនសូត្រណាមួយនៅភ្នំពេញដែរឬទេ?

**ឆ៖** ខ្ញុំអត់ដែលទេនៅភ្នំពេញហ្នឹង ខ្ញុំអត់ដែល ខ្ញុំអត់ដែលសោះ។

**សៈ** តើលោកស្រីធ្លាប់បានឃើញលោក ខៀវ សំផន ឬ នួន ជា <ទៅទស្សនកិច្ចនៅពាយ័ព្យ> ដែរទេ? <>

**ឆ៖** ពេលហ្នឹង ខ្ញុំឮសូរតែឈ្មោះទេ ខ្ញុំអត់ស្គាល់ទេ ខៀវ សំផន អីអត់ស្គាល់សោះ ឮសូរតែឈ្មោះ។ ព្រោះអីខ្ញុំវាទើបប៉ុណ្ណឹង ទើបថ្នាក់ប៉ុណ្ណឹង យើងទៅស្គាល់គេអី គេមិនឲ្យយើងស្គាល់ទេ គេប្រើយើងពលកម្មហ្នឹងហើយ។ ខ្ញុំអត់ស្គាល់ទេ ឮតែឈ្មោះ។

**សៈ** អ៊ីចឹងសំណួរមួយដែលខ្ញុំភ្លេចពីចំណុចមួយ។ នៅក្នុងពិធីគេរៀបការ ដែលមាន៣៨គូ តើអ្នកណាវត្តមានធ្វើជាធិបតី តាម៉ុក ឬក៏ តាទិត្យ នៅពេលដែលគេរៀបការនោះ?

**ឆ៖** កាលហ្នឹង អ៊ំម៉ុកៗ អ្នកចាប់រៀបការតែម្តង។ ហើយការបានពីរបីថ្ងៃបាន អ៊ំទិត្យ គាត់មកគាត់មកសួរណែនាំអ៊ីចឹងទៅណា គាត់មកសួរនាំអ៊ីចឹងមានអាណារត់ចោលគ្នាអ៊ីចឹងទៅណ៎ា។ ហើយអត់មានណារត់ចោលអ៊ីចឹងក៏គាត់ចេះតែណែនាំទៅអ៊ីចឹង ណែនាំឲ្យធ្វើល្អកុំឲ្យធ្វើអាក្រក់អ៊ីចឹងទៅណ៎ា។

[១១:០៧:៤៥]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណច្រើនលោកស្រីសាក្សី ខ្ញុំមិនមានសំណួរអ្វីទៀតទេ លោកប្រធានបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកព្រះរាជអាជ្ញា។ សូមអញ្ជើញលោកមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណីមានសំណួរលើសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរទៅលោកស្រី។ ជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ ម៉ារី ហ្គីរ៉ូដ៍។ ខ្ញុំជាមេធាវីតំណាងឲ្យក្រុមដើមបណ្ដឹងរដ្ឋប្បវេណីដែលបានដាក់ពាក្យសុំតាំងខ្លួននៅក្នុងសំណុំរឿងនេះ។ ខ្ញុំមានសំណួរមួយចំនួនពាក់ព័ន្ធនឹងការរៀបការនៅក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ លោកស្រីទើបតែនិយាយថា តាម៉ុក មានវត្តមានក្នុងពេលដែលលោកស្រីរៀបការ។ តើពេលនុំងក្នុងពិធីរៀបការហ្នឹង គាត់មានតួនាទីអីដែរ? ហើយគាត់មានឡើងនិយាយអ្វីក្នុងពេលរៀបការរបស់លោកស្រីហ្នឹងទេ? លោកស្រីមាននៅនឹកឃើញអ្វីខ្លះពេលដែលលោកស្រីរៀបការនុំង តើ តាម៉ុក គាត់ធ្វើអ្វីខ្លះក្នុងពិធីនោះ?

[១១:០៩:០៥]

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** គាត់យកពួកខ្ញុំរៀបការ គាត់ណែនាំ ហើយក៏គាត់អត់មានខ្ញុំ -- ខ្ញុំដឹងតែគាត់ទៅពីតាកែវទៅ ដឹងតែគាត់ភូមិភាគពាយ័ព្យហ្នឹងហើយ។ គាត់ណែនាំឲ្យបានត្រូវគ្នាកុំឲ្យខុសគ្នាអ៊ីចឹង ណែនាំអ៊ីចឹង។

**ស៖** ការណែនាំឲ្យស្រុះស្រួលគ្នាត្រូវគ្នាហ្នឹង តើគេនិយាយនៅថ្ងៃរៀបការ ឬក៏មុនពេលរៀបការ ឬក៏ក្រោយពេលរៀបការ?

**ឆ៖** និយាយថ្ងៃការហ្នឹងហ្មង ការហើយគាត់ឃាត់ឲ្យគ្នានៅទាំងអស់គ្នា គាត់ណែនាំអ៊ីចឹង។ អាហ្នឹងអ៊ីចឹងខ្ញុំមិនដឹងតែត្រឹមហ្នឹង។

**ស៖** ពេលដែលលោកស្រីឆ្លើយថាគេណែនាំឲ្យត្រូវគ្នា កុំឲ្យឈ្លោះគ្នា។ អ៊ីចឹង តើ<ចំណុច>ហ្នឹង<វា>តម្រូវឲ្យ<លោកស្រីថា លោកស្រីត្រូវតែ>រួមដំណេកជាមួយនឹងប្ដីលោកស្រីហ្នឹងទេ?

**ឆ៖** កាលជំនាន់ហ្នឹងគេតាមដានដែរហ្នឹង តែយើងរាងនេះគេៗចេះតែឲ្យកងឈ្លបគេតាមដានដែរហ្នឹង តាមដានយើង ប៉ុនយើងអត់មានសភាពអីក៏សុខសប្បាយទៅ។

**ស៖** ខ្ញុំអត់ទទួលបានការបកប្រែនៅផ្នែកចុងក្រោយនៃចម្លើយអម្បាញ់មិញទេលោកប្រធាន។ អ៊ីចឹងខ្ញុំសូមសួរឡើងវិញ។ ពេលដែលលោកនិយាយថាគេតាមដានលោកស្រីហ្នឹង តើលោកស្រីអាចពន្យល់បានទេថា គេតាមដានហ្នឹងតាមដានពេលណា? ពេលយប់ថ្ងៃការហ្នឹង ឬក៏យប់ក្រោយៗមកទៀត? សូមលោកស្រីរៀបរាប់បន្តិចអំពីថា ពេលដែលលោកស្រីនិយាយថាគេតាមដានហ្នឹង?

**ឆ៖** គឺការហើយបានពីរបីយប់ គឺចេះតែតាមដានដែរ។ ការបានហើយ២យប់ ៣យប់ហ្នឹងណ៎ាគេតាមដានយើងហើយ ហើយអត់ៗមានអីក៏សុខស្រួលគ្នាទៅ ក៏អត់មានបញ្ហាអីទៅ។

[១១:១២:២៥]

**ស៖** លោកស្រីអាចរៀបរាប់អំពីការរួមរស់ជាមួយប្ដីលោកស្រីបានក្រោយពីរៀបការបានទេ?

**ឆ៖** ការហើយ ឬក៏មុនការ? ចង់សួរថាអ៊ីចេះ! ការហើយក៏ខ្ញុំអត់មានអីទេ ចេះតែទ្រាំយកគ្នាទៅធ្វើម៉េចទេអង្គការការឱ្យហើយ គេជំនាន់គេហៅអង្គការហើយចុះ។ អង្គការការឱ្យចេះតែទ្រាំយកទៅ បានគ្នាបានជាកូន បានជាចៅហើយ។

**ស៖** មុនពេលលោកស្រីរៀបការ តើលោកស្រីធ្លាប់ឮគេនិយាយថា ពេលរៀបការហ្នឹងត្រូវតែបង្កើតកូន។ ខ្ញុំចង់សួរបញ្ជាក់ថាមុនពេលដែលលោករៀបការហ្នឹង លោកស្រីធ្លាប់ឮគេនិយាយអ៊ីចឹងទេ?

**ឆ៖** ដូចធ្លាប់ និយាយយ៉ាងម៉េច? កាលហ្នឹងដូចរាងឆោតៗដែរហ្នឹង នៅវ័យក្មេងមិនដឹងអីទេ។ មិនចង់យកចង់តែរត់ចោលទេ តែធ្វើម៉េចចេះតែទ្រាំទៅ។ ខ្ញុំនិយាយដូចដដែលៗ។

**ស៖** ខ្ញុំយល់<>ចម្លើយលោកស្រីច្បាស់ណាស់លោកស្រីនិយាយមកនោះ។ អ៊ីចឹងប្រហែលជាលោកស្រីមិនយល់សំណួរខ្ញុំមើលទៅ។ ខ្ញុំសួរថាមុនពេលរៀបការណ៎ា <ឬក៏នៅថ្ងៃរៀបការនោះ> តើមានកម្មាភិបាលណា<ប្រាប់លោកស្រី>ថា លោកស្រីការហ្នឹង គឺដើម្បីបង្កើតកូនជូនអង្គការ។ លោកស្រីធ្លាប់ឮពាក្យហ្នឹងមុនពេលលោកស្រីរៀបការ ឬក្នុងពេលលោកស្រីរៀបការទេ មានអ្នកណាម្នាក់ប្រាប់លោកស្រីថាការហ្នឹងគឺដើម្បីបង្កើតកូនជូនទៅអង្គការ?

[១១:១៤:៣៦]

**ឆ៖** អាហ្នឹងចេះតែព្រោកគ្នាសើចទៅហ្នឹងណ៎ា។ ព្រោកគ្នាកើតដែរ "អ៊ូ! អង្គការការឱ្យអ៊ីចឹងតែកូន កើតមក បញ្ជូនទៅឱ្យអង្គការហើយ" អ៊ីចេះ អ៊ីចឹងទេ។

**ស៖** ដូច្នេះ<អ្វីដែលលោកស្រីនិយាយថា ជាការចាំបាច់ក្នុងការបង្កើតកូនជូនអង្គការ តើនេះជាអ្វីដែល>លោកស្រីធ្លាប់ឮកម្មាភិបាល ឧទាហរណ៍ដូច តាម៉ុក ជាដើមនេះ គាត់និយាយថា ឱ្យការហ្នឹងដើម្បីកើតកូនហ្នឹង លោកស្រីឮពីកម្មាភិបាលណាមួយ ឬក៏លោកស្រីយល់ឃើញដោយខ្លួនឯងទេ?

**ឆ៖** យល់ឃើញតែខ្លួនឯង ចេះតែព្រោកគ្នាទៅហ្នឹងណ៎ា ព្រោកគ្នាៗហ្នឹងណ៎ា។ ខ្ញុំអត់មានសម្ភាសថាអ៊ីចឹងផង ចេះតែព្រោកគ្នាទៅ។

**លោកស្រី ម៉ារី ហ្គីរ៉ូដ៖**

សូមអរគុណលោកស្រីសាក្សី។

លោកប្រធានខ្ញុំអស់សំណួរហើយ។ សុំអនុញ្ញាតប្រគល់វេទិកានេះជូនសហភាគីខ្ញុំ គឺមេធាវី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ពេជ អង្គ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម ភាគី។ សុំជម្រាបសួរលោកស្រីដើមបណ្ដឹងរដ្ឋប្បវេណី។ ខ្ញុំមានសំណួរបញ្ជាក់បន្ថែមបន្ថែមបន្តិចសម្រាប់លោកស្រីសាក្សី។ ខ្ញុំចង់សុំសួរលោកស្រីនៅពេលដែលលោកស្រីនៅកំពត តើពេលនោះលោកស្រីមានតួនាទីអ្វីដែរ? ខ្ញុំប្រហែលជាពីមុនខ្ញុំមិនបានស្ដាប់ឲ្យបានស្ដាប់ឲ្យបានច្បាស់លាស់ អ៊ីចឹងសុំសួរបញ្ជាក់ពីបញ្ហាហ្នឹងបន្តិច។

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** កាលខ្ញុំស្រែអំបិល គឺគេចាត់តាំងឲ្យធ្វើប្រធានហា កងហា។

[១១:១៧:០៤]

**ស៖** បាទ អរគុណ លោកស្រីបានបញ្ជាក់បញ្ហាហ្នឹងម្ដងហើយ។ ខ្ញុំនឹកឃើញវិញហើយ។ លោកស្រីអាចបញ្ជាក់បានទេ នៅពេលនោះមាននៅក្នុងកន្លែងលោកស្រីធ្វើការហ្នឹង ឬក៏សហករណ៍ដែលលោកស្រីធ្វើការហ្នឹង មានការរៀបការដែរឬទេ?

**ឆ៖** គឺអត់ រៀបការតែម្ដងហ្នឹង។ តាមប្រជាជនអ្នេស? ប្រជាជនគាត់រៀបការតើ។ ខ្ញុំនៅជាមួយប្រជាជនតាមសហករណ៍ហ្នឹង គាត់រៀបការតើ។

**ស៖** បាទ អរគុណលោកស្រី។ លោកស្រីមានធ្លាប់ចូលរួមនៅក្នុងការរៀបការរបស់ប្រជាជននាពេលនោះទេ?

**ឆ៖** ប៉ុន្តែការជំនាន់ហ្នឹង វាស្រឡាញ់គ្នា បានយើងការឲ្យ បានអ្នកនៅហ្នឹងការឲ្យ កូនប្រជាជនណ៎ះ! ការឲ្យ អត់មានបង្ខំដូចយើងនៅអង្គភាពទេ។

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់សួរបញ្ជាក់បន្ថែមបន្តិច។ ពេលដែលលោកស្រីរៀបការនៅសំឡូត លោកស្រីអម្បាញ់មិញបញ្ជាក់ថា តាម៉ុក ជាអ្នកឲ្យរៀបការ។ លោកស្រីមានបានចាំទេ តាម៉ុកបានបញ្ជាឲ្យអ្នកណាជាអ្នករៀបចំកម្មវិធីរៀបការហ្នឹង?

**ឆ៖** ខ្ញុំបញ្ជាក់ហើយបញ្ជាក់ទៀត ថាតាម៉ុក ហ្នឹងតែម្ដង ហៅៗទៅការតែម្ដង។ គាត់នៅហៅការ ហៅចាប់ដៃ ហៅអី គាត់តាម៉ុក ថាតាម៉ុក ហ្នឹងតែម្ដង បើ តាម៉ុក មកហ្នឹងហើយ។ គាត់ការ

ឲ្យយើង គាត់ឲ្យចាប់ដៃគាត់ ភ្នែកគាត់និយាយណែនាំអ៊ីចឹង។ តាម៉ុក មានណា៎! ថ្ងៃហ្នឹង តាម៉ុក មកហ្នឹង។ ចាស តាម៉ុក ហ្នឹងតែម្ដង។

[១១:១៨:០៣]

**ស៖** មុនថ្ងៃរៀបការហ្នឹង លោកស្រីមានដឹងអំពីថា លោកស្រីត្រូវទៅរៀបការជាមុនទេ?

**ឆ៖** គឺថ្ងៃរៀបការហ្នឹង គឺពួកខ្ញុំអត់មានដឹងទាំងអស់ ខាងយុទ្ធជនក៏អត់ដឹងដែរ ខាងបុរសក៏អត់ដឹង ខាងនារីក៏អត់ដឹងដែរ អត់សោះ។ ចាប់យកមកដល់ ផ្ទុចនឹងតែម្ដង។ ស្មានតែមក យកយុទ្ធជនមកបានតែមួយយប់ -- អ៎! ពីរយប់ ចាប់ការហ្នឹងតែម្ដង ពីរបីយប់ហ្នឹង។

**ស៖** អ៊ីចឹង លោកស្រីអាចបញ្ជាក់ច្បាស់លាស់បានទេ នៅពេលណានៅពេលដែលលោកស្រីដឹងថា គេហៅលោកស្រីមកដើម្បីរៀបការ? នៅពេលណា? នៅពេលភ្លាមៗថ្ងៃ ឬក៏ម៉ោងដែលត្រូវរៀបការតែម្ដង ឬក៏ថាលោកស្រីដឹងមុនប៉ុន្មានម៉ោងជាមុន?

**ឆ៖** ខ្ញុំនៅឯក្រោមនេះ ខ្ញុំអត់ដឹង អត់ដឹង ដល់តែគាត់ -- ខ្ញុំចេះតែឆ្ងល់ គាត់ថា មុនដំបូងហៅយកទៅប្រជុំ។ ប្រជុំស្អី ដល់អត់ដឹង ខ្ញុំអត់ទៅ។ អត់ទៅ គាត់ -- គេចេះតែថាទៅៗ ប្រយ័ត្នអ៊ំខឹង។ អើ ទៅ មានដឹងឯណា មានដឹងថាយកមករៀបការឯណា។

**ស៖** អ្នកណាដែលជម្រាបលោកស្រីថា ទៅប្រជុំទៅ? អ្នកណាគេអ្នកជម្រាបលោកស្រី?

**ឆ៖** គ្នាឯង ក្មេងៗគ្នាឯងហ្នឹង គិតតែព្រោកគ្នាទៅណា៎។ “ទៅ គេប្រជុំហើយនោះ ទៅ” តែមិនប្រជុំ ទៅការ។ អ៊ីចេះ។

[១១:២០:៤៥]

**ស៖** ពួកគាត់មានតួនាទីអីទេ លោកស្រី? គ្នាឯងដែលលោកស្រីបញ្ជាក់អម្បាញ់មិញ ដែលជាអ្នកហៅលោកស្រីទៅកន្លែងប្រជុំហ្នឹង គាត់មានតួនាទីអីទេ?

**ឆ៖** អត់ៗមាន មហាជនសុទ្ធសាធ ក្មេងៗ។

**ស៖** ចុះលោកស្រី មានដឹងអ្នកដទៃទៀត ក្រៅពីលោកស្រីទេ ថាតើពួកគាត់ស្ថិតនៅក្នុងៗស្ថានភាពដូចគ្នាដែរឬទេ ពេលដែលគាត់ទៅដល់ បានគាត់ដឹងថាគេឲ្យមករៀបការ? តើស្ថានភាពដូចគ្នាដែរឬទេ?

**ឆ៖** អត់ដឹងដូចគ្នា ព្រោះអីមកដល់ចាប់ការៗ ណាខាង ទាំងអស់ អត់ដឹងទាំងអស់ ៣៩គូហ្នឹង អត់ដឹងទាំងអស់។

**សៈ** ហើយពេលដែលលោកស្រីមកដល់ លោកស្រីមានដឹងថា អ្នកណាគេជាអ្នកដឹកនាំកម្មវិធីនុំងផ្ទាល់ទេ ក្រៅពី តាម៉ុក មានអ្នកណាជាអ្នករៀបចំផ្សេងទៀតទេ កម្មវិធីហ្នឹង?

**ឆៈ** គាត់អ្នករៀបការមួយភ្លែតឲ្យហ្នឹងតែម្តង ការហ្នឹងតែម្តង។ គាត់មកហ្នឹង មានអ្នកណាក្រៅពីគាត់ តែគាត់ហ្នឹង។

**សៈ** លោកស្រីមានស្គាល់ តាម៉ុក ពីមុនដែរទេ?

[១១:២២:១០]

**ឆៈ** ស្គាល់ៗតើ ខ្ញុំស្គាល់គាត់តើ ពីមុនមក។

**សៈ** ក្នុងពេលនោះ គេមានឲ្យលោកស្រីប្តេជ្ញាចិត្ត ឬក៏និយាយអ្វីដែរឬទេ? ទាំងលោកស្រីហើយនិងគូរបស់លោកស្រី ឬក៏ថាគូផ្សេងៗទៀត គេមានប្តេជ្ញាចិត្តថាយ៉ាងដូចម្តេចទេ?

**ឆៈ** ប្តេជ្ញាចិត្តទាំងអស់គ្នា ឡើងម្តងមួយៗ។ ប្តេជ្ញាចិត្ត គឺអង្គការរៀបចំអាពាហ៍ពិពាហ៍ឲ្យហើយ គឺត្រូវតែដាច់ខាត ត្រូវតែប្តេជ្ញា គោរពអង្គការចាត់តាំង។ អ៊ីចឹង ហ្នឹងម្នាក់ៗថាអ៊ីចឹងឯង។

**សៈ** បាទ អរគុណលោកស្រី។ នៅពេលនោះ លោកស្រីមាន ខ្ញុំចង់និយាយអំពីសម្លៀកបំពាក់របស់លោកស្រី លោកស្រីស្លៀកពាក់ជាធម្មតា ជាសម្លៀកមកៗប្រជុំ ឬក៏ថាគេមានឲ្យដូរសម្លៀកអីទេ?

**ឆៈ** សម្លៀកបំពាក់អត់ទេ គឺខោខ្មៅ អាវខ្មៅ អាវដៃវែង មានអីសម្លៀកបំពាក់អីល្អ អត់ទេ។ ដូចៗតែគ្នាហ្នឹង ប្រុសក៏អ៊ីចឹង ស្រីក៏អ៊ីចឹងដែរ។ ខោខ្មៅ អាវខ្មៅហ្នឹង។

**សៈ** កម្មវិធីហ្នឹង មានធ្វើតាមប្រពៃណីខ្មែរ ដែលលោកស្រីធ្លាប់ស្គាល់ពីមុនៗដែរទេ? មានចាស់ទុំ មានសាច់ញាតិចូលរួមអីដែរទេ?

**ឆៈ** គឺបញ្ហាហ្នឹង គឺអត់។ មួយណាក៏អត់មានបងប្អូន អត់មានម៉ែឪ មានតែញាតិអ្នកស្គាល់គ្នាទៅធ្វើនារី កងនារីស្រែអំបិលជាមួយគ្នាហ្នឹង តែគ្នាឯងៗហ្នឹង។ មានបងប្អូនឯណា អត់ផង មានតែគ្នាឯងហ្នឹងឯង។

[១១:២៤:១៤]

**សៈ** បាទ។ ចំណែកឯខាងកូនកំលោះទាំង៣៩ ឬក៏៤០គូដែលលោកស្រីមានប្រសាសន៍នុំង ថាតើពួកគាត់មកពីណាខ្លះ? ហើយបើចំពោះអ្នកពិការហ្នឹង គេពិការនៅសមរភូមិណាខ្លះ លោកស្រីដឹងទេ?

**ឆៈ** សុំបញ្ជាក់ គឺអ្នកពិការហ្នឹង គឺខ្ញុំអត់ដឹងដែរ ដឹងនៅឯណា អីឯណា គឺដឹងនៅតាកែវខ្លះអ៊ីចឹងទៅ ប្អូនដប់ -- ប្អូនប្រាំនាក់អ៊ីចឹងទៅ ខាងស្រីក៏នៅតាកែវខ្លះអ៊ីចឹងទៅ ព្រោះអីខ្ញុំនៅតាកែវដែរ។ ហើយ

នៅឯណា ពិការសមរភូមិណា សមរភូមិណា ខ្ញុំអត់បានដឹងដែរ។

**ស៖** នៅពេលដែលលោកស្រី អម្បាញ់មិញលោកស្រីមានប្រសាសន៍ថា មកដល់ភ្លាមគឺគេឲ្យការភ្លាម បានដឹងភ្លាមតែម្តង ហើយការនោះមិនតាមប្រពៃណី ឬក៏ថាមិនមានសាច់ញាតិចូលរួមទេ ហើយជាពេលដែលលោកស្រីមានគ្រួសារ។ អ៊ីចឹងលោកស្រីមានអារម្មណ៍យ៉ាងដូចម្តេចដែរនៅពេលនោះ ដែលគេឲ្យការភ្លាមៗអ៊ីចឹង ហើយគ្មានការចូលរួមពីគ្រួសារ ហើយមិនប្រព្រឹត្តទៅតាមប្រពៃណី?

[១១:២៥:៤៤]

**ឆ៖** គឺខ្ញុំ អត់មានអារម្មណ៍អី នឹកឃើញអារម្មណ៍ថាអន់ចិត្ត ថាគាត់ការឲ្យហ្នឹងតែម្តង អត់មានបងប្អូន អើជំនាន់ហ្នឹងយើងជ្រះស្រឡះ។ អត់មានអារម្មណ៍ថា ចង់បានម៉ែឪ បងប្អូនអីអត់ទេ គឺវាទូទៅទាំងអ៊ីចឹងហើយ ទាំងអស់គ្នាអ៊ីចឹងហើយ។

**ស៖** បាទ អរគុណ ខ្ញុំចង់សួរសំណួរចុងក្រោយ។ លោកស្រីមានដែលនិយាយអំពីការដែលថា លោកស្រីត្រូវបានគេផ្សំផ្គុំឲ្យរៀបការក្នុងសម័យខ្មែរក្រហម ប្រាប់ទៅដល់កូនចៅរបស់លោកស្រីដែរឬទេ?

**ឆ៖** គឺខ្ញុំ ហើយពិបាកណាស់! មាន យើងម៉េចហ៊ានទៅប្រាប់ ម៉ែឪក៏អត់ដឹង បងប្អូនក៏អត់ដឹង អត់ដឹងខ្ញុំមានគ្រួសារផងហ្នឹង។ ទាំងអស់គ្នាមានអ្នកណាដឹង អត់។ មានម៉ែឪឯណាដឹងអត់រលីង។

**ស៖** ខ្ញុំៗចង់និយាយថានៅពេលក្រោយៗមកទៀត នៅពេលដែលកូនចៅលោកស្រីធំៗហើយ កូនរបស់លោកស្រីធំៗហើយ លោកស្រីមានដែលនិយាយរឿងរ៉ាវអស់នោះជម្រាបដល់កូនចៅរបស់លោកស្រីដែរឬទេ?

[១១:២៦:៥៥]

**ឆ៖** ស្តាប់សំណួរអត់បាន។ គឺខ្ញុំនិយាយប្រាប់តើ និយាយប្រាប់ ឪមុំឯងហើយនិងម៉ែ អត់មានបានការត្រឹមត្រូវទេណាកូន ការចាប់ដៃទេណា អត់បានផ្លូងពាក់ អត់មានបានភ្លេងភ្លាត់អីនឹងគេទេ។ ការព្រោះអីការយាយតាអត់ដឹងទេ។ និយាយប្រាប់កូនអ៊ីចឹងទៅ កូន ចុះវាទៅតាមសភាពដែរទៅ ធ្វើម៉េច។

**ស៖** សំណួរចុងក្រោយមែនទែន។ លោកស្រីមានដែលគិតថានៅក្នុងមួយជីវិតរបស់ លោកស្រីៗចង់ឲ្យមានការរៀបអាពាហ៍ពិពាហ៍មួយតាមបែបដែលលោកស្រីចង់បានដែរឬទេ?

**ឆ៖** គឺខ្ញុំជម្រាបតាមត្រង់ ព្រោះអីកាលជំនាន់ហ្នឹង ក្នុងចិត្តនោះ វាចង់បានការមានប្រពៃណីនឹងគេហើយ ប៉ុនធ្វើម៉េចវាតាមដំណើរទៅអ៊ីចឹងហើយ។ អារឿងចិត្តនោះវាចង់បានប្រពៃណីហើយ

ប្រពៃណីតាំងដូនតាម៉ាកុងយើងពីដើមមកនោះ ប៉ុន្តែដល់សម័យនេះ សម័យអ៊ីចឹងមិនដឹងធ្វើម៉េច តាមដំណើរទៅ។

**លោក ពេជ អង្គ៖**

បាទ សូមអរគុណ លោកស្រីដែលបានឆ្លើយនឹងសំណួរខ្ញុំ។

លោកប្រធានខ្ញុំអស់សំណួរហើយ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ ឥឡូវនេះដល់ពេលឈប់សម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ទៅកាន់បន្ទប់រង់ចាំខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់មកចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយកន្លះ។

សូមអញ្ជើញសម្រាក។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:២៨ នាទី ដល់ម៉ោង ១៣: ២៨នាទី)*

[១៣:២៨:៣៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកមេធាវីការពារលោក នួន ជា --

អ៎! សូមអញ្ជើញលោកៗចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរបន្តិចបន្តួចទេ អ៊ីចឹងមិនយូរទេ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** លោកស្រី កាលពីព្រឹកមិញលោកស្រីបាននិយាយថា ក្រោយពីលោកស្រីបានរៀបការហើយ លោកស្រីបានកត់សម្គាល់ឃើញថា ឈ្លបមកតាមដាន មកតាមមើល ថាតើលោកស្រីចុះសម្រុងជាមួយនឹងប្តីលោកស្រីដែរឬក៏អត់? តើលោកស្រីដឹងថាឈ្លបមកតាមដានលោកស្រីនេះតាមវិធីណាដែរ? ហេតុអីបានដឹង? តើលោកស្រីបានឃើញពួកគាត់ បានឮពួកគាត់ ឬក៏លោកស្រីបាននិយាយជាមួយពួកឈ្លបទាំងអស់ហ្នឹង ឬក៏យ៉ាងម៉េច?

[១៣:២៩:៥៩]

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** ខ្ញុំក៏សូមមានប្រសាសន៍ គឺចំពោះខ្លួនខ្ញុំ គឺអាចឈ្លបនៅជិតៗគ្នា ឈ្លបគ្នាឯងហ្នឹង ក៏គេតាមដានពួកខ្ញុំ អ៊ីចឹងក៏បានឮ។ មានតាមដានប៉ុណ្ណឹង អត់មានអីទៀតវែងឆ្ងាយដែរ អត់ទេ។

**ស៖** សំណួរខ្ញុំ ខ្ញុំចង់ថាតើហេតុអ្វីបានលោកស្រី<គិត>ថា ឈ្លបមកតាមដានលោកស្រី? តើលោកស្រីបានឮពួកគាត់ ឬក៏លោកស្រីបានឃើញពួកគាត់ ឬក៏មានហេតុមូលហេតុផ្សេងណាមួយទៀតដែលធ្វើឲ្យលោកស្រី<គិត>ថាពួកគេមកតាមដានលោកស្រី?

**ឆ៖** ហ្នឹងព្រោះអីដឹង ដឹងឈ្លបមកតាមដាន ព្រោះអីមើលឃើញទាំងយប់។ នាំគ្នាថា នែ! ឈ្លបមកតាមដានហើយ យើងប្រយ័ត្នណា៎។ ពួកនាងខ្ញុំទាំងអស់គ្នានិយាយគ្នាថាអ៊ីចឹង។

**ស៖** ឈ្លបទាំងអស់ហ្នឹង គឺឈ្លបនៅស្រុកសំឡូតហ្នឹង តើអ្នកណាជាមេឈ្លបទាំងអស់ហ្នឹង? ឈ្លបទាំងអស់ហ្នឹងទទួលបញ្ជាពីអ្នកណាដែរ?

**ឆ៖** ខ្ញុំអត់ដឹងដែរ ព្រោះអីគេមានឈ្លប មិនមេកងនៅណា អត់ដឹងផង ខ្ញុំ។ ដឹងថាឈ្លប មិនដឹងមេគេមួយណា ប្រធានក៏អត់ដឹងដែរ ទើបទៅនៅប៉ុណ្ណឹងឆ្នាំ ប៉ុណ្ណឹងខែ អត់សូវដឹងដែរហ្នឹង ខ្ញុំ។ ហើយក៏យើងចេះតែខ្លាចទៅ ដល់ចេះតែសាមគ្គីគ្នាទៅ។ នាងខ្ញុំមានពាក្យ *(ឮមិនច្បាស់)*។

[១៣:៣២:០១]

**ស៖** អ៊ីចឹង ហេតុអីបានលោកស្រីភ័យខ្លាចពួកទាំងអស់ហ្នឹង? លោកស្រីឃើញឈ្លបទាំងអស់ហ្នឹងចាប់មនុស្សឬក៏យ៉ាងម៉េច? តើក្នុងចំណោមអ្នកដែលលោកស្រីស្គាល់ និងលោកស្រីផ្ទាល់ហ្នឹង មានអ្នកណាដែលត្រូវបានគេចាប់ខ្លួនទេ?

**ឆ៖** ចាស នាងខ្ញុំអត់មានបានឃើញគេចាប់ទេ ប៉ុន្តែចេះតែខ្លាចៗនាំគ្នាខ្លាចទៅណ៎ា។ អត់ដែល

បានឃើញគេចាប់ ហើយឈ្លបហ្នឹងឈ្លបភូមិប្រជាជននៅហ្នឹងទេ ខ្ញុំមិនបានស្គាល់ដែរ ទើបតែមកបានប៉ុន្មានខែ មិនទាន់បាន១ឆ្នាំផង។

**ស៖** អ៊ីចឹងឈ្លបទាំងអស់ហ្នឹងមកពីណាដែរ? តើឈ្លបទាំងអស់ហ្នឹង គាត់នៅហ្នឹងស្រាប់ មុនពេលលោកស្រីទៅដល់ទីហ្នឹង ឬក៏ឈ្លបទាំងអស់ហ្នឹងមកពីភូមិភាគនិរតីជាមួយលោកស្រីដែរ?

**ឆ៖** ឈ្លបទាំងអស់ហ្នឹងគឺអត់មានមកពីនិរតីមកទេ ពួកខ្ញុំមកសុទ្ធតែនារីៗ គឺឈ្លបកូនប្រជាជននៅម្ដុំហ្នឹង។ ខ្ញុំមិនបានស្គាល់ជិតដល់ដែរហ្នឹង ព្រោះអីឈ្លបកូនប្រជាជននៅម្ដុំហ្នឹង។ ចេះតែខ្លាចទៅ ប៉ុនអត់ដែលឃើញចាប់មនុស្សចាប់អី អត់ទេ។ អត់មានដែលចាប់ទេ គ្រាន់តែគេទៅអង្កេតមើលយើងចេះរួមដំណេកគ្នាអត់ សាមគ្គីគ្នាអត់ តែប៉ុណ្ណឹងហ្នឹង។

[១៣:៣៣:៥៨]

**ស៖** តើឈ្លបទាំងអស់ហ្នឹង គាត់មានអាយុប៉ុន្មានដែរ?

**ឆ៖** ចាស ខ្ញុំអត់ដឹងអាយុប៉ុន្មាន វានៅធំ តូចខ្លះធំខ្លះ ក៏មិនដឹងគេផង មិនបានសួរគេផង។ ដឹងអាយុប៉ុន្មាន អីប៉ុន្មាន។

**ស៖** បើតាមលោកស្រីមើលទៅនោះ តើឈ្លបដែលអាយុតិចជាងគេនោះ អាយុប្រហែលប៉ុន្មានដែរ?

**ឆ៖** ប្រហែលប្រាំពីប្រាំបីដណ្ដប់ឆ្នាំហ្នឹងឯង ជំនាន់ហ្នឹង។

**ស៖** ហើយអ្នកដែលរៀបការនោះ ក្មេងជាងគេអាយុប៉ុន្មាន? លោកស្រីបាននិយាយថាមាន <ក្មេងស្រីអាយុ១៦ឆ្នាំពីរនាក់ ដែលគេចមិន>រៀបការ <តើមានក្មេងស្រីអាយុ១៦ឆ្នាំផ្សេងទៀត ឬក៏ក្រោមអាយុ១៦ឆ្នាំ ដែលរៀបការនៅពេលនោះទេ>?

**ឆ៖** ចាស់ជាងគេ អាយុ៣០, ២៥។ ក្មេងជាងគេ ១៦, ១៧ ហ្នឹងក្មេងៗ។ ដូចខ្ញុំអី អាយុ២៨បានការ។

**ស៖** ចុះខាងប្ដី ខាងប្រុសវិញនោះ គេអាយុយ៉ាងម៉េចដែរ? អាយុតិចជាងគេប៉ុន្មាន? អាយុច្រើនជាងគេប៉ុន្មាន?

**ឆ៖** ប្រាំបីដណ្ដប់ដែរ គេអត់ឲ្យការទេ ទាល់តែអាយុ២០ជាង ហើយដូចប្ដីខ្ញុំអី ប្អូនខ្ញុំមួយឆ្នាំ។ គ្រួសារខ្ញុំអី ប្អូនមួយឆ្នាំ ខ្លះក៏ប្អូនគ្នាមួយឆ្នាំពីរឆ្នាំ ប្ដីបង ប្រពន្ធៗបងប្ដីក៏មាន ថាមិនត្រូវ បើចាប់ការអ៊ីចឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៣:៣៦:២៦]

**ស៖** ខ្ញុំមិនដឹងថាចម្លើយរបស់លោកស្រីហ្នឹង ត្រូវបានបកប្រែទាំងស្រុង ឬក៏អត់ទេ? ប៉ុន្តែអ្វីដែលខ្ញុំស្តាប់ឮហ្នឹង គឺថាលោកស្រីបាននិយាយថា គឺថាបើក្រោមអាយុ១៨ឆ្នាំហ្នឹង គេមិនអាចឲ្យនារីហ្នឹងការបានទេ ក៏ប៉ុន្តែមុននឹងបន្តិចហ្នឹង លោកស្រីបាននិយាយថា នារីមួយចំនួនហ្នឹង មានអាយុចន្លោះពី ១៦ ទៅ១៧ឆ្នាំទេ។ អ៊ីចឹង លោកស្រីឆ្លើយយ៉ាងម៉េចដែរ តើចាប់ពីអាយុ១៦ ទៅ១៧ឆ្នាំទៅ បានគេឲ្យនារីនោះរៀបការ ឬក៏ទាល់តែពី១៨ឆ្នាំឡើងទៅ? តើយ៉ាងម៉េចដែរ មានការសម្រេចពិសេសណាមួយចំពោះអ្នកដែលមានអាយុក្រោម១៨ ឬក៏យ៉ាងម៉េច?

**ឆ៖** ខ្ញុំសូមមានប្រសាសន៍ គឺមនុស្សប្រុសអាយុប្រាំបីដណ្តប់ ទៅប្រាំបួនដណ្តប់ ទៅ២០, ២៥ បានគេឲ្យការ។ ដល់នារីម្តេជាងដែរ ហើយបើត្រឹម អត់ឲ្យមានអាយុការ ត្រឹមប្រាំមួយដណ្តប់ អត់ទេនារី។ អ៊ីចឹង។ យុទ្ធជនម្តេជាង ការបាន។ ហ្នឹងជំនាន់ហ្នឹង គេនិយាយអ៊ីចឹងឯង។

**ស៖** លោកស្រីបាននិយាយថា លោកស្រីមានប្រវត្តិរូបល្អ ហើយប្តីរបស់លោកស្រីក៏មានប្រវត្តិរូបល្អដែរ។ តើ<លោកស្រីអាចរៀបរាប់បានទេអំពី>សារៈសំខាន់នៃប្រវត្តិរូប<ទាក់ទងនឹង>ការរៀបការនោះ? <ឧទាហរណ៍>ថា តើប្រជាជនថ្មីហ្នឹង អាចរៀបការជាមួយប្រជាជនមូលដ្ឋានដែរឬទេ ឬក៏គេរៀបការ ឬក៏គេរៀបការឲ្យហ្នឹង គឺគេរៀបការទៅតាមប្រវត្តិរូប តាមពីដើមកំណើតមក មកពីខាងណា ខាងណីអ៊ីចឹង។ លោកស្រីអាចរៀបរាប់បានទេ តើប្រវត្តិរូបហ្នឹង មានសារៈសំខាន់យ៉ាងណាដែរ ក្នុងការចាប់គូរៀបការហ្នឹង?

[១៣:៣៩:០១]

**ឆ៖** គឺចាប់គូរៀបការ គឺខ្ញុំក៏មិនសូវមានយោបល់ដែរ។ គឺចាប់គូរៀបការ គឺអត់មានរកពីណាពីណីមក គឺឃើញ គឺចាប់ការតែម្តង។ អត់មានណាថា អង្គភាពណាថា តំបន់ណាក៏អត់ដែរ គឺឃើញចាប់។ ឲ្យតែគេថានេះ ចាប់ការតែម្តង។ ប៉ុន្តែមានខ្លះ គេត្រូវគ្នាដែរ គេស្រឡាញ់គ្នាដែរ។ ស្រឡាញ់គ្នាដែរ ក៏គាត់ការឲ្យទៅ។

**ស៖** លោកស្រីសាក្សី លោកស្រីបាននិយាយថា ប្តីរបស់លោកស្រីមានប្រវត្តិរូបល្អ លោកស្រីក៏មានប្រវត្តិរូបល្អដែរ។ តើប្រវត្តិរូបនេះជាកត្តាមួយដែលគេត្រូវតែយកទៅគិត ដើម្បីសម្រេចថាតើរៀបការអ្នកណាជាមួយអ្នកណា ឬក៏យ៉ាងម៉េច? លោកស្រីយល់សំណួរខ្ញុំទេ ថាតើប្រវត្តិរូបហ្នឹងវាជាកត្តាសំខាន់មួយក្នុងការចាប់គូរៀបការ ឬក៏យ៉ាងម៉េច?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** គឺក្នុងប្រវត្តិរូប គេមើលក្នុងប្រវត្តិរូប អ្នកនេះនៅស្រុកនោះៗ ដូចខ្ញុំអីនៅជិតគ្នាអ៊ីចឹងគេចាប់ការឲ្យទៅ កុំឲ្យឆ្ងាយគ្នា ការឲ្យទៅ។ គឺមិនមានប្រវត្តិរូបល្អអីទេ គ្រាន់ថា ប្រវត្តិរូបអ្នកក្រដូចគ្នាអ្នកកំសត់។ ហ្នឹងហើយរឿងប្រវត្តិរូប។ ដូចខ្ញុំអី គេចាប់ការ ក៏គេមើលប្រវត្តិរូប តាមប្រវត្តិរូប អ្នកនេះនៅស្រុកភូមិជិតគ្នា គេការឲ្យទៅ។

[១៣:៤១:០៥]

**ស៖** តាមលោកស្រីនោះ តើគេបានរៀបការ តើគេអាចរៀបការលោកស្រីជាមួយនឹងប្រជាជនថ្មីបានទេ? តើករណីហ្នឹងអាចកើតឡើងបានទេ បើយកលោកស្រីទៅរៀបការជាមួយប្រជាជនថ្មីវិញនោះ?

**ឆ៖** កាលជំនាន់ហ្នឹងខ្ញុំក៏មិនសូវដឹងដែរ រៀបការជាមួយប្រជាជនថ្មី គឺអត់មានបានរៀបការផង ពួកនៅអង្គភាពខ្ញុំ។ គឺការតែជាមួយពួកនៅក្នុងអង្គភាព ដូចអ្នកពិការ កន្លែងខ្ញុំអីមក យកមកការអ៊ីចឹងបាន។ ប៉ុន្តែក្នុងប្រជាជន ខ្ញុំអត់ -- ប្រជាជនថ្មី ខ្ញុំអត់បានដឹងដែរហ្នឹងណា បើខ្ញុំនៅតែនោះ អត់ដែលបានដឹងផង។

**ស៖** តើមានប្រភេទមនុស្សផ្សេងទៀត ដែលមានការលំបាកដែរនោះ ឧទាហរណ៍ដូចជា អ្នកមកពីកម្ពុជាក្រោម ឬក៏ពីវៀតណាមអីហ្នឹង តើពួកគាត់អាចរៀបការជាមួយខ្មែរ បានទេ?

**ឆ៖** ខ្ញុំរស់នៅអត់មានឃើញគេការជាមួយពួកកម្ពុជាក្រោមអីផង អត់។ គឺខ្ញុំអត់មានបានឃើញទេ។

[១៣:៤២:៤៨]

**ស៖** តើលោកស្រីមានកត់សម្គាល់ឃើញថា មានវត្តមានចាម ឬក៏វៀតណាមដែរឬទេ?

**ឆ៖** ពួកយើងខ្ញុំនៅកន្លែងនោះ អត់មានឃើញចាម ឃើញខ្មែរកម្ពុជាក្រោមអីអត់ទេ ឃើញតែខ្មែរគ្នាឯងហ្នឹងតែម្តង។ ហ្នឹងពួកយើងខ្ញុំនៅកន្លែងនោះ។ អត់មានកម្ពុជាក្រោម អត់មានអីផង។

**ស៖** បាទ តាមលោកស្រី តើអ្នកណាជាអ្នកពិនិត្យបញ្ជី បុរស នារី? ហើយអ្នកណាជាអ្នកសម្រេចថា អ្នកណាត្រូវរៀបការជាមួយអ្នកណានោះ តើតាម៉ុក ជាអ្នកសម្រេច ឬក៏អ្នកដទៃ? តើអ្នកស្រីដឹងទេ ថាអ្នកណាជាអ្នកសម្រេចឲ្យអ្នកណាម្នាក់រៀបការជាមួយអ្នកណាម្នាក់ទៀតនោះ?

**ឆ៖** តាមខ្ញុំបានយល់ហ្នឹង គឺតាម៉ុក ហ្នឹងតែម្តង មកដល់ចាប់ដាក់ៗហ្នឹងតែម្តង។ គាត់មើល -- មិនដឹងគាត់ធ្វើប្រវត្តិរូបពីអង្កាល់ខ្ញុំអត់បានដឹងដែរ។ មកដល់ចាប់ដាក់ៗ គាត់ធ្វើប្រវត្តិពីអង្កាល់ ក៏អត់

01382507



បានដឹង។ ពួកយើងខ្ញុំនិយាយដោយស្មោះត្រង់។

[១៣:៤៤:១៧]

**ស៖** បើសិនជាខ្ញុំយល់មិនច្រឡំទេ កាលពីព្រឹកមិញនោះ លោកស្រីបាននិយាយថា នៅក្នុងចំណោមយោធាពិការទាំងអស់ហ្នឹងមានអ្នកខ្លះមកពីខាងតាកែវ អ្នកខ្លះទៀតមកពីកំពត ហើយមានអ្នកខ្លះទៀតមកពីតំបន់ផ្សេងៗទៀតនៃប្រទេសខ្មែរ។ តើបើតាមលោកស្រី តើយោធាពិការទាំងអស់ហ្នឹងត្រូវបានបញ្ជូនទៅសំឡូត ពី<>ផ្នែកផ្សេងៗនៃប្រទេសកម្ពុជាទាំងអស់ហ្នឹង ដើម្បីទៅរៀបការនៅទីនោះ<ឬក៏មាន>ហេតុផល<ផ្សេងទៀត? ហេតុអ្វីបានជាទាហានមកពីទូទាំងប្រទេសត្រូវបានគេ>បញ្ជូនគាត់ទៅសំឡូត<>?

**ឆ៖** គឺយើងខ្ញុំក៏ គឺយកទៅរៀបការហ្នឹង គឺបញ្ជូនទៅរៀបការ អត់មានឲ្យអី គ្រាន់ថាអ្នកពិការ។ ហើយគឺអ្នកពិការនៅតាខ្មៅហ្នឹងក៏សុទ្ធតែអ្នកនៅកំពង់ស្ពឺ នៅតាកែវ នៅកំពត ហ្នឹងអ្នកពិការ តាមខ្ញុំសួរគាត់ដឹងច្រើន ភាគច្រើននៅតាកែវ អ្នកពិការ។ ហើយដូចហើយអ្នករៀបការអី យកទៅរៀបការគឺយើងខ្ញុំមិនដឹងខ្មែរកម្ពុជាក្រោមកម្មអី ក៏អាចមើលសម្គាល់ដឹងដែរ គឺកម្ពុជាក្រោមក៏ដឹង ប៉ុន្តែអត់ទេនៅស្រុកសំឡូត គឺខ្មែរយកទៅពីតាខ្មៅ អ៊ីយកទៅ។ អ៊ំម៉ុក យកទៅ។

**ស៖** តើនៅក្នុងចំណោមបុរសៗទាំងអស់ហ្នឹងគឺថាមានអ្នកផ្សេងទៀតដែលមកពីភូមិភាគផ្សេងពីភូមិភាគនិរតីដែរឬទេ?

[១៣:៤៦:៣៦]

**ឆ៖** ហ្នឹងចាស សុទ្ធតែនិរតីមក មកបាត់ដំបងហ្នឹង នៅស្រុកសំឡូតសុទ្ធតែពួកនិរតី។ អត់មានភូមិភាគផ្សេងមកនៅច្របូកច្របល់ជាមួយខ្ញុំ ពួកខ្ញុំអីអត់ទេ។ មានតែពួកខ្ញុំហ្នឹងមកនៅហ្នឹង។

**ស៖** តើប្តី -- តើប្រុសៗទាំងអស់ហ្នឹងគាត់នៅជាមួយប្រពន្ធគាត់ពេញមួយរបបកម្ពុជាប្រជាធិបតេយ្យហ្នឹងតែម្តង ឬក៏រៀបការហើយចេញ ត្រឡប់ទៅវិញអស់ទៅ?

**ឆ៖** អត់ទេនៅជាមួយគ្នា ទើសតែការហើយរហូតទៅរត់យួន ៧៩ហ្នឹងបានរត់បែកគ្នាជាមួយខ្ញុំអីហ្នឹង គាត់រត់ខ្លះក៏ជួបប្តី ខ្លះក៏រត់បែកគ្នាទៅឯណាក៏មិនដឹង ខ្ញុំមិនបានដឹងដែរ ប៉ុន្តែរត់ -- ការហើយនៅរួម នៅជាមួយគ្នាទាំងអស់ ពីព្រោះអីអ្នកពិការមិនដឹងគាត់យកទៅណាទេ ឲ្យនៅថែរក្សាគ្នាជាមួយនារីហ្នឹង។ នេះខ្ញុំសូមអស់។

**ស៖** តើលោកស្រីដឹងដែរឬទេថានៅក្នុងចំណោមគូរៀបការទាំងអស់ហ្នឹង មានអ្នកខ្លះដែលមិន

ចុះសម្រុងនឹងគ្នា ហើយតើមានអ្នកខ្លះហ្នឹងត្រូវគេយកទៅអប់រំកែប្រែទេ? លោកស្រីមានធ្លាប់ស្ដាប់ឮពីបញ្ហាអស់ហ្នឹងទេ?

**ឆ៖** កន្លែងខ្ញុំដូចអត់មានផង អត់មានកន្លែងខ្ញុំ ហើយតាមកន្លែងផ្សេងៗក៏អត់ ខ្ញុំអត់ឮ អត់មានឮពាក្យហ្នឹងផង។ ប៉ុន្តែពួកយើងខ្ញុំទាំងអស់គ្នា គឺគោរពវិន័យចាត់តាំង គឺខំ ខិតខំ ខំគោរពវិន័យចាត់តាំងមិនឲ្យខុសឆ្គងរឿងគាត់រៀបគ្រួសារឲ្យហ្នឹងចេះតែយកចិត្តទុកដាក់ទៅ។ បើតាមកន្លែងខ្ញុំអត់មានទេ បើតាមនានា គេដឹង គេមានអត់ ក៏ខ្ញុំអត់ដឹងដែរ។

[១៣:៤៩:០៩]

**ស៖** តើលោកស្រីមានដែលស្ដាប់ឮនិយាយអំពីកំហុសសីលធម៌ដែរឬទេ? <បើមាន> តើមានរឿងអីកើតឡើងដែរឬទេ ដែលមានករណីកំហុសសីលធម៌ហ្នឹងដែរឬទេ? ហើយអ្នកប្រព្រឹត្តខុសសីលធម៌ហ្នឹង តើមានរឿងអីកើតឡើងចំពោះពួកគាត់?

**ឆ៖** គឺអ្នកខុសសីលធម៌គឺគេយកអប់រំៗ យកណែនាំទៅ គឺខាងនៅកន្លែងខ្ញុំទើបប៉ុណ្ណឹងមិនទាន់បាន១ឆ្នាំផង ខ្ញុំអត់បានឃើញគេចាប់យកទៅវ៉ៃ យកតប់អីអត់ដែរ គឺគ្រាន់តែខុសសីលធម៌ក្នុងករណីម្នាក់ៗអី គឺគេអប់រំ យកកសាងទិតៀនអីចឹងទៅ ហ្នឹងខ្ញុំដែលឃើញ។

**ស៖** ហើយកំហុស គេហៅ "កំហុសសីលធម៌" ហ្នឹង<មានអ្វីខ្លះ>? <តើការខុសសីលធម៌ហ្នឹងមានន័យថា ជាការរួមភេទ>ជាមួយនឹងអ្នកដែលយើង<មិន>រៀបការជាមួយ ឬក៏យ៉ាងម៉េច?

**ឆ៖** គឺអ្នកដែលមានតែស្រឡាញ់គ្នាអី មេៗដូចធំ អ្នកធ្វើការអីអត់ដឹង អ្នកមេៗអត់ដឹង ដឹងអីចឹងគេយកទៅអប់រំអីចឹងទៅ។ អ្នកការហើយអត់អីទេ។ ដូចខ្ញុំនិយាយខាងដើម អ្នកការហើយគេត្រូវគោរពគ្នាទៅវិញទៅមក ខំសាមគ្គីគ្នា។ និយាយអ្នកខូចសីលធម៌អី មានស្រឡាញ់គ្នាមុនអីចឹងទៅ។ ប៉ុន្តែកន្លែងខ្ញុំអត់មាន មានច្រើនកន្លែងគេ ហើយអប់រំគ្នាទៅ ក៏លែងអីទៅ មិនបានយកទៅវៃតប់អីក៏អត់ដែរ។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកស្រី ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកស្រីសាក្សី។

លោកប្រធាន ខ្ញុំអស់សំណួរហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកចៅក្រម។ អញ្ជើញមេធាវីការពារលោក នួន ជា សូមអញ្ជើញ!

[១៣:៥១:៤០]

**លោក លីវ សុវណ្ណា៖**

សូមអរគុណលោកប្រធាន។ ជាបឋមសូមគោរពលោកប្រធាន សូមគោរពអង្គសវនាការទាំងមូល។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** សូមជម្រាបសួរលោកស្រីសាក្សី ខ្ញុំឈ្មោះ លីវ សុវណ្ណា ជាមេធាវីជាតិនៅក្នុងក្រុមការពារក្តីលោក នួន ជា។ ខ្ញុំថ្ងៃនេះខ្ញុំមានសំណួរមួយចំនួនចង់សួរបន្ថែមចំពោះលោកស្រី។ ទី១ ភ្ជាប់ហ្នឹងសំណួររបស់លោកចៅក្រមអម្បាញ់មិញ គឺកំហុសសីលធម៌ លោកស្រីបានលើកឡើងថា "កំហុសសីលធម៌គឺស្រលាញ់គ្នាមុនពេលរៀបការ"។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ថា តើស្រឡាញ់គ្នាដែលលោកស្រីសំដៅថាជាកំហុសសីលធម៌ គ្រាន់តែជាការស្រឡាញ់ចិត្តនិងចិត្ត ឬទាល់តែបានរួមដំណេកជាមួយគ្នាបានចាត់ទុកថាជាកំហុសសីលធម៌?

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** នាងខ្ញុំក៏ អាហ្នឹងដល់តែមើលខុសឆ្គង មានស្រឡាញ់គ្នា រួមដំណេកអីមួយគ្នាហ្នឹងបានគេថាខុស បើត្រឹមសាមគ្គីគ្នាអត់អីទេ ចាស។

**ស៖** អ៊ីចឹងខ្ញុំចង់បញ្ជាក់លោកស្រីឲ្យបានច្បាស់បន្តិច។ អ៊ីចឹងទាល់តែបានរួមដំណេកជាមួយគ្នាបានខ្លួនប្រាណគ្នា បានចាត់ទុកថាជាកំហុសសីលធម៌។ តើអ៊ីចឹងមែនបាទ?

**ឆ៖** ចាស អ៊ីចឹងមែន។

[១៣:៥៣:២២]

**ស៖** បាទ អរគុណលោកស្រី។ សំណួរមួយទៀតទាក់ទងនឹងលោកស្រីអំមិញបានលើកឡើងថាស្ត្រីអាយុ១៦ឆ្នាំ មិនឲ្យរៀបការទេ។ អ៊ីចឹងក្នុងនាមដែលលោកស្រីដែលៗធ្លាប់ធ្វើជាកម្មាភិបាលមួយរូបដែរ តើក្នុងសម័យហ្នឹងលោកស្រីដែលឮគោលនយោបាយថា ស្រីអាយុចាប់ពីប៉ុន្មានឆ្នាំទៅបានអាចរៀបការបានទេ លោកស្រីមានដែលឮទេ?

**ឆ៖** គឺខ្ញុំបានឮគឺ ពេលថាអាយុនារីស្រីអាយុ២០ ទៅ២១ គឺទៅ១៩ក៏បានដែរ ១៨ក៏បានដែរ។ អាហ្នឹងចំពោះ ខ្ញុំមានតែប៉ុណ្ណឹងឯង។ ហើយបើប្រុសវិញ អាយុ២០ជាងបានគេឲ្យការ។

**ស៖** អ៊ីចឹងមានន័យថាស្រីអាយុទាបបំផុតត្រឹម ១៨ឆ្នាំបានអាចរៀបការបាន តើខ្ញុំនិយាយអ៊ីចឹង

តើត្រូវទេលោកស្រី?

**ឆ៖** ចាស។

**ស៖** បាទ អរគុណលោកស្រី។ សំណួរខ្ញុំមួយទៀតទាក់ទងនឹងការសង្កេត ក៏ដូចជាបទពិសោធន៍ផ្ទាល់របស់លោកស្រី ក្នុងរយៈកាលដែលលោកស្រីកាន់តួនាទីជាអនុលេខាស្រុកម្នាក់ហ្នឹង តើលោកស្រីមានកត់សម្គាល់ ឬក៏បានចូលរៀប -- ចូលរួមរៀបការឲ្យគូស្រករណា ក្រៅពីការចូលរួម៤០គូ ដែលលោកស្រីចូលផ្ទាល់ហ្នឹង? តើលោកស្រីមានដែលបានចូលរួមរៀបការឲ្យទៅកូនប្រជាជនណា ឬក៏គូស្រករណាផ្សេងទៀតទេបាទ?

**ប្រធានអង្គជំនុំ៖**

លោកស្រីសាក្សីចាំមីក្រូហ្វូនដំណើរការសិន ចាំភ្លើងក្រហមចាំឆ្លើយ។ មន្ត្រីរដ្ឋបាលតុលាការលើកមីក្រូហ្វូនឡើងលើបន្តិច ដើម្បីឲ្យអង្គជំនុំជម្រះអាចមើលឃើញភ្លើងក្រហម។

លោកមេធាវីសូមតាំងសំណួរម្តងទៀត។

[១៣:៥៦:២២]

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទ អរគុណលោកចៅក្រម។ លោកស្រីខ្ញុំដឹងថា តាមការសង្កេត ឬក៏បទពិសោធន៍របស់លោកស្រី តើលោកស្រីដែលបានចូលរួម ឬក៏ឃើញមានគូគេរៀបការផ្សេង ក្រៅពីគូរបស់លោកស្រី៤០គូហ្នឹងដែរទេ?

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** សួរថា ខ្ញុំអត់ដែល -- ខ្ញុំបាន -- ខ្ញុំគេ អ៊ំម៉ុក រៀបការឲ្យដែរហ្នឹង។ ខ្ញុំមិនបានរៀបការឲ្យគេផង អត់។

**ស៖** បាទ សូមទោសលោកស្រី។ ឥឡូវអ្វីដែលខ្ញុំសួរ ក្រៅពីការរៀបការរបស់លោកស្រី លោកស្រីកុំអាលទាន់គិតរឿង ថ្ងៃរៀបការរបស់លោកស្រី។ ខ្ញុំចង់ដឹងថា នៅក្នុងឋានៈលោកស្រីជាអនុលេខាស្រុកម្នាក់នោះ អ៊ីចឹងនៅពេលដែលក្នុងរយៈពេលដែលលោកស្រីធ្វើជាអនុលេខាស្រុកហ្នឹង លោកស្រីមានដែលបានឃើញ ឬក៏ទៅបានចូលរួមក្នុងការរៀបការឲ្យគូស្រករណាផ្សេងដែរទេ?

**ឆ៖** ឥឡូវខ្ញុំក៏មានមតិដែរ គឺ គេរៀបការ គឺខ្ញុំអត់ដែលបានទៅរៀបការឲ្យកូនប្រជាជន ហើយបានរៀបការឲ្យអង្គភាព ក្នុងអង្គភាពខ្ញុំនុ៎ងដែរ គឺការគេ លេខាតាប្រធានទេ គឺត្រឹមខ្ញុំអីអត់ទេ អត់ដែល

បានទៅទេ។ គឺខ្ញុំមិនសូវចេះ អត់ដែលបានទៅទេ។ ប៉ុន្តែមិនសូវបានរៀបការផង អ្នកកូនប្រជាជនស្រុកសំឡូត។ រៀបការបានមួយគូ ពីរគូ ចាស។

[១៣:៥៨:១០]

**ស៖** បាទ អរគុណលោកស្រី។ លោកស្រីអំមិញមានប្រសាសន៍ថា ប្រធានទៅហ្នឹង តើលោកស្រីសំដៅប្រធានហ្នឹងអ្នកណាគេទៅលោកស្រី?

**ឆ៖** បងឡេង ហ្នឹងស្រុកសំឡូតហ្នឹង។ គាត់នៅស្រុកសំឡូតហ្នឹង។ គឺខ្ញុំមិនដែលបានទៅទេ គេមិនឲ្យទៅទេ ខ្ញុំមិនចេះអក្សរនោះ។ គេប្រើធ្វើការរវីរក់នឹងផ្ទះហ្នឹងឯង។

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់ -- តើលោកស្រីបានដឹងថា មុនពេលដែលលោកស្រី ឡេងឈ្មោះ ឡេង ហ្នឹងគាត់ទៅរៀបការហ្នឹង តើគូស្រករហ្នឹងគាត់ស្នើគ្នាម៉េច ហើយអ្នកណាអ្នកសម្រេចរៀបការ តើលោកស្រីមានបានដឹងដែរទេ?

**ប្រធានអង្គជំនុំ៖**

លោកស្រីសាក្សីកុំអាលទាន់ឆ្លើយ ចាំមីក្រូហ្វូនប្រតិបត្តិការ ចេញភ្លើងក្រហមសិន!

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** គឺកូនប្រជាជនគាត់ត្រូវគ្នាជាមួយគ្នាគាត់អ៊ីចឹងហើយ យើងចេះតែចូលរួមជាមួយគាត់ទៅប៉ុន្តែខ្ញុំអត់ដែលបានចូលរួមទេ។ ខ្ញុំគេប្រើនៅផ្ទះហ្នឹងឯង។ ចាស អស់មានយោបល់។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** លោកស្រីអាចពន្យល់បានទេ ពាក្យថា ត្រូវគ្នាជាមួយគ្នាគាត់ហើយ បានខាងស្រុកគេទៅចូលរួមរៀបការឲ្យហ្នឹង។ តើអាហ្នឹងមានន័យថាម៉េចលោកស្រី?

[១៤:០០:០៤]

**ឆ៖** ហ្នឹង មានន័យថា ម៉ែឪទាំងសងខាងកូនប្រជាជនហ្នឹង ម៉ែឪគេទាំងសងខាង គេត្រូវគ្នាហើយ គេគិតគូរឲ្យកូនគេ គេហៅយើងទៅ គេហៅពួកខ្ញុំ ពួក បងឡេង ហ្នឹងទៅៗ ប៉ុន្តែខ្ញុំអត់បានទៅនឹងគេទេ។ ចាស មានតែប៉ុណ្ណឹងឯង។

**ស៖** បាទ អរគុណលោកស្រី។ អ៊ីចឹងមានន័យថា ប្រជាជនហ្នឹង គាត់កូនប្រជាជន គាត់មានសិទ្ធិជ្រើសរើសគូស្រករ គាត់ពេញចិត្តគ្នាហើយ គាត់ស្នើទៅអង្គការថ្នាក់ស្រុក ដើម្បីឲ្យរៀបការជាមួយគាត់ តើអ៊ីចឹងមែន ក៏មែនបាទ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** ចាស។ គាត់និយាយត្រូវគ្នាអ៊ីចឹងហើយ គាត់ហៅយើងកន្លែងស្រុកហ្នឹងទៅៗ ជួយរៀបចំគ្នា។ រៀបចំមួយភ្លែតៗហ្នឹង មានស្អីយូរ រៀបការ។ ចាស ខ្ញុំអស់មានយោបល់ហើយ មានតែប៉ុណ្ណឹងទេ។

**ស៖** បាទ អរគុណលោកស្រី។ សំណួរខ្ញុំបន្តទៀត ខ្ញុំចង់ដឹងថា តើក្រោយរៀបការហើយ តើលោកស្រីមានដឹងថា ប្ដីលោកស្រីហ្នឹងបានប្រាប់លោកស្រីថា គាត់ជាអ្នកស្នើលោកស្រី គាត់បានឃើញលោកស្រីមុន ឬក៏អត់ទេ?

[១៤:០១:៣១]

**ឆ៖** ចាស អត់ទេ។ អត់មាននិយាយអីទាំងអស់ ទាំងសងខាង គឺអត់មានបានស្នើ បានអីទេ។ ខ្ញុំចេះថាដែរ ចាប់បញ្ជូលៗ មានទៅបានស្នេហ៍ស្នើគ្នាណា ទាំងសងខាង អត់ទេ អត់។ សុទ្ធតែចាប់ដាក់ៗតែម្ដង មានបានស្នើគ្នា មានបានឃើញគ្នាអីទេ។ ចាស ខ្ញុំមានតែប៉ុណ្ណឹងទេ។

**ស៖** បាទ អរគុណលោកស្រី។ ដើម្បីរំឭកការចងចាំរបស់លោកស្រី លោកប្រធាន ខ្ញុំសូម ខ្ញុំបាទសូមអនុញ្ញាតអាននូវសម្រង់ចម្លើយរបស់ប្ដីលោកស្រីនៅ ឌី.ស៊ី.ខេម គឺឯកសារលេខ E3/9110 ដែលមានលេខ ERN ជាភាសាខ្មែរ 00734877, ជាភាសាអង់គ្លេស 01063385, ជាភាសាបារាំង 01309460។ លោកស្រី ខ្ញុំសូមដកស្រង់ចម្លើយរបស់ប្ដីលោកស្រី។

ប្ដីលោកស្រីបានឆ្លើយថា៖ “ខ្ញុំរៀបការនៅឆ្នាំ៧៨។” អ្នកសួរ៖ “អ៊ីចឹងកាល៧៨ហ្នឹង ពូពេញចិត្តមីង ឬមើលឃើញគ្នា ឬយ៉ាងម៉េច? អង្គការចាត់ដាក់ឲ្យ?” ប្ដីរបស់លោកស្រី៖ “អត់ទេ ពេញចិត្តដែរ។ តាម៉ុក គាត់ឲ្យរើសដែរហ្នឹង មិនមែនគេចាប់បង្ខំទេ។” អ្នកសួរ៖ “អ៊ីចឹងមាន តាម៉ុក ចូលរួមដែរ?” ប្ដីរបស់លោកស្រី៖ “គាត់មិនចូលរួមទេ គាត់ឲ្យមេបន្ដបន្ទាប់ ជាអ្នករៀបចំ ប៉ុន្តែគេយកនារីមកឲ្យយើងមើលអ៊ីចឹងទៅណ៎ា។” អ្នកសួរ៖ “បាទ”។ ប្ដីរបស់លោកស្រី៖ “យើងពេញចិត្តអ្នកណា យើងប្រាប់គេទៅ។ ពេលរៀបចំ មានមេខាងនារីហ្នឹង គេប្រាប់ថា មេខាងយុទ្ធជនហ្នឹង ប្រាប់ថា ខ្ញុំស្រឡាញ់នារី “ខ”អ៊ីចឹងទៅណ៎ា។ ទៅប្រាប់អង្គភាពនារីអ៊ីចឹងទៅ ហើយនារីៗគេទៅប្រាប់នារី “ខ”ថា ខ្ញុំឈ្មោះនេះ អង្គភាពនេះ ស្រឡាញ់មិត្តឯង។” អ្នកសួរ៖ “បាទ”។ ប្ដីរបស់លោកស្រី៖ “មិត្តឯង អាចទទួលបានដែរឬអត់ បើនារីគេថាទទួលបាន អ៊ីចឹងគេរៀបចំឈ្មោះទៅថ្ងៃយើងរៀបចំផ្សំផ្គុំគ្រួសារ និងគេយកឈ្មោះហ្នឹង តុមួយអង្គុយទល់មុខគ្នាអ៊ីចឹងទៅ។” បិទការដកស្រង់។

អ៊ីចឹងបន្ទាប់ពីការអានចម្លើយរបស់ប្ដីលោកស្រី តើលោកស្រីមាននឹកឃើញថា ប្ដីលោកស្រីធ្លាប់

បាននិយាយថា គាត់ធ្លាប់ឃើញលោកស្រី ឬក៏គាត់ធ្លាប់ស្នើលោកស្រីដែរទេ បាទ?

[១៤:០៤:២៨]

**ឆ៖** ចាស ខ្ញុំគាត់អត់ដែលបានស្នើខ្ញុំ ហើយខ្ញុំក៏អត់ដែលបានស្រឡាញ់គាត់ ហើយក្រែងគាត់ចេះតែនេះទេដឹង គាត់មិនដឹងដែរ ខ្ញុំមិនដឹងដែរ។ ផ្សេង អង្គភាពផ្សេង គេនៅផ្សេង។ គឺខ្ញុំអត់ទេ ខ្ញុំអត់មានបាន គាត់បានស្នើខ្ញុំទេ អត់ទេ បើស្នើ ខ្ញុំប្រកែកបាត់ហើយ ខ្ញុំមិនយកទេ។

**ស៖** បាទ។ អរគុណលោកស្រី អ៊ីចឹងក្រោយរៀបការហើយ ប្ដីរបស់លោកស្រីក៏អត់ដែលបានប្រាប់រឿងហ្នឹង ដល់លោកស្រីដែរ ឬមួយក៏យ៉ាងម៉េចដែរ បាទ?

**ឆ៖** គាត់អត់ដែលប្រាប់ ដែលនិយាយអីផង អត់ៗសោះ។ អត់មានដែលនិយាយអីរឿងថា ស្រឡាញ់ខ្ញុំអី លបមើលខ្ញុំអីឯណាអត់ អត់ដែលនិយាយសោះ។ ហ្នឹងខ្ញុំនិយាយដោយជាក់ស្ដែង ដោយស្មោះត្រង់ អត់សោះ។

**ស៖** បាទ អរគុណលោកស្រី។ ឥឡូវចូលដល់ថ្ងៃដែលរៀបការ ដែលលោកស្រីបញ្ជាក់កាលពីព្រឹកមិញថាមាននារីពីរនាក់--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំសូមការបំភ្លឺមួយ។ តើលោកមេធាវីហ្នឹងគាត់អាចផ្ដល់លេខឯកសារហ្នឹងបានដែរឬទេ? ព្រោះថាយើងរកអត់បានទេ អម្បាញ់មិញនេះ។ ហើយតើគាត់អាចផ្ដល់ឈ្មោះប្ដីរបស់លោកស្រីសាក្សីនេះបានដែរឬទេ ដើម្បីឱ្យយើងអាចផ្ទៀងផ្ទាត់បានលោកប្រធាន។

**លោក នីកូឡាស គូមជែន៖**

ខ្ញុំអាចៗជួយ គឺ E3/9310។ បាទ ជាចំណុចដែលមេធាវីដកស្រង់ ឈ្មោះប្ដីរបស់គាត់ ឈ្មោះព្រាប កប--

**លោកស្រី ដូរីន ជិន៖**

<បញ្ហា>ដូចគ្នា <ប៉ុន្តែខុសគ្នា>គឺ E3/9110, ERN អង់គ្លេស 01063385, ខ្មែរ 00734877, បារាំង 01309460។

[១៤:០៧:១៦]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីបន្តសំណួរ!

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទ អរគុណលោកប្រធាន។ លោកស្រីថ្ងៃដែលលោកស្រីរៀបការហ្នឹង លោកស្រីបានឆ្លើយថាមាននារីពីរគូបានរត់ចេញមិនព្រមរៀបការ ហើយលោកស្រីបានបញ្ជាក់ថាគាត់មានអាយុ១៦ឆ្នាំ ប៉ុន្តែអម្បាញ់មិញ លោកស្រីបញ្ជាក់ថាគោលការណ៍គឺស្ត្រីអាយុ១៨ ទាបបំផុត ១៨ឆ្នាំ បានអាចរៀបការបាន។ តើលោកស្រីរំឭកការចងចាំលោកស្រី ថាតើហេតុអីបានជាលោកស្រីដឹងថានារីទាំងពីរនាក់ហ្នឹងអាយុ១៦ឆ្នាំ ឬមួយក៏គាត់មិនមែនជាអាយុ១៦ឆ្នាំទេ សូមលោកស្រីជួយបំភ្លឺចំណុចនេះបាទ?

**លោកស្រី ណុប ង៉ីម៖**

**ឆ៖** ចាស ខ្ញុំសូមជួយបំភ្លឺ គឺ អ្នកក្នុងការរត់ពីរនាក់ហ្នឹងគឺវារត់។ វារត់អ៊ីចឹង សួរវា កូន -- ខ្ញុំអត់ដឹង អត់ដឹងគេអាយុប៉ុន្មានអីប៉ុន្មាន ប៉ុន្តែវាថាៗវាអាយុ១៦ ពីរនាក់ហ្នឹងអាយុ១៦។ អ៊ីចឹងក៏អ៊ំថា បើវាតិចពេកមិនបាច់ វារត់ៗទៅ អ៊ំគាត់ថាអ៊ីចឹង អ៊ំម៉ុក ណា។ គាត់ថាអ៊ីចឹង វារត់ៗទៅ វាអាយុតិចណាស់ទើប១៦ឆ្នាំ អ៊ីចេះ បានខ្ញុំដឹងហ្នឹង។

**ស៖** បាទ អ្នកណាគេប្រាប់ថាគាត់អាយុ១៦ឆ្នាំ?

**ឆ៖** ខ្លួនវាហ្នឹង។ ចាស ខ្លួនវា ខ្លួនអ្នកសាមីខ្លួនអ្នករត់ហ្នឹង អ្នករៀបការជាមួយខ្ញុំអីរត់ហ្នឹង ខ្លួនគាត់ហ្នឹងអ្នកប្រាប់ គាត់ទើបអាយុ១៦ឆ្នាំ។

[១៤:០៩:០៨]

**ស៖** បាទ សូមៗលោកស្រីរកនឹកមើល ថាតើគាត់ប្រាប់ថាអាយុ១៦ឆ្នាំហ្នឹង គាត់ប្រាប់នៅពេលណា? នៅពេលដែលកំពុងរៀបការ ក៏ក្រោយពេលដែលគាត់រត់ហើយ?

**ឆ៖** គាត់ថាពេលរត់ហើយបាន២ថ្ងៃ ស្អែកឡើងនិយាយប្រាប់។ ខ្ញុំខ្ជិលណាស់ ខ្ញុំអាយុតិចណាស់ ទើប១៦ឆ្នាំ ថាអ៊ីចេះ។ ចាស នាងខ្ញុំដឹងតាមសាមីខ្លួនរបស់គាត់ដែរ។

**ស៖** បាទ អ៊ីចឹងពេលថ្ងៃរៀបការហ្នឹងពុំមានអ្នកណាដឹងថាគាត់ទាំងពីរនាក់ហ្នឹងអាយុប៉ុន្មានទេ អ៊ីចឹងអ្នីលោកស្រី?

**ឆ៖** ចាស គឺអត់មានសួររកអាយុអីទេ អាយុនេះប៉ុន្មានៗអត់ ចាប់បញ្ចូលៗ។ ដូចខ្ញុំថាខាងលើ អ៊ីចឹង អត់មានសួររកអាយុគ្នា គ្នានៅក្មេងៗ។ ចាស ប៉ុណ្ណឹងហើយ។

**ស៖** បាទ អរគុណលោកស្រី។ ខ្ញុំចង់បញ្ជាក់អាថ្ងៃរៀបការហ្នឹង តើក្រៅពីពីរនាក់ដែររត់ចេញ មានអ្នកណាមួយដែលគាត់ប្រកែកថា គាត់សុំមិនទាន់រៀបការអីទេបាទ?

**ឆ៖** ចាស អត់មានអ្នកហ៊ានប្រកែកទេ អ្នកហ៊ានសួរអីក៏អត់ដែរ អត់ហ៊ានទាំងអស់។ ហ៊ានសួរថា មិនទាន់រៀបការរៀបអីអត់ គឺអត់ហ៊ានតែម្តង។ អត់ហ៊ានមាត់ ហ៊ានកអីទេ។ គាត់ធ្វើម៉េចធ្វើអ៊ីចឹងជាមួយគាត់ទៅ។

**ស៖** ហេតុអីបានជាលោកស្រីអត់ហ៊ានប្រកែក?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

**ប្រធានអង្គជំនុំ៖**

លោកស្រីចាំមីក្រូហ្វូនប្រតិបត្តិការសិន ចេញភ្លើងក្រហម ចាំលោកស្រីឆ្លើយ។

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** គឺចំពោះខ្លួនខ្ញុំផ្ទាល់ គឺខ្លាចតែម្តង។ អត់ ទោះបីយ៉ាងណា អត់ហ៊ានប្រកែក អត់ហ៊ាន ដូចខ្ញុំនិយាយខាងដើមអ៊ីចឹង ខ្លាចតែម្តង ទាំងអស់គ្នា អ្នកណាក៏ខ្លាចដែរ ខ្លាចច្បាប់តែម្តង។

[១៤:១១:៣៥]

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** បាទ សូមទោស សូមលោកស្រីបញ្ជាក់ឲ្យច្បាស់បន្តិច តើខ្លាចហ្នឹង តើលោកស្រីខ្លាចអ្វី? ខ្លាចគេសម្លាប់ ខ្លាចបាត់បង់តំណែង ខ្លាចគេទិតៀន ខ្លាចគេយកទៅកសាង ខ្លាចអ្វី ដែលលោកស្រីគិតថា លោកស្រីខ្លាចហ្នឹង?

**ឆ៖** ពួកយើងខ្ញុំខ្លាច ខ្លាចគេចាប់យកទៅកសាង យកទៅអប់រំអ៊ីចឹងទៅ ហើយលគេទិតៀនអ៊ីចឹងទៅ គឺមិនចង់ឲ្យធ្វើអ៊ីចឹង គឺចំពោះខ្លួនខ្ញុំអ៊ីចឹងឯង។

**ស៖** បាទ ឆ្លងកាត់បទពិសោធន៍របស់លោកស្រី ឬក៏ការសង្កេតរបស់លោកស្រី តើលោកស្រីដែលឃើញមានគូស្រករណា ដែលគាត់ប្រកែកមិនព្រមរៀបការ ហើយគេយកគាត់ធ្វើអ្វី ទៅកសាង ឬក៏ទៅចាប់ខ្លួនគាត់យ៉ាងម៉េចទេបាទ?

**ឆ៖** ចាស គឺខ្លាច មានចាប់ខ្លួនដែរ តែនេះគេចាប់ហើយ គេចាប់យកទៅ ខ្លាចអ៊ីចឹងហ្នឹងហើយ។ ហ៊ឺ ! គាត់សួរថាម៉េចទេ ភ្លេចហើយអំមិញ។ វិញ្ញាណតិចណាស់ខ្ញុំឥឡូវ។

**ស៖** បាទ អត់អីទេលោកស្រី ខ្ញុំគ្រាន់ចង់បញ្ជាក់លោកស្រីថាតើលោកស្រីដែលឃើញ មានអ្នក

ណាមួយដែលគេ គាត់ប្រកែកអត់ព្រមរៀបការ ហើយគេធ្វើអ្វីចំពោះគាត់នោះ? មានដែលបានសរសេរដែលឃើញដែរទេ?

[១៤:១៣:១៧]

**ឆ៖** ចាស គឺចំពោះខ្លួនខ្ញុំ អត់ដែលឃើញទេ អត់ដែលឃើញគេចាប់ គេស្អីយកទៅនេះអីចឹង ប៉ុន្តែចេះតែខ្លាចទៅ។ ខ្លាចៗច្បាប់ ខ្ញុំខ្លាចច្បាប់គេ។ ខ្ញុំមានអីឆ្លើយ ឆ្លើយតែប៉ុណ្ណឹង ខ្លាចច្បាប់គេ។

**ស៖** តើច្បាប់ហ្នឹងៗគេនិយាយថាម៉េចដែរ លោកស្រីអាចបញ្ជាក់បានទេ?

**ឆ៖** គឺបញ្ជាក់ជូនបាន ច្បាប់ហ្នឹងគឺ ច្បាប់គេៗមានច្បាប់ទម្លាប់ដូចយើងអីចឹង។ ម៉េចថាច្បាប់នោះ ខ្ញុំមិនបញ្ជាក់ណាស់ ច្បាប់។ ច្បាប់ទម្លាប់ គេមាន មានច្បាប់ទម្លាប់គេអីចឹង។

**ស៖** បាទ សំណួរខ្ញុំបន្តទៀតទាក់ទងនឹងរឿង អំមិញលោកស្រីបញ្ជាក់ថា លោកស្រីចេះតែខ្លាចឈ្លបទៅលបស្ដាប់។ អីចឹងលោកស្រីរកនឹកមើល ថាតើថ្ងៃដែលលោក ក្រោយពីលោកស្រីរៀបការហើយ លោកស្រីមានបានឃើញឈ្លប គេលបស្ដាប់លោកស្រី ឬក៏តាមដានលោកស្រីផ្ទាល់ភ្នែកដែរទេ?

**ឆ៖** ចាស ខ្ញុំឆ្លើយ គឺខ្លាចឈ្លបតាម គឺកន្លែងហ្នឹងវាមានកងឈ្លប មានកូនប្រជាជន ព្រោះអីចេះតែខ្លាចទៅ ខ្លាចក្រែងលោកគេលបស្ដាប់អីទៅ យើងចេះតែ -- ចេះតែណែនាំគ្នាឱ្យបានល្អទៅ។ តែយើងខុសក៏ពិបាកដែរ ពិបាកត្រង់អី ត្រង់គេហៅអប់រំ ហៅកសាង យើងការហើយមិនចុះដំណេកគ្នា មិនរួមដំណេកគ្នាអីចឹង គឺចំពោះខ្លួនខ្ញុំខ្លាចអីចឹងឯង មានអារម្មណ៍មួយខ្លាចអីចឹង ចាស។

[១៤:១៥:២៤]

**ស៖** បាទ ដើម្បីរំឭកការចងចាំរបស់លោកស្រី លោកប្រធានសូមអនុញ្ញាតអានចម្លើយដែលលោកស្រីបានផ្ដល់ឆ្លើយនៅសហចៅក្រមស៊ើបអង្កេត គឺឯកសារលេខ E3/9819 ត្រង់ចំណុចសំណួរចម្លើយទី៧០ ដែលមានសំណួរគេសួរថា៖ "មានរបាយការណ៍ដែលគេនិយាយថា ចំពោះប្ដីប្រពន្ធដែលគេចាប់ឱ្យរៀបការដោយបង្ខំក្នុងរបបខ្មែរក្រហម ត្រូវបានគេតាមដាននៅពេលយប់ ថាតើពួកគេបានរួមរក្សជាមួយគ្នាឬអត់? តើករណីនេះមានកើតឡើងនៅស្រុកសំឡូតដែរឬទេ?" ចម្លើយលេខ៧០ លោកស្រីបានឆ្លើយថា៖ "មិនមានអ្នកណាមកតាមដានពួកយើងទេ"។ តើការអានបែបនេះ លោកស្រីរំឭកការចងចាំបានទេថា ពេលដែលរៀបការនោះ មានការណែនាំឱ្យឈ្លបតាមដានអ្នកដែលរៀបការថ្មីដែរឬទេបាទ?

**ឆ៖** ចាស គឺវាសាមសែឆ្នាំហើយ ខ្ញុំវាភ្លេចដែរហ្នឹង។ ភ្លេចទៅ ការចងចាំវានៅខ្វះខាតដែរហ្នឹង

គឺនៅខ្វះខាត គឺមិនបាននឹកឃើញឲ្យជាប់លាប់ដែរ។ គឺចាសប៉ុណ្ណឹងឯង។

[១៤:១៧:០១]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ប្រហែលជាខ្ញុំយល់ច្រឡំ គាត់បាននិយាយថា គាត់ភ័យខ្លាចនឹងគេតាមឃ្លាំ តាមដានមើលដែរ ប៉ុន្តែ<គាត់មិនបាននិយាយថា គាត់ពិតជាបានឃើញអ្នកណាម្នាក់បានតាមដានគាត់នោះទេ។ នេះជាអ្វីដែលខ្ញុំយល់ពីសក្ខីកម្មរបស់គាត់នៅថ្ងៃនេះ។> អ៊ីចឹងដូចខ្ញុំស្ដាប់មើលទៅ ដូចជា<មិន>មានភាពផ្ទុយគ្នា<ទេ>។

**លោក លីវ សុវណ្ណា៖**

អរគុណលោកស្រីចៅក្រម ដោយសារនេះ ជាចម្លើយដែលគាត់ឆ្លើយនេះ គឺចម្លើយរបស់សាក្សីផ្ទាល់នៅ ផ្ដល់ចម្លើយនៅសហចៅក្រមស៊ើបអង្កេត។ អ៊ីចឹងខ្ញុំបាទ ដោយសារគាត់មិនច្បាស់លាស់ ខ្ញុំបាទរំឭកថា តើគាត់ធ្លាប់បានឆ្លើយថាមិនមានអ្នកណាគេតាមដានពួកយើងទេ។ អ៊ីចឹង សំណួរចង់សួររំឭកគាត់ថាតើ គាត់រកនឹកឡើងវិញ ថាតើវាមានការតាមដានដែរទេ បាទ។

**សួរដោយលោក លីវ សុវណ្ណា៖**

**ស៖** អរគុណ។ លោកស្រីអាចនឹកមើល ថាចម្លើយរបស់លោកស្រី ដែលឆ្លើយថាមិនមានអ្នកណាគេតាមដានពួកយើងនុ៎ង តើចម្លើយហ្នឹងយ៉ាងម៉េចដែរ បាទ?

**លោកស្រី ណុប ងឹម៖**

**ឆ៖** ចម្លើយហ្នឹងគឺខ្ញុំឆ្លើយថា ខ្ញុំខ្លាច។ ខ្លាច បើគេមិនតាម ក៏ល្អ។ បើគេតាម ក៏ខ្លាច។ ហ្នឹងជាចម្លើយខ្ញុំអ៊ីចឹងឯង។ គឺខ្ញុំវាភ្លេចដែរ យូរឆ្នាំទៅហើយ ៤០ឆ្នាំហើយ។ រកនឹកមាំឃើញ វាមានវង្វេងវង្វាន់អ៊ីចឹងដែរ។ កុំប្រកាន់ខ្ញុំអី។

[១៤:១៨:៣០]

**ស៖** បាទ អរគុណលោកស្រី អត់អីទេ ខ្ញុំគ្រាន់តែបញ្ជាក់ឲ្យបានច្បាស់បន្តិច។ ចុះលោកស្រីមានដែលឮលេខាស្រុកឈ្មោះ ឡេង ឬក៏មានអ្នកណាមួយណែនាំថា បន្ទាប់ពីមានគេរៀបការហើយ ត្រូវចាត់ឲ្យឈ្លបតាមដានដែរទេ លោកស្រីដែលឮការចាត់តាំង ឬក៏បញ្ហាបែបនេះដែរទេ បាទ?

**ឆ៖** គឺចំណុចនេះ គឺគាត់អត់មានដែលនិយាយសោះ អត់ ហើយខ្ញុំក៏អត់ឮដែរ។ គាត់អត់មានដែលនិយាយទេ។ ហ្នឹងចំពោះខ្លួនខ្ញុំ រាយការណ៍ដោយត្រង់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទ អរគុណលោកស្រី។ សំណួរខ្ញុំមួយទៀត ទាក់ទងនឹងការរួមដំណេកដំបូងរបស់លោកស្រីហ្នឹង តើលោកស្រីរួមដំណេកដោយមានការបង្ខិតបង្ខំពីប្តីរបស់លោកស្រី ឬក៏ដោយសារការព្រមព្រៀងគ្នា?

**ផ៖** គឺចំពោះខ្លួនខ្ញុំ អត់មានបង្ខំ ខាងនោះក៏មិនបង្ខំដែរ សំខាន់គឺចិត្ត។ ដូចខ្ញុំថា ថាគោរពវិន័យចាត់តាំង គឺយើងនៅក្រោមគេដឹកនាំ។ ចំពោះខ្លួនខ្ញុំអ៊ីចឹង អត់មាននិយាយថាណាៗ និយាយថាណា អត់ទេ គឺចំពោះប្តីប្រពន្ធខ្ញុំអត់សោះ។ អត់មានអ្នកណាបង្ខំណា អត់ទេ។

[១៤:២០:១៣]

**ស៖** បាទ អរគុណលោកស្រី។ សំណួរខ្ញុំមួយទៀតទាក់ទងទៅនឹងរឿង តើលោកស្រីមានសង្កេតឃើញថា គូដែលរៀបការជាមួយលោកស្រី ក្រោយមកលោកស្រីបានជួបពួកគាត់វិញហ្នឹង តើពួកគាត់រួមរស់ជាប្តីប្រពន្ធជាមួយគ្នាដែរ ឬមួយក៏គាត់មិនរួមរស់ជាប្តីប្រពន្ធទេ?

**ផ៖** ចាស គឺត្រូវគ្នាទាំងអស់ រួមរស់គ្នាទាំងអស់ រហូតទល់រត់យួនហ្នឹង។ ហ្នឹងអ្នកការដំណាលខ្ញុំ។ អត់មានអ្នកណាបែកបាក់គ្នាទេ។ ចាស ខ្ញុំមានតែប៉ុណ្ណឹងឯង។

**ស៖** ចុះក្រោយឆ្នាំ១៩៧៩ ដែលថារត់យួនហ្នឹង តើលោកស្រីមានដែលបានជួបគូណាមួយដែលបានរៀបការថ្ងៃជាមួយលោកស្រីហ្នឹងដែរទេ?

**ផ៖** ចាស គឺថ្ងៃរត់ហ្នឹង រត់មកទាំងអស់គ្នា ដល់ហើយរកតែអាយុរៀងខ្លួន។ អាណាបែកទៅណាៗ គឺខ្ញុំអត់ដឹងដែរ គឺបានតែខ្ញុំមក មកពីរនាក់ប្តីប្រពន្ធរត់បែកគ្នាចូលដល់អង្គភាពគេប្រជាជន ស្រុកបរវេល រត់បែកគ្នា បាក់គ្នារហូត អត់មានជួបទេទល់ឥឡូវហ្នឹង ខ្ញុំមិនដឹងថា អាណាស្លាប់អាណារស់។

[១៤:២១:៣៨]

**ស៖** បាទ អរគុណលោកស្រី។ សំណួរខ្ញុំមួយទៀត ទាក់ទងនឹងប្រធានរបស់លោកស្រីឈ្មោះឃីម ដែលលោកស្រីបានមានប្រសាសន៍ព្រឹកមិញថា គេយកគាត់ទៅរៀបការនៅភ្នំពេញ ហើយលោកស្រីបានឆ្លើយសំណួរសហព្រះរាជអាជ្ញាថា តាម៉ុក អ្នកយក។ ប៉ុន្តែបើតាមចម្លើយរបស់លោកស្រី នៅឌី.ស៊ី.ខេម ឯកសារលេខ E3/9087 ត្រង់ ERNជាភាសាខ្មែរ 00733821, ជាភាសាអង់គ្លេស 01155586 ពុំមានជាភាសាបារាំងទេ។ នៅក្នុងនេះ លោកស្រីបានឆ្លើយថា "បងឃីម គាត់នៅភ្នំដិន។ គាត់ហ្នឹងកាលបែកនេះហើយ ពូគាត់យកគាត់មកការនៅភ្នំពេញ"។ អ៊ីចឹងខ្ញុំចង់បញ្ជាក់ថា "ពូគាត់"នេះដែលលោកស្រីឆ្លើយនេះ "ពូគាត់" តើសំដៅលើ តាម៉ុក ក៏សំដៅលើអ្នកផ្សេង?

**ឆ៖** បងឃីម មុនគាត់ អ៊ំម៉ុក យកមកការ គាត់នៅស្រែអំបិល។ ប៉ុន្តែគាត់មាននៅភ្នំដិនឯណា បងឃីម អត់ផង នៅស្រែអំបិល យកមកការនៅភ្នំពេញ។ តាម៉ុក យកមកការ។ ឈ្មោះ បងឃីមតើ មិនមែន ឃីម ឯណា។

**ស៖** បាទ ចុះនៅក្នុងចម្លើយលោកស្រីដាក់ពូគាត់ហ្នឹង តើតាម៉ុក ជាពូរបស់គាត់ ឬមួយក៏ពូគាត់អ្នកផ្សេងទេ?

**ឆ៖** ចាស មានតែខ្ញុំកាល ៧៥ -- ៧៤ នៅភ្នំដិន។ តែបងឡេង ហ្នឹងគាត់អត់មាននៅភ្នំដិនផង មានតែខ្ញុំ មានពូឯណា មានណា។ ចាស ខ្ញុំអត់ដឹងដែររឿងហ្នឹង។

**លោក លីវ សុវណ្ណា៖**

បាទ ខ្ញុំបាទអស់សំណួរលោកចៅក្រម សុំប្រគល់វេទិកាជូនសហភាគីរបស់ខ្ញុំ អន្តរជាតិដែលនឹងបន្តបាទ។ សូមអរគុណលោកស្រីដើមបណ្តឹង -- សាក្សី។

**សួរដោយចៅក្រម ក្លូឌា ហ្វេនស៍៖**

**ស៖** មុនពេលលោក<ចាប់ផ្តើម> ខ្ញុំសួរចំណុចមួយ<មិន>សំខាន់ណាស់<ណាទេ>គឺថា វាលេចឡើងនៅពេលដែលមេធាវីការពារក្តីសួរសំណួរ។ នេះគឺអំពីក្មេងស្រីអាយុ១៦ឆ្នាំពីរនាក់ ដែលរត់គេចចេញពីការបង្ខំឲ្យរៀបការ ឬក៏ការរៀបការ ហើយដែលតាម៉ុក ថាឲ្យវារត់ព្រោះវានៅក្មេងអាយុទើបតែ ១៦ឆ្នាំ។ លោកស្រីថា គូស្រករ ហ្នឹងគឺ<ត្រូវបាន>គេ<ចាប់គូឲ្យ>រៀបការ<ដោយផ្អែកទៅតាមប្រវត្តិរូបរបស់ពួកគេ>។ តើក្នុងប្រវត្តិរូបនេះគេត្រូវពិចារណាទៅដល់ថ្ងៃខែឆ្នាំកំណើតនោះផងដែរទេ?

[១៤:២៥:០៤]

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** ចាស អត់ទេ អត់មានពិនិត្យអីតាមថ្ងៃខែទេ ចាប់ដាក់តែម្តង។ អត់មានដឹង អាណាឆ្នាំអីៗ នៅស្រុកណាអីណា អត់ទេ គ្រាន់ដឹងថានៅស្រុកអ៊ីចឹង ភូមិ ឃុំអ៊ីចឹង ប៉ុន្តែដល់ឆ្នាំកំណើតអីអត់មានដឹងទេ។

**ស៖** ប្រហែលជាខ្ញុំយល់ច្រឡំ<ចំពោះអ្វីដែលលោកស្រីនិយាយ>អំពីប្រវត្តិរូប<>ហើយ។ តើត្រឹមត្រូវទេ លោកស្រីថា<ពួកគេត្រូវបាន>គេរៀបការ<ឲ្យដោយ>យោងទៅលើប្រវត្តិរូប? តើនេះសំដៅទៅលើប្រវត្តិរូបដែលគេបានសរសេរជាលាយលក្ខណ៍អក្សរ ឬ<>រៀប<ទៅតាមអ្វីដែលគេដឹង

អំពីអ្នកទាំងនោះ>?

**ឆ៖** ចាស អត់មានប្រវត្តិរូបទេ ស្គាល់។ មានប្រវត្តិរូប គេធ្វើសង្ខេបៗគ្រាន់តែថា ឈ្មោះ “ក” នៅឃុំនេះ នៅស្រុកនេះ មនុស្សស្រីនៅស្រុកនេះ ឃុំនេះអ៊ីចឹងទៅ។ ចាស គឺឲ្យទៅដឹងខែឆ្នាំអីក៏អត់ដែរ អត់មានដឹងទេ ចម្រុះអ៊ីចឹងតែម្តងចាស។ អត់មានដឹងខែឆ្នាំអីច្បាស់ទេ។

[១៤:២៦:១៩]

**ស៖** <ដូច្នេះតើគេធ្វើយ៉ាងម៉េច បើ>គេមានច្បាប់<>ថាអ្នកដែលគេផ្សំផ្គុំឲ្យរៀបការហ្នឹង ក៏មានអាយុកំណត់ណាមួយ <ប៉ុន្តែ>នៅពេល<ជាមួយគ្នា>នោះគឺថា <គេមិនបានសួរអាយុលោកស្រីទេ។ អ៊ីចឹងតើ>គេធ្វើយ៉ាងម៉េចដែរ? <តើលោកស្រីយល់សំណួរខ្ញុំទេ?>

**ឆ៖** មានអាយុ២៥ មនុស្សប្រុស។ មនុស្សស្រីត្រឹមអាយុ២០អី ប្រាំបី-ប្រាំបួនដណ្តប់អីហ្នឹងបាន។ ចាស ដូចខ្ញុំឆ្លើយខាងដើមអ៊ីចឹង។

**ស៖** ខ្ញុំយល់ហើយត្រង់ចំណុចនេះ ក៏ប៉ុន្តែតើអាជ្ញាធរធ្វើម៉េចទើបអាជ្ញាធរដឹងថា បុរសណាម្នាក់មានអាយុ២៥ឆ្នាំ ហើយស្ត្រីមានអាយុ២០ឆ្នាំ។ អ៊ីចឹងសំណួររបស់ខ្ញុំ សួរថាធ្វើម៉េចបានគេដឹងថាម្នាក់ៗមានអាយុប៉ុន្មាន?

**ឆ៖** កាលហ្នឹងខ្ញុំមិនដឹងដែរ ក្រែងលោគេលួចធ្វើឈ្មោះអីអាយុប៉ុន្មានៗ ព្រោះអីខ្ញុំអត់ដឹងដែរ។ ប៉ុន្តែបើមានបញ្ហាគឺ គេមកសួរតាមកងដែរ សួរថា “មីអូនអ្អែងអាយុប៉ុន្មានហើយ? ខ្ញុំអាយុ២២ អ៊ីចឹង, ២១អ៊ីចឹងទៅ” អ៊ីចឹងអ៊ីចេះអ៊ីចឹងដែរ។ ហ្នឹងចំពោះខ្លួនខ្ញុំបានយល់ដឹងប៉ុណ្ណឹងឯង។

**ស៖** អ៊ីចឹងគេមានសួរអាយុលោកស្រីដែរឬទេមុនលោកស្រីរៀបការនេះ?

**ឆ៖** ចាស អត់មានទេ អត់មានសួរខ្ញុំទេ ចាប់ការតែម្តង អត់មានសួរទេ មានសួរប្តីអាយុប៉ុន្មានប្រពន្ធអាយុប៉ុន្មាន ក៏អត់ដែរ។ នេះចំពោះខ្លួនខ្ញុំផ្ទាល់ អត់តែម្តង។

[១៤:២៨:០៩]

**ស៖** ដូច្នេះលោកស្រីមិនដឹងថា អាជ្ញាធរពេលនោះ ដឹងថាលោកស្រីអាយុប៉ុន្មាននោះទេ។ អ៊ីចឹងមែនទេ? <ព្រោះថា បើគេមិន>សរសេរ<>ប្រវត្តិរូប ឬក៏ទៅសួរបុគ្គល<ណាទេ> តើ<គេដឹងថា>បុគ្គលណាម្នាក់មានអាយុប៉ុន្មាននោះ<ដោយរបៀប>ណា?

**ឆ៖** ខ្ញុំវាមិនបានដឹងដែរហ្នឹងណា គឺខ្ញុំអត់បានដឹងដែរហ្នឹងណា មិនដឹងទៅសួរពីណាបានគេដឹងបើខ្ញុំអត់ដឹងហ្នឹង។ បើធ្វើប្រវត្តិរូប ខ្ញុំអត់ដែល ខ្ញុំបើគេថាប្រវត្តិរូបល្អដូចគ្នា ប៉ុន្តែបើខ្ញុំមិនដឹងដែរ។ ហើយ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អាយុខ្ញុំនិងប្ដីខ្ញុំ ខ្ញុំបងគាត់ បងប្ដីខ្ញុំ។

**ស៖** សំណួរចុងក្រោយ តើលោកស្រីអាចជម្រាបជូនតុលាការបានទេថា តើនៅពេលណាដែលក្មេងស្រីអាយុ១៦ឆ្នាំពីរនាក់ហ្នឹងរត់ហ្នឹង គឺថាក្នុងពេលគេរៀបការ ឬក៏ក្រោយពេលគេរៀបការ ឬក៏មុនពេលពិធីរៀបការនោះ?

**ឆ៖** ចាស គេកំពុងតែការ កំពុងការ វារត់ចេញទៅ។ កំពុងតែចាប់ដៃគ្នាមិនទាន់ដល់វា វារត់ចេញទៅ។ ចាស ខ្ញុំជម្រាបតាមត្រង់ ប៉ុណ្ណឹងឯង។

**ស៖** ដូច្នេះគេឈរជាជួរ គឺប្ដី ប្រពន្ធឈរជាជួរ។ អ៊ីចឹងក្មេងស្រីពីរនាក់នេះក៏រត់ចេញពីជួរហ្នឹងអ៊ីចឹងមែនទេ?

**ឆ៖** ចាស រត់ចេញៗបាត់ទៅ។ ទៅផ្ទះដេកទៅ។ គ្មានពីណាធ្វើអីវា វារត់ចេញទៅ។

**ស៖** អ៊ីចឹងតើពេលនុ៎ងជាពេលដែលគេកំពុងតែរៀបការហ្នឹងឬអី ដែល តាម៉ុក គាត់និយាយថាហៅក្មេងស្រីពីរនាក់ដែលរត់ចេញទៅ ឲ្យវារត់ទៅ វានៅក្មេងនុ៎ង?

**ឆ៖** ចាស តាម៉ុកៗគាត់អ្នកនិយាយ។ មានណាហ៊ាននិយាយជំនួសគាត់ មានតែគាត់ហ្នឹងឯង។

[១៤:៣០:១៤]

**ស៖** ខ្ញុំយល់ហើយ ក៏ប៉ុន្តែសំណួរខ្ញុំសួរថាតើ តាម៉ុក គាត់និយាយៗពេលណា? ពេលមានពិធីរៀបការក្មេងស្រីពីរនាក់ហ្នឹងរត់ចេញទៅបាន។ តើ តាម៉ុក និយាយថាឲ្យវារត់ទៅចុះវានៅក្មេងហ្នឹង ក្នុងពេលគេរៀបការហ្នឹង ឬក៏គាត់និយាយក្រោយពេលរៀបការហើយទេ?

**ឆ៖** និយាយរត់បាត់ប្រហែលពីរម៉ោង ពីរបីម៉ោង គាត់ថាឲ្យវារត់ទៅ វានៅក្មេងណាស់។ អ៊ីចេះគាត់ថាអ៊ីចឹង។ ហើយពួកគាត់ខ្ញុំអី ហៃអ៊ីតែមួយគាត់ហ្នឹងណ៎ា បាននៅស្ងៀមជាមួយគាត់ទៅ។

**ចៅក្រម ក្លូឌា ហ្វេនស៖**

សូមអរគុណ។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** សូមអរគុណលោកស្រីសាក្សី។ ខ្ញុំមានសំណួរមួយចំនួនសួរបន្តពីសហការីរបស់លោកខ្ញុំ លោក វណ្ណា។ ហើយខ្ញុំមានប្រធានបទមួយដែលត្រូវសួរលោកស្រី ហើយក៏ដូចជាប្រធានបទមួយចំនួនដែលលោកស្រីបានឆ្លើយរួចមកហើយផងដែរ។ ចំណុចទី១ ដែលខ្ញុំចង់ពិភាក្សាជាមួយលោកស្រី គឺអំពីលក្ខខណ្ឌការងារ។ <ថ្ងៃនេះ>លោកស្រីបាននិយាយអំពីស្រែអំបិលនិងសំឡូត នៅម៉ោង ១០:៣៩

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

លោកស្រីឆ្លើយទៅសហព្រះរាជអាជ្ញាថា តាម៉ុក ណែនាំ<លោកស្រី>ឲ្យ<ខំ>ធ្វើការ <ឲ្យបំពេញតួនាទី>ឲ្យបានល្អ<បំផុត ដូច្នេះហើយអ្នកទាំងអស់នោះមានអាហារហូបចុកគ្រប់គ្រាន់។> ដោយសារ<ស្រុក>នេះថ្មីសម្រាប់លោក<ស្រី និងថ្មីសម្រាប់អ្នកផ្សេងៗទៀត គេបានប្រាប់>លោកស្រី<ឲ្យ>អនុញ្ញាតឲ្យ<>ប្រជាជនហូបទាំងបាយទាំងបបរ ទាំងបាយមិនមែនតែបបរទេ។ <ដូច្នេះ សំណួរខ្ញុំគឺអំពី>អ្វីដែល<លោកស្រី>ស្ដាប់ឮពី តាម៉ុក ពាក់ព័ន្ធទៅនឹងលក្ខខណ្ឌការងាររបស់ប្រជាជន។ ខ្ញុំចង់យកចម្លើយរបស់លោកស្រីឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាពាក់ព័ន្ធនឹងពេលវេលាលោកស្រីនៅឯស្រែអំបិល។ លោកប្រធាននេះគឺឯកសារ E3/9087, ERN <ភាសាអង់គ្លេស>គឺ <01155593> <ដល់ 4>, ខ្មែរ <00733826> <ដល់> 7 <អត់មានភាសាបារាំងទេ។> លោកស្រីបាននិយាយអំពីការរែកអំបិលនៅឯស្រែអំបិល។ សូមដកស្រង់៖ “អ្នកណាម្នាក់ដែល<ដឹងថា>ឈឺ<> គឺគេអនុញ្ញាតឲ្យឈប់សម្រាក។ <អ្នកឈឺត្រូវបានគេអនុញ្ញាតឲ្យធ្វើឬកដូច>ជាអ្នកជំងឺ។ <ហើយដានី និយាយទៅកាន់លោកស្រីថា៖> តើអ្នកដែលឈឺគេអនុញ្ញាតឲ្យឈប់សម្រាកដូចអ្នកឈឺ? <លោកស្រីថា៖> ត្រឹមត្រូវហើយ។ ដានី៖ តើ តាម៉ុក មានបង្គាប់ថាដូច្នេះទេ? លោកស្រីឆ្លើយថា ចាស។ គាត់និយាយថា បើសិនណាអ្នកណាម្នាក់ឈឺកុំឲ្យគេធ្វើការងារ។ <ដានី សួរ៖> តើគាត់បានប្រាប់អ៊ីចឹងមែនទេ? លោកស្រីថា ចាស គឺគាត់បានប្រាប់អ៊ីចឹងមែន ហើយយើងធ្វើតាមការណែនាំរបស់គាត់។” ដូច្នេះលោកស្រីបានឆ្លើយថា តាម៉ុក បានប្រាប់ទៅលោកស្រីថា កុំប្រើមនុស្សដែលឈឺ។ តើលោកស្រីនៅចាំទេ តើលោកស្រីទទួលការណែនាំ ឬក៏បញ្ហានេះនៅក្នុងពេលប្រជុំណាមួយ ឬក៏ពេលណា?

[១៤:៣៣:១៦]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន ខ្ញុំធ្វើការកត់សម្គាល់មួយ។ បើសិនជាខ្ញុំ<>យល់គាត់មិនច្រឡំទេនោះ គឺកត្តាសំណួររបស់គាត់ហ្នឹងទាក់ទងនឹងស្រែអំបិល។ អ៊ីចឹង ខ្ញុំសូមរំឮកដល់អង្គជំនុំជម្រះថាទីតាំងនេះគឺដកចេញពីសំណុំរឿង០២/២ នេះហើយ។ <ព្រោះវា>ជាទីតាំង<មួយ>ដែលត្រូវ<បានសិក្សានៅឡើយ>នៅវគ្គក្រោយ<គឺសំណុំរឿង០០៣>។ អ៊ីចឹងកាលណាយើងនិយាយអំពីទីតាំងស្រែអំបិលនេះ វាក្រៅវិសាលភាពនៃសំណុំរឿងយើងនេះហើយលោកប្រធាន។

**លោកស្រី ដូរីន ជិន៖**

លោកប្រធាន តើខ្ញុំអាចធ្វើការឆ្លើយតបជាសង្ខេបបានទេ?

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:៣៥:២០]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងលោកស្រីចង់ធ្វើ<សេចក្តីថ្លែងការណ៍បន្តទៀត ឬក៏ចង់បញ្ជាក់?>

**លោកស្រី ដូរីន ជិន៖**

<យើងដឹងថា>វានៅក្រៅវិសាលភាពៗនៃការជំនុំជម្រះ។ <ខ្ញុំគ្រាន់តែចង់សួរសំណួរបីអំពីបញ្ហានេះ គឺផ្អែកលើ>សេចក្តីសម្រេចមុនអង្គជំនុំជម្រះថា យើងអាចសួរសំណួរ<ទូទៅ>តិចតួចបាន<ពេលណាចូលដល់សួរអំពីបញ្ហាគោលនយោបាយ។ គោលនយោបាយអំពីលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារ គឺជាអ្វីដែលត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿងយើងនេះ។ ស្រែកអំបិលក៏ត្រូវបានចោទប្រកាន់នៅក្នុងសំណុំរឿង០០២ដែរ មុនពេលវាត្រូវបានផ្តាច់ចេញពីសំណុំរឿងនេះ>។ ហើយជាទូទៅ គឺយើងនិយាយជាច្រើននៅសវនាការថ្នាក់ វគ្គទី១ និយាយអំពី តាម៉ុក <និងគោលនយោបាយរបស់គាត់>។ យើងនិយាយអំពីកម្មាភិបាលនិរតី។ យើងនិយាយពីកន្លែងផ្សេងៗគ្នានៅឯភូមិភាគនិរតី <ប៉ុន្តែជាទូទៅគឺសំដៅទៅលើតាម៉ុក>។

[១៤:៣៦:០៤]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

តើលោកស្រីដឹងពីចំនួនឯកសារដែលនិយាយអំពីលក្ខខណ្ឌការងារនៅស្រែអំបិលហ្នឹងទេ<នៅក្នុងសំណុំរឿងនេះ>? បើសិន ជាយើងចាប់ពិភាក្សាអំពីប្រធានបទស្រែអំបិលនេះហ្នឹង គឺវាត្រូវការចំណាយពេលវេលាច្រើនណាស់។

**លោកស្រី ដូរីន ជិន៖**

សំណួរខ្ញុំគ្រាន់តែសួរថា តើគាត់មានបានស្តាប់ឮសម្តីនេះពី តាម៉ុក ឬក៏អត់? <សាក្សីបាននិយាយជាទូទៅអំពីការដែលគាត់និយាយជាមួយ តាម៉ុក នេះបើតាមខ្ញុំយល់ គឺ>គាត់ថាគាត់បានស្តាប់

តាម៉ុក ផ្ទាល់មាត់ពីរបីដង។ <ដូច្នេះវាគួរឲ្យចាប់អារម្មណ៍សម្រាប់ខ្ញុំ> ខ្ញុំគ្រាន់តែសួរថា <តើ>ក្នុងកាលៈទេសៈពិសេសនេះ<ឬ ដែល>គាត់<បានស្ដាប់>ឮ<ការបញ្ជាពី>តាម៉ុក<>។ អ៊ីចឹងប្រសិនណាជាអាចសួរបាន ខ្ញុំនឹងបន្តទៅទៀត។

**ប្រធានអង្គជំនុំ៖**

អនុញ្ញាត លោកមេធាវីសួរសំណួរហ្នឹងបាន។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** <>ខ្ញុំ<នឹង>សួរខ្លីទេ។ លោកស្រីសាក្សី តើលោកស្រីនៅចាំសំណួរអំមិញទេ? អ្វីដែលខ្ញុំសួរលោកស្រី គឺថាលោកស្រីបានឆ្លើយថា តាម៉ុក បានណែនាំដោយគាត់មិនឲ្យប្រើប្រាស់អ្នកដែលឈឺឲ្យទៅធ្វើការនោះទេ។ តើលោកស្រីបានស្ដាប់ឮសួរការណែនាំពី តាម៉ុក នៅក្នុងពេលប្រជុំ ឬ<តាមរយៈការបញ្ជា>?

[១៤:៣៧:២៦]

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** ចាស គឺពេលគាត់ -- អត់មានប្រជុំទេ គាត់ដើរមកដល់គាត់ប្រាប់អ៊ីចឹងតែម្ដង។ អត់មានបានប្រជុំទេ ហើយគាត់វិញទៅ។ ខ្ញុំស្ដាប់បានប៉ុណ្ណឹង។ បើអាណាឈឺកុំឲ្យវាធ្វើការ ពេលដំបៅជើងដំបៅដៃរែកអំបិលទៅ វារីក។ គាត់ប្រាប់ហើយគាត់ទៅវិញទៅ អត់មានបានប្រជុំបានអីផង។ ចាសអាហ្នឹងឆ្លើយឲ្យពិតហ្នឹងហ្មង។

**ស៖** តើគាត់មានបាននិយាយថា អ្នកដែលឈឺនុំងត្រូវតែធ្វើការដែរឬក៏អត់ទេ?

**ឆ៖** ចាស អត់ឲ្យទៅ គ្នាអត់ទៅដែរតើ។ បើអត់ប្រាប់គ្នាទៅហ្នឹងឯង ប៉ុន្តែប្រាប់អ៊ីចឹងអត់ទៅដែរតើ។

[១៤:៣៨:១២]

**ស៖** ហើយខ្ញុំ<សន្យាថា>នឹងសួរតែបីសំណួរទេ។ អានេះសំណួរទី<៣ តើ>លោកស្រី<ចាំទេពេលណាដែល>លោកស្រីបានទទួល<>ការ<ណែនាំ>ពី តាម៉ុក<>?

**ឆ៖** ចាស តាម៉ុក គាត់ប្រាប់អ៊ីចឹង។ ខ្ញុំទទួលគាត់បានអ៊ីចឹង។

**ស៖** នេះ គឺ<នៅពេល>ដែលលោកស្រី<ធ្វើការ>នៅវាលស្រែអំបិលមែនទេ?

**ឆ៖** ចាស អត់បានប្រជុំទេ។

**លោកស្រី ដូរីន ជិន៖**

ប្រហែលជាដល់ពេលសម្រាកសិនហើយលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។

អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅ។

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៩ នាទី ដល់ម៉ោង ១៤:៥៨ នាទី)*

[១៤:៥៨:១២]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយ!

សូមអញ្ជើញលោកស្រីមេធាវីការពារលោក នួន ជា បន្តសំណួរ។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** ជម្រាបសួរម្តងទៀតលោកស្រីសាក្សី។ ឥឡូវនេះ ខ្ញុំបន្តទៅវគ្គផ្សេង។ ខ្ញុំចង់សួរលោកស្រីអំពីមូលហេតុដែល<តាម៉ុក>បញ្ជូនលោកស្រីទៅភូមិភាគពាយ័ព្យ។ នៅម៉ោង ១០:២៩ ព្រឹកមិញនេះ <លោកស្រីបាននិយាយថា៖> "តាម៉ុក ណែនាំឲ្យលោកស្រីធ្វើការឲ្យខ្លាំង គឺបំពេញភារកិច្ចឲ្យបានខ្លាំង ដើម្បីឲ្យមានអាហារគ្រប់គ្រាន់ ហើយដោយសារជាតំបន់ថ្មី<សម្រាប់>លោកស្រី<និងអ្នកផ្សេងៗទៀត។ គេបានប្រាប់លោកស្រីឲ្យអនុញ្ញាតឲ្យប្រជាជន>ហូបបបរ និងហូបបាយផងដែរ <មិនមែនតែបបរទេ">។ ក្រោយមកនៅម៉ោង ១០:៥៣ ដែលឆ្លើយទៅសហព្រះរាជអាជ្ញានិយាយអំពី "តើមានអ្វីកើតឡើងចំពោះអតីតកម្មាភិបាលនៅភូមិភាគពាយ័ព្យ? ហើយលោកស្រីនិយាយថា "គេចោទអ្នកទាំងនោះថាជាជនក្បត់ ដោយសារគេមិនឲ្យប្រជាជនហូបគ្រប់គ្រាន់។" អ៊ីចឹងតាមអ្វីដែលលោកស្រីយល់ តើតាម៉ុក ចាត់តាំងឲ្យលោកស្រីនៅសំឡូតនោះ ដោយសារតែកម្មាភិបាលពីមុននៅទីនោះមិនឲ្យអាហារប្រជាជនហូបគ្រប់គ្រាន់ឬដូចម្តេច?

**ឆ៖** ខ្ញុំឆ្លើយថាម៉េច បើនិយាយអត់ -- បកប្រែអត់ដឹងផង។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីតាំងសំណួរសាជាថ្មី សាក្សីអត់យល់ពីសំណួរនេះទេ។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** សាក្សី ខ្ញុំអានសេចក្ដីដកស្រង់ពីសក្ខីកម្មរបស់លោកស្រីព្រឹកមិញទៅសហព្រះរាជអាជ្ញា លោកស្រីនិយាយថា កម្មាភិបាលចាស់នៅភូមិភាគពាយ័ព្យ គេចោទអ្នកទាំងនោះថាជាខ្មាំង ជាជនក្បត់ ដោយសារគេមិនឱ្យអាហារប្រជាជនហូបគ្រប់គ្រាន់។ អ៊ីចឹង សួរលោកស្រីថា នៅពេលដែលគេចាត់តាំងឱ្យលោកស្រីទៅធ្វើការនៅសំឡូតហ្នឹង ដោយសារកម្មាភិបាលពាយ័ព្យនៅទីនោះពីមុននោះ គឺមិនឱ្យប្រជាជនហូបគ្រប់គ្រាន់ ទើបគេប្ដូរ។ តើយ៉ាងដូច្នេះ ឬយ៉ាងណា?

[១៥:០១:១៤]

**លោកស្រី ណុប ងឹម៖**

**ឆ៖** អត់។ អត់ឮសំឡេងផង ឱ្យខ្ញុំឆ្លើយថាម៉េច!

**ស៖** លោកស្រីសាក្សី តើស្ដាប់ខ្ញុំឮទេ ពេលនេះ?

**ឆ៖** ចាស ឮៗ។

**ស៖** អ៊ីចឹង ខ្ញុំចាប់ផ្ដើមជាថ្មីម្ដងទៀត។ អ្វីដែលខ្ញុំចង់សួរលោកស្រីនោះ គឺថាមូលហេតុពីដំបូង <ដែល តាម៉ុក>បញ្ជូនលោកស្រីទៅភូមិភាគពាយ័ព្យ។ លោកស្រីបានឆ្លើយទៅសហព្រះរាជអាជ្ញាព្រឹកមិញនេះ គឺថា គឺសូមដកស្រង់នៅម៉ោង ១០:៣៩ និយាយថា តាម៉ុក ណែនាំឱ្យលោកស្រីធ្វើការឱ្យខ្លាំង ហើយបំពេញភារកិច្ចឱ្យល្អ ដើម្បីឱ្យប្រជាជនហូបគ្រប់គ្រាន់។ ដោយសារស្រុកហ្នឹងគឺជាកន្លែងថ្មីសម្រាប់លោកស្រី និងអ្នកផ្សេងទៀត ហើយក៏លោកស្រីថា <គេប្រាប់លោកស្រីឱ្យអនុញ្ញាត>ឱ្យហូបទាំងបបរនិងបាយផងដែរ <មិនមែនតែបបរទេ>។ ក្រោយមក ម៉ោង<១០:៥៣>ហ្នឹង គឺថា ឆ្លើយទៅនឹងសហព្រះរាជអាជ្ញា លោកស្រីថា កម្មាភិបាលពាយ័ព្យនៅទីនោះចាស់នោះ គឺត្រូវបានគេចោទថាជាជនក្បត់ ដោយសារមិនឱ្យប្រជាជនហូបគ្រប់គ្រាន់។ អ៊ីចឹង តាមអ្វីដែលលោកស្រីយល់ តើគេចាត់តាំងលោកស្រីឱ្យទៅធ្វើការនៅសំឡូតហ្នឹង គឺថាមូលហេតុអី ដោយសារតែកម្មាភិបាលពាយ័ព្យចាស់ហ្នឹងគេជាជនក្បត់ មិនឱ្យប្រជាជនហូបគ្រប់គ្រាន់ ឬយ៉ាងម៉េច?

[១៥:០៣:២១]

**ឆ៖** ចាស ខ្ញុំក៏ -- គឺគាត់នាំទៅសំឡូតហ្នឹង គឺថាគាត់ប្រាប់ថា កុំឱ្យប្រជាជនកាលមុននៅជាមួយពួកក្បត់ ប្រជាជនណា ប្រជាជនស្រុកសំឡូត ដូចខ្ញុំនិយាយព្រឹកមិញអ៊ីចឹង។ ដល់ ក៏ពួកយើងខ្ញុំក៏

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ថា ហូបបបរខ្លះ បាយខ្លះ ហើយក្នុងពេលនោះ ក៏គាត់ -- សួរវែងពេក ខ្ញុំស្ដាប់អត់បាន ចាំអត់បានទេនេះ សួរវែងពេក។ បើចាប់ចំណុចៗ ខ្ញុំចាំបាន។ សូមអភ័យទោស ខ្ញុំចាំអត់បាន តែសួរវែងពេក។

**ស៖** សូមអភ័យទោស។ អ៊ីចឹង ខ្ញុំអានពីអ្វី<ដែលលោកស្រីបាននិយាយនៅក្នុងតុលាការនេះ និងនៅក្នុងឯកសារ> ដើម្បីឲ្យលោកស្រីយល់ <ហើយឆ្លើយនឹងសំណួររបស់ខ្ញុំ ដោយសារខ្ញុំត្រូវ>សួរ<លោកស្រីនូវបញ្ហាជា>ច្រើន<ខុសៗគ្នា> ប៉ុន្តែខ្ញុំនឹងសួរខ្លីជាងមុន។ ចំណុចមួយដែលលោកស្រីនិយាយ<អំពីប្រធានបទនេះ> នៅក្នុង<>ចម្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជានោះ <ខ្ញុំមិនបានស្ដាប់ឮនៅថ្ងៃនេះទេ ដូច្នេះ ខ្ញុំចង់ផ្ទៀងផ្ទាត់ចំណុចនោះជាមួយលោកស្រី។ នេះគឺជាបទសម្ភាសន៍ដែលលោកស្រីបានឆ្លើយកាលពី>៥ឆ្នាំទៅហើយ ដែលលោកស្រីឆ្លើយទៅ ឡុង ដានី។ ឯកសារ គឺ E3/9087, ERN អង់គ្លេស 01155598 ហើយនៅក្នុងភាសាខ្មែរ 00733829 មិនមានជាអត្ថបទបារាំងទេ។ លោកស្រីសាក្សី ខ្ញុំនឹងសួរបែបនេះ។ ឡុង ដានី សួរថា៖ "ហេតុអីបាន<ជា តាម៉ុក ប្រាប់>ឲ្យលោកស្រីទៅសំឡូត? ហើយលោកស្រីឆ្លើយថា៖ គាត់ប្រាប់យើងថា ក្រុមអាភឹម ក្បត់។" ហើយក្រោយមកលោកស្រីនិយាយថា "គេមិនឲ្យប្រជាជនហូបបាយទេ។ <សូម្បីតែចានសម្រាប់ហូបបាយក៏គ្មានផង> គឺថាហូបបាយនឹងដៃ។ <គាត់ប្រមូលយកចានទាំងអស់។> អ៊ីចឹងគឺថា<គាត់>ជាជនក្បត់។ ហើយក៏គេមិនឲ្យប្រជាជនបេះដូងអ្វីហូបដែរ។" ចប់សេចក្ដីដកស្រង់។ អ៊ីចឹងខ្ញុំសួរលោកស្រីបែបនេះវិញ--

**ឆ៖** ចាស គឺគាត់បាននិយាយអ៊ីចឹងមែន។

**<លោក នីកូឡាស គូមជែន៖>**

<សូមទោសលោកប្រធាន។ វាហាក់ដូចជាមេធាវីការពារក្ដី-->

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

[១៥:០៥:៤៣]

**លោក នីកូឡាស គូមជែន៖**

សូមអរគុណលោកប្រធាន។ មេធាវីបានអាន<>ឃ្លា<មួយនៃចម្លើយដែលពន្យល់ថា ភឹម ជា នរណា> ដែល<សាក្សីគាត់និយាយពី ភឹម នោះ។> នៅក្នុងបទសម្ភាសន៍ទាំងស្រុងហ្នឹង <គឺវាច្បាស់ណាស់> គាត់និយាយថា៖ "អាភឹម ដែលត្រូវបាន<>អង្គការចាត់ឲ្យនៅសំឡូត<គឺជាជនក្បត់>។" គាត់បាននិយាយ<អំពី> ភឹម ជាអតីតលេខាស្រុកនោះទេ។ <ដូច្នេះ លោកចៅក្រម សាក្សីគាត់អត់>

មានការភ័ន្តច្រឡំ<ទេ>។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** សូមអរគុណលោកសហព្រះរាជអាជ្ញា អ៊ីចឹងគឺខ្ញុំមិន<បាន>ធ្វើឲ្យសាក្សីភ័ន្តច្រឡំទេ។ ខ្ញុំមិនសួរនាំមុខទេ។ <ខ្ញុំនឹងសួរសំណួរបើក ដើម្បីចង់ដឹងថា តើគាត់ចងចាំអ្វីខ្លះនៅពេលនេះ> ខ្ញុំនឹងសួរខ្លីៗទៅគាត់។ តើលោកស្រីចាំទេ ភឹម ហ្នឹងជា<អ្នកណា? តើគាត់ពិតជា>បុគ្គលដូចដែលសហព្រះរាជអាជ្ញាលើកឡើងថា គាត់ជាអភិបាល ឬក៏ជាលេខាស្រុកចាស់ ឬក៏ដូចម្តេច?

**លោកស្រី ណុប ង៉ីម៖**

**ឆ៖** ចាស ខ្ញុំអត់ដឹងដែរ អត់ដឹងថា ថានៅស្រុកសំឡូតៗ ប៉ុនអត់ដឹងគាត់ធ្វើមេស្អី លេខាស្អីៗអត់ដឹងដែរ ខ្ញុំ។ អត់ដែលឃើញមុខគាត់ផង ឮគេថា ឮតែគេនិយាយ ឮតាម៉ុកនិយាយ។ អត់មានដឹងថាគាត់ធ្វើមេអីៗអត់ដឹង។ នៅស្រុកសំឡូតហ្នឹង ប្រធានស្រុកសំឡូតហ្នឹងហើយ។ បែបអ៊ីចឹងហើយមិនស្រួល បានគាត់ថាអ៊ីចឹង។ ហើយហ្នឹង ខ្ញុំដឹងតែប៉ុណ្ណឹងឯង។

[១៥:០៧:១០]

**ស៖** អ៊ីចឹងយើងបន្តទៅទៀត។ យើងនិយាយអំពីសំឡូតដដែល ហើយយើងនិយាយពីរបបអាហារ។ ប៉ុន្តែនៅពេលនេះ យើងនិយាយអំពីការពិភាក្សារបស់លោកស្រី ជាមួយសហព្រះរាជអាជ្ញាដែលថាបញ្ជូនស្រូវអង្ករទៅថ្នាក់លើ គឺខ្ញុំដកស្រង់ គឺនៅម៉ោង១១:០៣ គឺថា៖ “យើងបង្កបង្កើនផលស្រូវហើយទុកខ្លះសម្រាប់មូលដ្ឋាន ហើយមួយចំនួនទៀតបញ្ជូនទៅថ្នាក់លើ។ ហើយមិនដឹងថា គេបែងចែកម្តេចទេ នៅក្នុងសហករណ៍។” គឺថាម៉ោង ១១:០៥ គឺថា៖ “អង្ករស្រូវមួយចំនួន<ត្រូវបានបញ្ជូន>ទៅថ្នាក់លើ ហើយខ្លះទុក<ដើម្បីប្រើប្រាស់> ប៉ុន្តែលោកស្រីមិនដឹងថាយកទៅថ្នាក់លើនៅកន្លែងណាទេ។” លោកស្រីសាក្សី <តាមដែលលោកស្រីអាចចងចាំបាន> សហព្រះរាជអាជ្ញាបានអានសេចក្តីដកស្រង់ជាចម្លើយរបស់លោកស្រីពីព្រឹកមិញ <ទាក់ទងនឹងការ>បញ្ជូនអង្ករទៅថ្នាក់លើ <ហើយបន្ទាប់មកលោកស្រីបានឆ្លើយនឹងសំណួរនោះ>។ អ៊ីចឹងអ្វីដែលខ្ញុំ<ចង់ធ្វើនោះ គឺអានសំណួរនោះ>ឲ្យលោកស្រី<ឲ្យបានពេញលេញ ដូច្នេះ>ខ្ញុំ<អាចសួរ>លោកស្រី<នូវសំណួរមួយចំនួនទៀត>។ លោកប្រធាន គឺឯកសារ E3/9087, ERN ដែលសហព្រះរាជអាជ្ញាអានហ្នឹងគឺថា <01155611> ក្នុងភាសាអង់គ្លេស, ខ្មែរ 00733839 ដល់ 40 ជាភាសាខ្មែរ, មិនមានជាភាសាបារាំងទេ។ នេះជាផ្នែកដែលសហព្រះរាជអាជ្ញាអានលោកសាក្សីស្តាប់។ <លោកស្រីបាននិយាយថា៖> “នៅពេលដែលយើងចង់លើកកម្ពស់ខ្លួន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

គេ គេបង្អត់ប្រជាជន។ គេឲ្យប្រជាជនហូបបបរ រីឯស្រូវនិងអង្ករនៅសល់។" បន្ទាប់មក គឺលោកស្រីនិយាយថា "គេបានបញ្ជូនស្រូវ<> អង្ករដែលនៅសល់ហ្នឹងជូនទៅថ្នាក់លើ។"

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹងគឺថា តើលោកស្រីសាក្សីតាមទាន់ទេ? <ព្រោះខ្ញុំគិតថា គាត់ទើបតែឆ្លើយរួចហើយ ហើយខ្ញុំមិនច្បាស់ថា តើវាមិនមានការភ័ន្តច្រឡំ ឬក៏អត់នោះទេ។ តើ>ស្តាប់យល់ទេ អំពីអ្វីដែលមេធាវីការពារក្តីនិយាយឲ្យលោកស្រីស្តាប់មិញនេះ ដកស្រង់មិញនេះ?

[១៥:០៩:១៩]

**លោកស្រី ណុប ងីម៖**

**ឆ៖** គឺខ្ញុំក៏សុំមាន គឺរឿងធ្វើស្រូវបានហើយ ដឹកយកទៅណា ទៅទុកឲ្យសហករណ៍ គាត់យកទៅណាៗ ខ្ញុំអត់ដឹង អត់ទេ អត់តាមដានផង។ អត់ដឹង។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** លោកស្រីសាក្សី ខ្ញុំនឹងអាន<នូវ>ចម្លើយដែលលោកស្រី<ឆ្លើយ>ទៅដល់មជ្ឈមណ្ឌលឯកសារកម្ពុជានោះ <គឺចម្លើយនេះព្រះរាជអាជ្ញាមិនបានអានជូនលោកស្រីស្តាប់ព្រឹកមិញនេះទេ។ នៅពេល>ដែល<លោកស្រី>និយាយ<ជាមួយ>មជ្ឈមណ្ឌលឯកសារកម្ពុជា និយាយអំពីកម្មាភិបាលថ្នាក់ក្រោម ដែលគេចង់លើកកម្ពស់ខ្លួនគេ គេបង្អត់ប្រជាជន។ នៅពេលនោះ ឡុង ដានី សួរទៅលោកស្រី "<>លោកស្រី<បាន>បញ្ជាក់ថា មានមនុស្សមួយចំនួនតូចស្លាប់។ ហេតុអីក៏មនុស្សមួយចំនួន ដ៏ច្រើនស្លាប់នោះ? តើបង្កឡើងដោយកម្មាភិបាល<ថ្នាក់ក្រោមនោះ>ឬ?" ហើយលោកស្រីឆ្លើយថា៖ "<មេដឹកនាំ>ថ្នាក់ក្រោម<ក្រអឺតក្រទមខ្លាំងណាស់> គេចង់បង្ហាញខ្លួនគេថាពូកែ ហើយគេបានបង្អត់ប្រជាជន គេចង់បានមុខមាត់"។ អ៊ីចឹងខ្ញុំសួរថា តើលោកស្រីចង់និយាយដូចម្តេចថា កម្មាភិបាលថ្នាក់ក្រោមនោះគេ ដូចថាឃោរឃៅ ហើយគេចង់លើកមុខមាត់របស់គេ ទើបបង្អត់ប្រជាជន។ តើមានន័យដូចម្តេច?

**ឆ៖** ខ្ញុំ -- គាត់និយាយអំមិញអត់ឮផង ខ្ញុំនិយាយគាត់អត់ឮផង ដល់នេះ ខ្ញុំស្តាប់ម៉េចបាន មិនដឹងបកប្រែថាម៉េច មិនដឹងនិយាយថាម៉េច អត់ឮគាត់និយាយផងៗ។

[១៥:១១:១៦]

**ស៖** ខ្ញុំមិន<ច្បាស់ថា> តើវាបញ្ហាបច្ចេកទេស ឬក៏សំណួរខ្ញុំវែងពេក តើលោកស្រីស្តាប់ឮទេ?

**ឆ៖** ធុរពេកស្តាប់អត់បានទេ។

**ចៅក្រម ក្ឫត្តា ហ្វេនស៍៖**

ប្រហែលជាគាត់ស្តាប់មិនឮទេមើលទៅ។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** សាក្សី លោកស្រីឮខ្ញុំទេ?

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** និយាយអត់ឮផង។

**ស៖** ឥឡូវឮហើយឬនៅលោកស្រី?

**ឆ៖** ឮ។

**ស៖** ខ្ញុំអានសេចក្តីដកស្រង់យ៉ាងវែងពីចម្លើយរបស់លោកស្រី។ ប៉ុន្តែចំណុចនេះ គឺថាលោកស្រីបានឆ្លើយថា <មេដឹកនាំ>ថ្នាក់ក្រោមហ្នឹងគឺគេចង់បានមុខមាត់ ហើយគេមិនល្អទេ គេចង់បានមុខមាត់ដោយបង្អត់ប្រជាជន។ តើពាក្យនេះ លោកស្រីចង់សំដៅអត្ថន័យដូចម្តេច?

**ឆ៖** ពាក្យហ្នឹង គឺខ្ញុំបានឆ្លើយគឺ ហ្នឹងពាក្យសម្តីហ្នឹង។ ខ្លះដូច ខ្ញុំថាចង់បានមុខបានមាត់ហ្នឹងដូចមានខ្លះគេចង់បានមុខបានមាត់ គេឲ្យបាយប្រជាជនហូបអត់ឆ្អែតអីចឹងទៅ។ ហើយខ្ញុំអត់ចង់បាន ខ្ញុំឲ្យហូបឆ្អែតៗហ្នឹងហើយ ចង់បានអីមុខមាត់ ឲ្យតែប្រជាជនរស់។

**ស៖** តាមអ្វីដែលលោកស្រីយល់ តើអំពើដែលបង្អត់ប្រជាជនដើម្បីមុខមាត់របស់ខ្លួនហ្នឹងជាអំពើដោយកម្មាភិបាលភូមិភាគពាយ័ព្យហ្នឹង គឺមុនពេលដែលលោកស្រីទៅដល់សំឡូតហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** ខ្ញុំទៅដល់សំឡូត អត់ដឹងកម្មាភិបាលណា មិនដឹងផង។ មានកម្មាភិបាល ភឹមៗ ហ្នឹងឮគេនិយាយហ្នឹង។ ដូចខ្ញុំប្រាប់ជម្រាបខាងដើមពីព្រឹកអីចឹងឯង ឮតែឈ្មោះទេ ខ្ញុំមិនដែលឃើញទេ។

[១៥:១៣:៤២]

**ស៖** តើលោកស្រីដឹងទេថា តាម៉ុក យកភឹម ទៅ<ពាយ័ព្យ> ឬក៏ ភឹម ហ្នឹងគាត់នៅនោះមុនហ្នឹងស្រាប់ទៅហើយ?

**ឆ៖** ចាស អត់ទេ ដឹង តាភឹម ហ្នឹងមិនដឹងនៅឯណា តាម៉ុក មកមិនឃើញ តាភឹម ហ្នឹងផងហ្នឹង។ ខ្ញុំក៏មិនឃើញ ណាក៏មិនឃើញដែរ ឮសូរតែឈ្មោះហ្នឹង។ ខ្ញុំឆ្លើយពីមុនមកអីចឹងដែរតើ ឮសូរតែឈ្មោះទេ ខ្ញុំអត់ដែលស្គាល់ទេ។ ពួកទៅជាមួយខ្ញុំក៏មិនដែលស្គាល់ដែរ ទៅសំឡូតជាមួយគ្នាហ្នឹង។

**ស៖** តើលោកស្រីធ្លាប់ឮហេតុការណ៍ណាប្រហាក់ប្រហែលនេះទេ ដែលថាកម្មាភិបាលថ្នាក់ក្រោមចង់ការពារមុខមាត់ ចង់បានមុខមាត់នោះ គេមិនឲ្យប្រជាជនហូបឲ្យគ្រប់ទេ ហើយឲ្យប្រជាជនមានការឈឺចាប់លំបាក តើមានករណីផ្សេងខុសពីហ្នឹងទៀតទេ?

**ផ៖** អត់ ពួកខ្ញុំអត់មានអីចឹងទេ ប៉ុនអាចក្រែងលោពួកគេ។ មានគេនិយាយប្រៀបធៀបទេ អាហ្នឹងនោះ ប្រៀបធៀបខ្លាចមាន ប៉ុន្តែវាមានខ្លះ វាមិនអត់ទេ តាមអង្គភាពមួយៗ ចេះតែការពារកន្លែងហ្នឹងកុំឲ្យមាន។ ចាស មានតែប៉ុណ្ណឹងទេខ្ញុំ។

**ស៖** អរគុណលោកស្រីសាក្សី។ ខ្ញុំនឹងសួរសំណួរអំពីប្រធានបទពាក់ព័ន្ធ ប៉ុន្តែខុសពីមុនបន្តិច។ សំណួរពេលនេះគឺថា តើៗលោកស្រីស្គាល់<នរណា>ម្នាក់ឈ្មោះ អៀង ធីរិទ្ធ ដែរឬទេ?

**ផ៖** អត់ អត់មានថាផង អត់មានឈ្មោះ អៀង ធីរិទ្ធ ផង។ មានតែឈ្មោះ អារិទ្ធនីរសារ។ ឈ្មោះ រិទ្ធ នីរសារហ្នឹងមាន។ នីរសារស្រុកសំឡូតហ្នឹង នីរសារ បងឡេង ហ្នឹងមាន។ ឈ្មោះថា កម្មាភិបាលឈ្មោះ រិទ្ធ អត់ទេ។ រិទ្ធ នោះ រិទ្ធ គ្នានៅស្មើរដែរហ្នឹង។ ខ្ញុំដែលថាតែអីចឹង។

[១៥:១៥:៥៦]

**ស៖** តើលោកស្រីចាំដែរឬទេ ថាតើរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចក្នុងសម័យកម្ពុជាប្រជាធិបតេយ្យគាត់ឈ្មោះអ្វីដែរ?

**ផ៖** រដ្ឋមន្ត្រីខ្ញុំអត់ស្គាល់ទេ អត់ទេខ្ញុំ ស្គាល់ត្រឹមថ្នាក់ក្រោមៗអីខ្ញុំស្គាល់ហ្នឹង ថារដ្ឋមន្ត្រីអត់ទេ អត់ស្គាល់ទេខ្ញុំ។

**ស៖** មិនថ្វីទេលោកស្រីសាក្សី ប៉ុន្តែខ្ញុំនឹងអានចម្លើយមួយផ្នែកដោយស្ត្រីម្នាក់ឈ្មោះ អៀង ធីរិទ្ធ ដែលគាត់ជាអតីតរដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនៅសម័យកម្ពុជាប្រជាធិបតេយ្យ។ គាត់និយាយថា គាត់បានទៅភូមិ<ភាគ>ពាយ័ព្យ ហើយគាត់បានសង្កេតឃើញអំពីជីវភាពរស់នៅ ហើយនិងរបបអាហារនៅភូមិភាគ ពាយ័ព្យ។ ខ្ញុំនឹងអានពីរវគ្គនៃបទសម្ភាសន៍របស់គាត់ ដើម្បីដាក់ព័ត៌មាននេះឲ្យលោកស្រីស្ដាប់មើល ហើយខ្ញុំនឹងសួរថា តើលោកស្រីមានប្រតិកម្មដូចម្ដេច។ លោកប្រធាន ឯកសារ E3/659 ឯកសារយោង<ជាភាសាអង់គ្លេស>គឺថា 00182322, ខ្មែរ 00741117 ដល់ 18 ហើយនិងជាភាសាបារាំង 00743047។ លោកស្រីសាក្សី នេះជាសម្ដី ព័ត៌មានអំពីថា អៀង ធីរិទ្ធ គាត់ទៅភូមិភាគពាយ័ព្យ។ គាត់និយាយថា៖ "ខ្ញុំបានធ្វើដំណើរទៅមើលលក្ខខណ្ឌជីវិត ជីវភាពរបស់ប្រជាជន ហើយ<>នៅពេលខ្ញុំត្រឡប់វិញ ខ្ញុំរាយការណ៍ទៅមេដឹកនាំ<ថា> មាន<ភាព>ចម្លែកនៅតាមខេត្តមួយ<>ចំនួន។

ដូចជានៅបាត់ដំបង។ ខ្ញុំបានឃើញអ្វីៗ<ចម្លែកខ្លាំងណាស់> ដែលគេបានធ្វើឲ្យប្រជាជនទាំងអស់ទៅធ្វើស្រែ នៅឆ្ងាយពីភូមិ ហើយគេអត់មានផ្ទះនៅ ហើយខ្ញុំបានឃើញថាគេអត់មានផ្ទះសម្បែងទេ ពួកគេមានជំងឺស្ទើរតែទាំងអស់។ ហើយខ្ញុំបានរាយការណ៍ទៅមេដឹកនាំខ្ញុំពេលនោះ។"

[១៥:១៨:២៣]

បន្ទាប់មក គាត់បាននិយាយបែបនេះថា៖ "នៅពេលនោះ ខ្ញុំបានប្រាប់មេដឹកនាំរបស់ខ្ញុំថា គឺមានបញ្ហាកំហុសនៅទីនោះ <ដោយសារខ្ញុំដឹងពីទិសដៅរបស់នាយករដ្ឋមន្ត្រី>។ ហើយខ្ញុំឃើញថា អ្នកនោះមិនមាន ឃើញកុមារ <មនុស្សចាស់ ស្ត្រីមានផ្ទៃពោះ> ស្ត្រីបំបៅដោះ<កូន>ទេ មិនឃើញនារី កុមារក្មេងនោះទេ ឃើញពួកគេនៅពេញវាលស្រែ ហើយនៅហាលកណ្ដាលថ្ងៃ ជាថ្ងៃដ៏ក្ដៅ។ ខ្ញុំបានឃើញមនុស្សជាច្រើនជា មានជំងឺ កើតជំងឺរាក ហើយនិងជំងឺគ្រុនចាញ់។ ហើយខ្ញុំរាយការណ៍ពីបញ្ហានេះទៅថ្នាក់លើ។" នេះជាសម្ដីរបស់ អៀង ធីរិទ្ធ ជាអតីតរដ្ឋមន្ត្រីសង្គមកិច្ចនៅពេលនោះ។

ហើយលោកស្រីបាននិយាយថា នៅពេលដែលគេបញ្ជូនទៅ បញ្ជូនលោកស្រីទៅសំឡូត <គេប្រាប់>លោកស្រី<>ថាមានការខ្វះរបបអាហារនៅទីនោះ ហើយ តាម៉ុក ចាត់តាំងឲ្យកម្មាភិបាលទៅទីនោះ។ ថាតើ តាម៉ុក <ឬនរណាផ្សេងទៀតបានប្រាប់លោកស្រីអំពីបញ្ហាផ្សេងៗទៀតនៅតំបន់នោះទេ ឧទាហរណ៍>បញ្ហា<ដូចដែលលោកស្រី> អៀង ធីរិទ្ធ បាននិយាយនោះ<>?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! មេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណីសូមអញ្ជើញ!

**លោកស្រី ម៉ារី ហ្គីរ៉ូដ៍៖**

សូមអរគុណលោកប្រធាន។ សូមអធ្យាស្រ័យដែលខ្ញុំរំខានមេធាវីការពារក្ដី។ សូមលោកស្រីផ្ដល់កាលបរិច្ឆេទនៃទស្សនកិច្ចរបស់ អៀង ធីរិទ្ធ។

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** ខ្ញុំគិតថាឆ្នាំ១៩៧៦។ ហើយមានការស៊ើបអង្កេតរឿងអង្កេតហ្នឹង ១៩៧៧។ អ៊ីចឹងសំណួរខ្ញុំបន្ត តើ តាម៉ុក ឬក៏កម្មាភិបាលណាប្រាប់លោកស្រីដែរទេ <អំពី>បញ្ហាដែលកើតនៅភូមិភាគពាយ័ព្យកាលនោះ វាស្រដៀងទៅនឹងអ្វីដែល អៀង ធីរិទ្ធ បាននិយាយ ដែលខ្ញុំអានឲ្យលោកស្រីស្ដាប់អម្បាញ់មិញហ្នឹងទេ?

[១៥:២០:២៦]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោកស្រី ណុប ងឹម៖**

**ឆ៖** ខ្ញុំអត់ស្គាល់ថា តាអៀង ធីរិទ្ធ ណាផង អត់ ឮសូរឈ្មោះ។ ប៉ុន្តែឈ្មោះកន្លែងខ្ញុំមានឈ្មោះ បងរិទ្ធ។ មានឈ្មោះ បងរិទ្ធ នារីនៅស្រែអំបិល។

**ស៖** ខ្ញុំនឹងសួរផ្សេងទៅហ្នឹងពីនេះវិញ។ នៅពេលដែលលោកស្រីទៅដល់សំឡូតដំបូង តើលោកស្រីបានសង្កេតឃើញមានថាការជីវភាពរស់នៅហ្នឹងខ្សត់ខ្សោយ ឬលំបាកលំបិនទេប្រជាជននៅទីនោះ?

**ឆ៖** ចាស ខ្សោយដែរហ្នឹងណា ខ្សោយគ្មានអីហូបទេ គាត់ហូបតែ បើអំបិលវិញគាត់ហូបតែផេះ យកដាក់ទឹកជ្រំធ្វើអំបិល។ ហ្នឹងពួកខ្ញុំទៅគាត់និយាយប្រាប់អ៊ីចឹង ប្រជាជន។ ប៉ុន្តែរឿងឈ្មោះ តាធីរិទ្ធ – អៀង ធីរិទ្ធ ណាខ្ញុំមិនដឹងទេ ខ្ញុំថា បងរិទ្ធៗ។ បងរិទ្ធហ្នឹងនៅស្រែអំបិលដែរ ច្រឡំហើយមិនស្រួល។ ចាស ខ្ញុំមានប៉ុណ្ណឹងឯង។

**ស៖** មិនថ្វីទេ ខ្ញុំនឹងបន្តទៅសំណួរផ្សេងទៀត។ យើងនិយាយដោយសង្ខេបអំពី ភឹម ដែលជាកម្មាភិបាលទទួលបន្ទុកនៅសំឡូតកាលនោះ។ តើលោកស្រីបានដឹងដែរទេថាគាត់បានចែក ឬក៏ផ្តល់របបអាហារទៅប្រជាជនហ្នឹងយ៉ាងដូចម្តេចដែរកាលនោះ?

[១៥:២១:៥៧]

**ឆ៖** ចាស ខ្ញុំអត់បានដឹងដែរ ព្រោះអីខ្ញុំទើបទៅពីនេះទៅ។ អត់ដឹងទេ ប៉ុនគ្រាន់ថាប្រជាជនអត់បាយ ប្រជាជនហូបតែបបរ ឡើងបេះដូងអីអត់ឲ្យហូបទេ។ ខ្ញុំឮគេនិយាយថាអ៊ីចឹងដែរ អ៊ីចេះ! វាដាក់ស្តែងមែន ដូងមួយដើមៗនៅឲ្យណែនៗផ្លាយ ដល់ណែនៗផ្លាយអត់មានប្រជាជនបេះហូបទេ ពួកខ្ញុំទៅប្រជាជនបេះហូបខ្ទេច។

**ស៖** មិនថ្វីទេលោកស្រីសាក្សី។ អ៊ីចឹងខ្ញុំរំឭកការចងចាំរបស់លោកស្រី។ តើលោកស្រីធ្លាប់ឮទេគឺអតីតកម្មាភិបាលនៅភូមិភាគពាយ័ព្យបានបង្កើតឃ្លាំងស្តុកស្រូវអង្ករ ឬក៏ស្បៀងអាហារជាសម្ងាត់ ឬក៏លាក់ដែរឬទេ? គឺគេបានទុកស្បៀងមិនចែកឲ្យប្រជាជនដែរឬទេ?

**ឆ៖** ចាស គឺ ខ្ញុំអត់ដែលបានឃើញទេ អត់ដែលឃើញលាក់ស្បៀងទុកណាៗអត់ទេ។ គឺអត់ដែលបានតាមដានគេផង អត់ដឹង។ ទុកឲ្យហូបប៉ុន្មាន ហូបប៉ុណ្ណឹង មិនដែលលាក់ទៅឯណាទៀត។ យើងខ្ញុំអត់ដឹង ចាស។

[១៥:២៣:៣៥]

**ស៖** អ៊ីចឹងយើងបន្តទៅសំណួរផ្សេងទៀត។ ព្រឹកមិញនេះ លោកស្រីនិយាយបន្តិចអំពីមនុស្ស

ម្នាក់ឈ្មោះ រស់ ញឹម នៅម៉ោង ១០:៥៩ ឆ្លើយទៅសហព្រះរាជអាជ្ញាគឺថា លោកស្រីឮពីឈ្មោះគាត់ ថាធ្លាប់ឮឈ្មោះ ប៉ុន្តែមិនបានជួបទេ។ ហើយនៅម៉ោងដប់មួយលោកស្រីឆ្លើយ<ទៅសហព្រះរាជអាជ្ញាពាក់ព័ន្ធនឹង>ការរាយការណ៍ទៅ តាម៉ុក ឬ រស់ ញឹម ហើយ<>លោកស្រីឆ្លើយថា <លោកស្រី>អត់បានជួប <រស់ ញឹម> ទេ <ពេលលោកស្រីនៅទីនោះ លោកស្រីមិនបានស្គាល់គាត់ផ្ទាល់ទេ> គឺគ្រាន់តែឮគេថាឈ្មោះគាត់ <លោកស្រីបានឮគេនិយាយឈ្មោះគាត់ពីមនុស្សម្នាក់ទៅមនុស្សម្នាក់ទៀត>។ អ៊ីចឹង ខ្ញុំចង់សួរពីអ្វីដែលលោកស្រីឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជាហ្នឹង គឺខុសពីនេះ គឺនៅក្នុង E3/9087, អង់គ្លេស 01155603 នៅក្នុងភាសាខ្មែរ 00733833។ ដានី សួរ<លោកស្រី>ថា៖ "ចុះតាញឹម ម៉េចដែរ? លោកស្រីឆ្លើយថា៖ ខ្ញុំមិនដឹងថា តាញឹម ទៅណាទេ។ ខ្ញុំបានឃើញ<តែមុខគាត់។ តាញឹម>គាត់<>នៅផ្ទះ។" បន្ទាប់មកគេសួរទៀត៖ "នៅពេលដែលលោកស្រីទៅដល់បាត់ដំបង តើលោកស្រីឃើញ តាញឹម ទេ? លោកស្រីឆ្លើយថា៖ ចាស ខ្ញុំឃើញ។ ដានី ក៏សួរទៀត៖ តើឃើញ តាញឹម នៅកន្លែងណា? លោកស្រីឆ្លើយថា៖ ខ្ញុំបានឃើញគាត់នៅខេត្តបាត់ដំបង"។

ដូច្នេះ លោកស្រីសាក្សី ខ្ញុំចង់ដឹងនៅក្នុងចម្លើយដែលលោកស្រីនិយាយទៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជានោះ លោកស្រីឆ្លើយថា គាត់ -- លោកស្រីបានឃើញ តាញឹម នៅខេត្តបាត់ដំបង។ តើតាញឹម ម្នាក់ហ្នឹងដែលជា តាញឹម ដែលលោកស្រីឆ្លើយទៅសហព្រះរាជាអាជ្ញាថា រស់ ញឹម ហ្នឹង ឬក៏ញឹម ណាផ្សេងវិញទេ?

**ផ៖** ខ្ញុំមិនដែលឆ្លើយ ញឹម ណំា។ ឆ្លើយថា តាម៉ុក។ រស់ ញឹម ដឹងណា ខ្ញុំឮសួរតែឈ្មោះគេនិយាយដែរហ្នឹង ខ្ញុំអត់ស្គាល់ផង។ ច្រឡំហើយ ឮសួរតែឈ្មោះ។ ខ្ញុំនិយាយតាំងពីព្រឹក ថាសួរតែឈ្មោះតើ។ ខ្ញុំអត់ស្គាល់ទេ ស្គាល់តែ តាម៉ុក។

[១៥:២៦:០៤]

**សៈ** ប្រហែលជាខ្ញុំយល់ច្រឡំទេ។ សំណួរមួយទៀតពីបញ្ហានេះ តើលោកស្រីធ្លាប់ឮឈ្មោះណាផ្សេងទៀត ពីឈ្មោះ រស់ ញឹម ដែលគេហៅឈ្មោះផ្សេងពីហ្នឹងទេ?

**ផ៖** ខ្ញុំមិនដែលស្គាល់ផង អត់ដែលស្គាល់សោះ ឮតែឈ្មោះ។ បើស្គាល់ ប្រាប់ថាស្គាល់ហើយខ្ញុំមិនចេះលាក់ទេ។

**សៈ** ខ្ញុំមិនគិតថាលោកស្រីស្គាល់ទេ ប៉ុន្តែខ្ញុំគ្រាន់តែចង់ដឹងឲ្យច្បាស់តែប៉ុណ្ណឹងទេ។ ខ្ញុំនឹងបន្តទៅវគ្គផ្សេង។ តើលោកស្រីធ្លាប់ឮពីផែនការអ្វីមួយរបស់កម្មាភិបាលភូមិភាគពាយ័ព្យ ដើម្បីធ្វើរដ្ឋប្រហារ

ផ្តួល ប៉ុល ពត ដែរឬទេកាលនោះ?

**ឆ៖** ខ្ញុំអត់ដឹងទេ អស់ដឹងសោះ ព្រោះឋានៈប្រហែលខ្ញុំ គេប្រើតែមើលគោ ប្រែតែរែកអំបិលតើ មានប្រើធ្វើស្អី។ អត់បានដឹងអី យល់អីទៅប្រជុំទៅអីឯណានឹងគេ អត់សោះខ្ញុំ។ អត់។

**ស៖** មិនអ្វីទេសាក្សី។ ព្រឹកមិញនេះលោកស្រីឆ្លើយទៅសហព្រះរាជអាជ្ញា គឺថានៅក្នុងអង្គប្រជុំ គឺថាគេនិយាយអំពីខ្មាំង ហើយគឺគេឲ្យកម្មាភិបាលតាមដានរកខ្មាំង។ អ៊ីចឹង<ពាក់ព័ន្ធនឹងបញ្ហានេះ ខ្ញុំនឹង>អានចម្លើយរបស់សាក្សី<ផ្សេងទៀត>នៅក្នុងសំណុំរឿង <ហើយចង់>ដឹងថាតើអ្វីដែលគាត់និយាយអំពីខ្មាំងនោះ តើវាដូចគ្នានឹងអ្វីដែលលោកស្រីដឹងដែរឬទេ? លោកប្រធាន គឺថាឯកសារ E3/9579 ជាកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សី ដែលរក្សាការសម្ងាត់ គឺ 2-TCW-1038 គឺសំណួរ និងចម្លើយ១៣។

លោកស្រីសាក្សីនេះ គឺបុគ្គលម្នាក់ទៀតនិយាយអំពីស្ថានភាពខ្មាំងនៅក្នុងភូមិភាគពាយ័ព្យ។ នេះ គេសួរទៅគាត់៖ "តើលោកដឹង ថាតើកម្មាភិបាលនិរតីមកជំនួសពួកពាយ័ព្យហ្នឹងដោយមូលហេតុអី? គាត់ឆ្លើយថា៖ គេចោទអ្នកទាំងនោះថាជាប់ខ្សែខ្មែរក្រហមខាងវៀតមិញ ហើយនិង<ប្រធាន>គណៈភូមិភាគ សោ ភឹម នៅបូព៌ា។ <ភូមិភាគទាំងពីរនេះបានងាកមកប្រឆាំងនឹងប៉ុល ពត។> តាមអ្វីដែលខ្ញុំសង្កេត គឺថាខ្មែរក្រហមមានបី ឬក៏បួនក្រុម។ ក្រុមទី១ គឺក្រុមវៀតមិញ។ ក្រុមទី២ គឺក្រុមខ្មែរក្រហមជាតិនិយម។ ក្រុមទី៣ គឺក្រុមនិយមសីហនុ។ ក្រុមទី៤ គឺក្រុមខ្មែរក្រហមមកពីប្រទេសចិន ដែលមានប៉ុល ពត នៅក្នុងនោះផង។"

លោកស្រីសាក្សី តើលោកស្រីធ្លាប់ឮអំពីការចោទប្រកាន់ប្រហាក់ប្រហែលនេះដែរទេថា កម្មាភិបាលភូមិភាគពាយ័ព្យមានទំនាក់ទំនងជាមួយនឹងកម្មាភិបាលនៅភូមិភាគបូព៌ាឈ្មោះថា សោ ភឹម នោះ?

[១៥:២៩:២៨]

**ឆ៖** ចាស ខ្ញុំអត់ដឹងទេ ខ្ញុំអត់ដែលដឹងសោះ។ អត់ដែលដឹងសភាពការណ៍គេម៉េចៗក៏ខ្ញុំអត់ដឹងដែរ។ អត់ដឹងសោះខ្ញុំ។ ខ្ញុំអត់ដឹងមែនតើ បើដឹងខ្ញុំនិយាយហើយ នេះអត់ដឹងសោះ។ សភាពការណ៍គេអាម៉េចក៏ខ្ញុំអត់ដឹងដែរ។

**ស៖** តើលោកស្រីធ្លាប់ឮ ថាតើមានគេបង្កើតជាបក្សពួក ក្រុមអី ដើម្បីប្រឆាំងអ្នកណាផ្សេងក្រុមផ្សេងទេនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរបស់ខ្មែរក្រហម?

**ឆ៖** យើងខ្ញុំសូមជម្រាបដោយស្មោះ គឺខ្ញុំអត់ដឹងទេ អត់ដឹងសោះហើយលោកអើយ អ៊ីចឹងៗអត់

ដឹងទេៗ អត់ដឹងគេជម្រាប ពួកបក្សអីអត់ដឹងទេខ្ញុំ។ មនុស្សល្ងង់អ្នកណាគេឲ្យដឹងនោះ *(ឮមិនច្បាស់)* នខ្ទាក់មួយផង។

**ស៖** មិនបញ្ហាទេ។ ឥឡូវនេះខ្ញុំចូលដល់វគ្គចុងក្រោយនៃសំណួររបស់ខ្ញុំ។ នេះជាហេតុការណ៍ដែលលោកស្រីបាននិយាយនៅពេលសម្ភាសន៍ទៅមជ្ឈមណ្ឌលឯកសារកម្ពុជាអំពីការចាប់ខ្មាំង។ ហើយពាក់ព័ន្ធទៅនឹងអ្វីដែលលោកស្រីបានឆ្លើយសហព្រះរាជអាជ្ញាដែរ ប៉ុន្តែ<ហេតុការណ៍នេះមិនមាននៅក្នុងសក្ខីកម្មរបស់លោកស្រីទេ>។ លោកប្រធាន E3/9087, ERN ហ្នឹងគឺ 01155613 ដល់ 15 ភាសាអង់គ្លេស, 00733840 ដល់ 41 ជាភាសាខ្មែរ, អត់មានអត្ថបទបារាំងទេ។ លោកស្រីសាក្សី នេះជាហេតុការណ៍ដែលលោកស្រីប្រាប់ទៅ ឡុង ដានី។ “ដានី សួរថា៖ នៅពេលដែលលោកស្រីនៅទីនោះ តើលោកស្រីបានចាប់អ្នកណាម្នាក់ដើម្បីយកទៅអប់រំកែប្រែទេពេលដែលគេធ្វើខុស? ហើយគាត់ លោកស្រីឆ្លើយថា៖ យើងបានតាមដាន< តាវុន ហើយយើងបានរកឃើញថា គាត់មានកន្លែងសម្ងាត់នៅភ្នំលើ។> ហើយគាត់ក្បត់យើង គាត់បានប្រជុំសម្ងាត់ ហើយគេចាប់ខ្លួនគាត់ដើម្បីយកទៅអប់រំកែប្រែ”។ លោកស្រីសាក្សី លោកស្រីនិយាយពីមនុស្សម្នាក់ឈ្មោះ<តាវុន> លួចប្រជុំស្ងាត់ៗ។ តើការប្រជុំស្ងាត់ៗរបស់ជាសម្ងាត់របស់គាត់នោះ គេប្រជុំអំពីអ្វី?

[១៥:៣១:៥៨]

**ផ៖** ចាស--

**ប្រធានអង្គជំនុំ៖**

លោកស្រីសាក្សីកុំអាលទាន់ឆ្លើយ! អញ្ជើញមេធាវីនាំមុខដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន សូមកែពាក្យឈ្មោះរបស់បុគ្គលដែលត្រូវបានលោកនិយាយអម្បាញ់-មិញ មិនមែនឈ្មោះ តាវឿន ទេ ឈ្មោះ តាវុន។ អរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសាក្សីឆ្លើយ!

**សួរដោយលោកស្រី ដូរីន ជិន៖**

**ស៖** សូមអធ្យាស្រ័យ គឺ តាវុន។ លោកស្រីសាក្សី លោកនិយាយថា តាវុន មានបើកអង្គប្រជុំសម្ងាត់ៗ។ តើលោកស្រីដឹងទេ តាវុន មាននិយាយអំពីអ្វីខ្លះដែរ?

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**លោកស្រី ណុប ងឹម៖**

**ឆ៖** តាវុន ហ្នឹងចាស់យូរហើយ។ គាត់អត់មាននិយាយអីទេ និយាយតែណែនាំឲ្យបានសុខសប្បាយគ្នា ឲ្យចេះសាមគ្គីគ្នាហ្នឹង តាវុន ហ្នឹងគាត់អត់មានដែលនិយាយអីគាត់ទេ គាត់ខ្លាចចង់ងាប់នោះ គាត់ប្រធានសហករណ៍យូរហើយ អត់មាននិយាយអីទេ តាវុន។ ខ្ញុំចេះតែឆ្លល់ រឿនៗ ខ្ញុំឆ្ងល់ដែរ ចាស។

**ស៖** ខ្ញុំខ្លាចតែខ្ញុំយល់ច្រឡំមិនច្បាស់ទេ តាវុន។ តើលោកស្រីមានបានចូលរួមប្រជុំសម្ងាត់នោះដែរទេ?

[១៥:៣៣:២១]

**ឆ៖** គាត់ប្រជុំ ប៉ុន្តែខ្ញុំអត់បានទៅប្រជុំទេ ប្រជុំសម្ងាត់ៗដូចថាមានការប្រុងប្រយ័ត្នអ៊ីចឹងទៅ កុំឲ្យមានខ្មាំងអីចូលជិតអ៊ីចឹងទៅណ៎ា ខ្លាចក្រែងលោមានអាណាប៉ងធ្វើបាបអ៊ីចឹងទៅណ៎ា វាមិនចេះអត់ទេ គាត់ប្រជុំសម្ងាត់អ៊ីចឹងមានប្រជុំអីឲ្យវែងឆ្ងាយទេ។ ហ្នឹងតាមឮគាត់និយាយទេ គាត់និយាយខ្លួនគាត់អ៊ីចឹងឯង តែខ្ញុំអត់មានបានទៅប្រជុំអីពិភាក្សាអីជាមួយគាត់អត់ទេ។ ប៉ុនខ្ញុំនិយាយ តាវុន ហ្នឹង តាវុនហ្នឹងគាត់ប្រធានឃុំយូរហើយ អ៊ីចេះ! ពួកខ្ញុំទើបទៅ ហើយដល់រត់ៗបែកគ្នារតោករតាកអស់ទៅ។ អាហ្នឹងខ្ញុំបញ្ជាក់។

**ស៖** ក្នុងចម្លើយរបស់លោកស្រី ខ្ញុំសូមអានឈ្មោះគាត់ឲ្យត្រឹមត្រូវម្តងទៀត។ គឺ តាវុន ក្បត់លោកស្រី ហេតុដូច្នេះឯងទើបគាត់ត្រូវបានគេចាប់ខ្លួនយកទៅអប់រំ។ តើលោកស្រីមានបានស្តាប់ឮពីអ្នកដទៃថា នែ! អាអំពើក្បត់ហ្នឹងវាពាក់ព័ន្ធនឹងអ្វីខ្លះទេ?

**ឆ៖** ដូចអត់មានក្បត់ទេ អត់ក្បត់ទេ គ្រាន់តែនិយាយ យើងចេះតែតាមដានគ្នាទៅវិញទៅមកទៅណ៎ា ដូចយើងនេះអ៊ីចឹងណ៎ា មានក្បត់ទេ គាត់អត់មានក្បត់អីគាត់ អត់ផង។

**លោកស្រី ដូរីន ជិន៖**

សូមអរគុណច្រើនចំពោះភាពអត់ធ្មត់របស់លោកស្រី លោកស្រីសាក្សី។

លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកមេធាវី។

សូមអញ្ជើញលោកមេធាវីការពារក្តី លោក ខៀវ សំផន មានសំណួរលើសាក្សីរូបនេះ។

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ជម្រាបសួរលោកស្រីសាក្សី <ខ្ញុំ>ឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិការពារក្តីលោក ខៀវ សំផន។ ខ្ញុំមានសំណួរពីរ<បី>តូចទេដែលចង់សួរបញ្ជាក់លោកស្រី ហើយលោកមេធាវី គង់ សំអុន គាត់មានសំណួរមួយចំនួនទៀត។ ខ្ញុំចង់ត្រឡប់មកនិយាយអំពីចំណុចមួយដែលលោកស្រីឆ្លើយជូនលោកចៅក្រម ឡាវែន៍។ <ហើយវារឹតតែច្បាស់ទៅទៀត នៅពេលលោកស្រីឆ្លើយនឹងសំណួររបស់សហការីខ្ញុំ> លោកស្រីឆ្លើយថា ក្រោយពីរៀបការហើយហ្នឹង លោកមិនដឹងថា គេតាមដានលោកស្រី ឬក៏អត់ទេ ក៏ប៉ុន្តែលោកស្រីគ្រាន់តែខ្លាចគេតាមដាន។ ខ្ញុំនិយាយអ៊ីចឹង តើត្រឹមត្រូវទេ?

[១៥:៣៥:៥៦]

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** ចាស និយាយអ៊ីចឹងត្រឹមត្រូវហើយ។ ខ្ញុំនិយាយថាអ៊ីចឹងមែន ខ្លាចគេតាមដាន។

**ស៖** ហើយមុននេះ ពេលដែលលោកស្រីឆ្លើយទៅចៅក្រម ឡាវែន៍ លោកស្រីបាននិយាយអំពីវត្តមានល្ពបនៅសំឡូត ហើយលោកស្រីថាជាកូនរបស់អ្នកភូមិ។ ហើយពួកហ្នឹង គឺមានវត្តមាននៅស្រុកសំឡូតហ្នឹង តាំងពីមុនពេលដែលលោកស្រីទៅដល់ទៅទៀត។ ខ្ញុំយល់អ៊ីចឹង ត្រឹមត្រូវទេ?

**ឆ៖** គាត់? នៅនឹងយូរហើយ គេជាកូនប្រជាជនចាស់យូរហើយ ចំពោះខ្ញុំទើបទៅដល់ ហើយចេះខ្លាចទៅណា។ តែខ្ញុំមានយោបល់តែប៉ុណ្ណឹងទេ។

**ស៖** សំណួររបស់ខ្ញុំហ្នឹង គឺវាចេញពីចម្លើយដែលលោកស្រីទើបតែឆ្លើយ។ បើលោកស្រីទៅសំឡូតក្នុងឋានៈជាសមាជិកលេខាស្រុក គឺលោកស្រីជាអនុលេខាស្រុក។ ដូច្នេះ តើឋានៈនេះមិនធ្វើឱ្យលោកស្រីមានសិទ្ធិអំណាចអីទៅលើល្ពបទាំងអស់ហ្នឹងទេ មែនទេ?

**ឆ៖** ចាស អត់មែន អត់ហ៊ានជាមួយគេទេ។ ហើយសិទ្ធិប្រហែលប៉ុនខ្ញុំៗអី ទៅធ្វើអីគេកើត។ បើខ្ញុំមិនចេះមាននយោបាយអីផង ល្ងង់អ៊ីចេះនេះ។

[១៥:៣៧:៤៤]

**ស៖** ដូច្នេះ មានន័យថា គណៈស្រុកមិនមានទំនាក់ទំនងអ្វី ឬក៏មិនមានសិទ្ធិអំណាចអ្វី គ្រប់គ្រងលើមេភូមិ ឬក៏ល្ពបទេ មែនទេ?

**ឆ៖** ចាស អាហ្នឹង បើគេត្រូវ គេសាមគ្គីគ្នា សាមគ្គីគ្នាដែរហ្នឹង ត្រូវអត់ អត់ដែលហ្នឹង។ ទំនាក់

ទំនងគ្នា ក៏ទំនាក់ទំនង ប៉ុន្តែច្រើនទំនាក់ទំនងគ្នាដែរ ចាស។

**ស៖** ខ្ញុំមិនសូវយល់ចម្លើយរបស់លោកស្រី។ លោកស្រីថា ពេលខ្លះពួកគេសាមគ្គីគ្នាហ្នឹង លោកស្រីចង់សំដៅទៅលើអ្នកណា? អ្នកណាសាមគ្គីជាមួយអ្នកណា?

**ឆ៖** អំមិញបានសួរខ្ញុំ ឃុំ -- អំនែ! ភូមិ ហើយនិងខាង ពួកខាងខ្ញុំ ខាងស្រុក។ ត្រូវតែសាមគ្គីគ្នាហ្នឹងឯង។ ប៉ុនសាមគ្គីត្រង់ទេ មិនមែនសាមគ្គីក្បត់ទេណា។ មិនមែនសាមគ្គីវៀចវេរទេណា។ សាមគ្គីត្រង់ ដោយល្អ ត្រឹមត្រូវ ចេះសាមគ្គីគ្នា។

[១៥:៣៩:១៦]

**ស៖** អ៊ីចឹង ក្នុងបរិបទហ្នឹង ខ្ញុំចង់សួរលោកស្រីថា បើអ៊ីចឹង ម៉េចក៏លោកស្រីខ្លាច ខ្លាចពួកឈ្លបដែលជាកូនរបស់អ្នកភូមិចាស់ៗហ្នឹង បើពួកហ្នឹងធ្វើការនៅឃុំដែរនោះ។ អ៊ីចឹងមានន័យថា នៅក្នុងភូមិ នៅក្នុងឃុំ នៅក្នុងភូមិអីហ្នឹង មានអ្នកធ្វើការដែលមិនសូវត្រូវគ្នា ឬយ៉ាងម៉េច បានជាលោកស្រីខ្លាចហ្នឹង?

**ឆ៖** ចាស ចេះតែខ្លាចទៅ ព្រោះអីខ្លាចមិនសូវ -- ដូចថា ត្រូវគ្នាៗ ប៉ុន្តែការពារ ខ្លាចហើយ ប៉ុន្តែមិនដែលធ្វើអីគេទេ ចេះតែខ្លាចៗទៅ។ ចាស ខ្ញុំអស់ចម្លើយហើយ មានតែប៉ុណ្ណឹងទេ។ ឆ្លើយពីរបីដងដដែល។

**ស៖** ចំណុចចុងក្រោយមុននឹងប្រគល់វេទិកាជូនលោកមេធាវី គង់ សំអុន ខ្ញុំយល់តាមចម្លើយរបស់លោកស្រី ថាលោកស្រីរៀបការប៉ុន្មានខែមុនពេលវៀតណាមវាយចូល។ លោកស្រីនិយាយថា ឆ្នាំ៧៨ ដែលលោកស្រីរៀបការ គឺពេលហ្នឹងគឺពេលរដូវដាំដុះស្រូវ។ បើលោកស្រីមិនចាំខែទេ អ៊ីចឹងមានន័យថា គឺនៅពាក់កណ្ដាលចុងក្រោយនៅឆ្នាំ៧៨មែនទេ ពេលដែលលោកស្រីរៀបការហ្នឹង?

**ឆ៖** ការខែ៦ ៧៨។ ហើយការបានដល់ជួបហើយ បានរត់ៗយួន រត់បែកបាក់គ្នារហូត។ មិនដឹងខែប៉ុន្មានទេ ខ្ញុំភ្លេចអស់ហើយ យូរហើយ ខ្ញុំអត់មានព្យាយាមអី ភ្លេចអស់ហើយ។ ការខែ៨ ឆ្នាំ៧៨ ៧៨ ខែ មិនដឹងខែប៉ុន្មានទេ មើលក្នុងនោះមានដឹងអត់? បើខ្ញុំមិនចាំដែរហ្នឹងណា។ វាយូរពេកហើយ។ ឆ្លើយទៅមុខទៅក្រោយអ៊ីចឹង។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ សុំប្រគល់វេទិកានេះជូនសហភាតារបស់ខ្ញុំ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកស្រីមេធាវី។

សូមអញ្ជើញលោកមេធាវីការពារក្តី លោកខៀវ សំផន!

[១៥:៤១:៥៤]

**សួរដោយលោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ សូមគោរពអង្គជំនុំជម្រះ។ សូមជម្រាបសួរអ្នកស្រី ខ្ញុំមេធាវី គង់ សំអុន ជាសហមេធាវីជាតិការពារក្តីលោក ខៀវ សំផន។ ហើយតទៅនេះ ខ្ញុំមានសំណួរមួយចំនួនតូចដើម្បីសួរបញ្ជាក់។

**ស៖** ពីរសៀលថ្ងៃនេះ លោកស្រីបាននិយាយអំពីការគោរពអង្គការវិន័យ និងការគោរពការចាត់តាំង។ ហើយលោកស្រីបានមានប្រសាសន៍ថា ដោយសារតែមានការចាត់តាំងបានអ្នកស្រីព្រមរៀបការ ហើយបើសិនជាប្តីរបស់លោកស្រីមកស្តីដណ្តឹង មកស្នើសុំអ្នកស្រីនៅពេលនោះ គឺអ្នកស្រីប្រកែកហើយ។ អ្នកស្រីចាំបានសម្តីនេះ លោកស្រីនិយាយទេ?

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** ចាស ខ្ញុំចាំ ព្រោះអីបានគាត់មកនិយាយ មកសួរខ្ញុំ ខ្ញុំអត់យកមែនតើ។ កាលជំនាន់ហ្នឹង គ្មានចង់បានប្តី ចង់បានអីទេ ពិបាកអីម៉េះៗនោះ។ ប៉ុន្តែគាត់អត់មានដឹងសោះ ខ្ញុំអត់មានដឹងសោះ។ គាត់ការឲ្យតែម្តង។ បើសិនមកសួរខ្ញុំ ខ្ញុំឆ្លើយអ៊ីចឹង អត់យកទេ។ ហ្នឹងខ្ញុំឆ្លើយអ៊ីចឹងមែន។

**ស៖** បាទ សូមអរគុណ។ អ្នកស្រីអាចបញ្ជាក់ពីលទ្ធភាពជាក់ស្តែងដែលអ្នកស្រីអាចធ្វើបាន ក្នុងករណីដែលអ្នកស្រីថាបដិសេធមិនៗរៀបការហ្នឹង តើអ្នកស្រីអាចប្រឈមមុខនឹងបញ្ហាអីទេ នៅពេលនោះ?

**ប្រធានអង្គជំនុំ៖**

អ្នកស្រីសាក្សី ចាំមីក្រូហ្វូនប្រតិបត្តិការចេញភ្លើងក្រហមសិន ចាំឆ្លើយ!

[១៥:៤៣:៤១]

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** កាលហ្នឹងបើសិនណាជំនាន់ហ្នឹង បើគាត់មកសួរខ្ញុំត្រឹមត្រូវ អត់មានអាងអី ខ្ញុំអាងមិនយកហ្នុង ពិបាកណាស់ ពិបាករត់លូន។ មានកូនមានចៅ ពិបាករត់លូនហ្នឹងហ្នុង។ មួលតែដៃអាវជើងខោមួយថ្ងៃៗ មួយខែៗ ពកូន ពពោះរត់។ អ៊ីចឹងខ្ញុំខ្ជិលណាស់ ខ្ញុំឃើញគេរត់អ៊ីចឹង ខ្ញុំខ្ជិលចង់យកណាស់

ចង់ខ្ជិលចង់យកប្ដីតែម្ដង។ បើនិយាយស្នូរខ្ញុំ ខ្ញុំមិនយកទេ។ ខ្ញុំប្រាប់តាមត្រង់អ៊ីចឹង និយាយដាច់ប៉ិតអ៊ីចឹង ហ្មង។ មែនតើ ខ្ញុំខ្ជិលណាស់។ អាហ្នឹង ខ្ញុំអាងអ៊ីចឹងឯង អាងខ្ជិលមានកូនមានចៅ វត់ទៅមិនដឹងងាប់ហើយរស់។

**ស្នួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ចុះអ្នកស្រីអាចបញ្ជាក់ពីការគោរពអង្គការចាត់តាំង អ្នកស្រី វាមានផ្ដល់ប្រយោជន៍អ្វីខ្លះដល់អ្នកស្រី ក្នុងការគោរពអង្គការចាត់តាំង ក្នុងឋានៈអ្នកស្រីជានារីបដិវត្តន៍ម្នាក់ក្នុងសម័យនោះ?

**ឆ៖** ខ្ញុំថាគោរពអង្គការចាត់តាំង គឺគេចាត់តាំងអីទៅ គឺធ្វើ កុំឲ្យប្រកែក គ្មាននរណាយកកាប់សម្លាប់អីទេ យើងធ្វើស្លូតអ៊ីចឹង ប៉ុន្តែកុំប្រកែកគេ យើងគោរពអង្គការចាត់តាំង កុំឲ្យមានប្រកែកទៅ វាវែងឆ្ងាយ ខ្ជិល ចង់ឲ្យមានមួយរស់គេដែរ កុំឲ្យប្រកែក។ ចាស អាហ្នឹងអ៊ីចឹង ខ្ញុំឆ្លើយអ៊ីចឹង ព្រោះអីខ្ញុំដឹង ខ្ញុំនឹកឃើញអ៊ីចឹងហើយ។

[១៥:៤៥:១៨]

**ស៖** បាទ សូមអរគុណ។ អ្នកស្រីបានប្រើពាក្យមួយជាញឹកញាប់ ទាក់ទងទៅនឹងការរៀបអាពាហ៍ពិពាហ៍របស់អ្នកស្រី អ្នកស្រីបាននិយាយថា "ចាប់ដាក់ឲ្យរៀបការ"។ លោកស្រីប្រើពាក្យថា "ចាប់ដាក់"។ ខ្ញុំចង់ឲ្យអ្នកស្រី ពន្យល់ពាក្យចាប់ដាក់ហ្នឹង អ្នកស្រីចង់សំដៅទៅលើអ្វី?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកមេធាវី ហាក់បីដូចជាសួរសំណួរច្រំដដែលៗហ្នឹង។ ហើយយើងបានស្ដាប់ឮសំណួរនេះ ពីសហមេធាវីជាតិការពារក្ដីលោក នួន ជា បានសួររួចមកហើយ។ ដូច្នេះ បើសិនណាជាលោកមានសំណួរដែលមិនទាន់បានឆ្លើយនោះ គឺថាមិនថ្វីទេ តែកុំសួរសំណួរដដែលៗ។

**លោក គង់ សំអុន៖**

សូមអរគុណលោកស្រី។ ខ្ញុំបានស្ដាប់ឮសម្ដីរបស់អ្នកស្រីសាក្សី ឆ្លើយជាភាសាខ្មែរនូវការប្រើពាក្យ "ចាប់ដាក់" ក៏ប៉ុន្តែជាភាសាអង់គ្លេសថា បកប្រែមកថា ជាការបង្ខំឲ្យរៀបការ។ ដូច្នេះពាក្យនេះវាអត់ដូចគ្នា។ គឺថាចាប់ដាក់នេះ ក្នុងន័យខ្មែរវាអាចជាការផ្គូផ្គងគ្នា។ អ៊ីចឹងន័យវាមានលក្ខណៈមិនដូចគ្នាទេ ដែលសហព្រះរាជអាជ្ញាគាត់បានលើកសំណួរនេះដែរ ហើយដោយសារគាត់ទទួលការបកប្រែមកថាជាការបង្ខំ។ អ៊ីចឹងសំណួររបស់គាត់ គាត់បង្ហាញពីការរៀបការបែបបង្ខំនេះទៅវិញ។ ចំណុចនេះ វា

ប្រាសចាកពីអង្គហេតុដែលសាក្សីបានផ្តល់។ ដូច្នេះហើយបានខ្ញុំ ចង់បញ្ជាក់ចំណុចនេះសាឡើងវិញជាមួយនឹងអ្នកស្រីសាក្សីនេះបាទ។

[១៥:៤៧:០៩]

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

ខ្ញុំមិនបានស្តាប់ឮសំឡេងទេ ប៉ុន្តែវាអាចបញ្ហាភាសាទេមើលទៅ។

**លោក គង់ សំអុន៖**

បាទ ហេតុដូច្នេះហើយបានខ្ញុំចង់បញ្ជាក់ទៅលើពាក្យនេះ។ ថាតើអ្នកស្រីគាត់និយាយពីការចាប់ដាក់ឲ្យរៀបការនេះ វាមានក្នុងន័យដូចម្តេច តាមការជួបប្រទះផ្ទាល់របស់អ្នកស្រីនេះ។ សូមអនុញ្ញាតលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី ចោទសំណួរ!

លោកស្រីសាក្សី ស្តាប់បានសំណួរនេះទេ? បើស្តាប់បានលោកស្រីឆ្លើយ!

**លោកស្រី ណុប ង៉ឹម៖**

**ឆ៖** ចាស ខ្ញុំឆ្លើយបាន។ គឺចាប់ដាក់ ហើយនិង យកមករៀបការជាបង្ខំ ដូចគ្នា។ ចាសពាក្យតែមួយ ចាសហ្នឹងពាក្យតែមួយ និងហើយចាប់ដាក់ វាមានពាក្យច្រើន ចាប់ដាក់ បង្ខំ បង្ខំចាប់បង្ខំ ចាប់ដាក់ ដូចគ្នា ចាស។

[១៥:៤៨:២៩]

**សួរដោយលោក គង់ សំអុន៖**

**ស៖** បាទ សូមអរគុណ។ ចុះអ្នកស្រីនិយាយអំពីការគោរពវិន័យ ហើយដែលអ្នកស្រីបញ្ជាក់ថាអ្នកស្រីមិនប្រកែកទេ ទោះបីលោកស្រីឃើញមនុស្សពីរនាក់ទៀត ដែលគាត់បានចាកចេញពីពេលរៀបការ នៅពេលដែលការប្រព្រឹត្តកំពុងតែរៀបចំទៅនោះ គាត់បានរត់ចេញពីកន្លែងរៀបការ។ ចុះហេតុអីបានអ្នកស្រីមិនធ្វើដូចអ្នកពីរនាក់នោះ?

**ឆ៖** ចាស គឺហ្នឹងគំនិតខ្លួនខ្ញុំ ខ្ញុំអត់រត់ដូចគេ។ គឺក្មេងៗវាគិតអត់ដល់ វារត់ហ្នឹងហើយ។ ខ្ញុំគិតដល់ ខ្ញុំអត់រត់ ខ្ញុំធ្វើគោរពអង្គការចាត់តាំង។ ចាត់តាំងអី ចាត់តាំងឲ្យយើងមានប្តី ហើយយើងធ្វើត្រណុងត្រណាំងឥឡូវក៏ពិបាកដែរ យើងចាស់ៗហើយ។ នឹកឃើញអ៊ីចឹងចំពោះខ្លួនខ្ញុំផ្ទាល់។ ចាស ប៉ុណ្ណឹង។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំអាចសរុបមកថា អ្នកស្រីអាចមិនពេញចិត្តចំពោះការរៀបការជាមួយប្ដីអ្នកស្រីដែលរៀបចំដោយអង្គការ ក៏ប៉ុន្តែអ្នកស្រីមិនបានបង្ហាញឆន្ទៈណាមួយដើម្បីប្រឆាំង ឬក៏ជំទាស់ទៅនឹងការរៀបការនេះទេ។ តើអ៊ីចឹងត្រឹមត្រូវទេ?

[១៥:៥០:១៧]

**ឆ៖** ចាស ត្រឹមត្រូវហើយ ខ្ញុំអត់ប្រឆាំងៗទេ ធ្វើម៉េចខ្ញុំវាចាស់ៗហើយ។ ដូចដែលខ្ញុំជម្រាបតាមត្រង់មកពីមុនមកអ៊ីចឹង ចាស់ៗហើយខ្ជិលប្រឆាំង នឹកឃើញប្រឆាំងទៅមិនបានប្រយោជន៍អី។ គោរពទៅ ថែរក្សាគ្នាទៅ។ ចាស តែប៉ុណ្ណឹងទេ។

**លោក គង់ សំអុន៖**

សូមអរគុណលោកស្រី។ លោកប្រធាន ខ្ញុំអស់សំណួរហើយ។

**ប្រធានអង្គជំនុំ៖**

អរគុណលោកមេធាវី។ សវនាការស្ដាប់សក្ខីកម្មសាក្សី ណុប ង៉ឹម ដល់ទីបញ្ចប់ហើយ។ អង្គជំនុំជម្រះអរគុណលោកស្រី ណុប ង៉ឹម ដែលបានចំណាយពេលវេលាមកផ្ដល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះក្នុងឋានៈជាសាក្សីក្នុងរយៈពេល១ថ្ងៃនេះ លោកស្រីអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនសាក្សីរូបនេះវិលត្រឡប់ទៅលំនៅដ្ឋានរបស់គាត់វិញ។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការថ្ងៃនេះត្រឹមនេះ ហើយសវនាការបន្តនៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៦ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ សវនាការនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងធ្វើសវនាការលើការដាក់បង្ហាញឯកសារគន្លឹះដោយតំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខដើមបណ្ដឹងរដ្ឋប្បវេណី។ សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាកំណត់។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីររូប នួន ជា និង លោក ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃអ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃអង្គារ ទី០៦ ខែកញ្ញា ឆ្នាំ២០១៦ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សូមអញ្ជើញសម្រាក៕

*(សវនាការផ្អាកនៅម៉ោង ១៥:៥២ នាទី)*